ធនាគារជាតិនៃកម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.



# របាយការណ៍ប្រចាំឆ្នាំ ២០២១





# មាតិកា

* * *

**អារម្ភកថា**.......... i
**អក្សរកាត់**.......... v
**ខ្លឹមសារសង្ខេប**.......... ix
**ផ្នែកទី១ - របាយការណ៍ប្រចាំឆ្នាំ២០២១**
I- **ស្ថានភាពសេដ្ឋកិច្ចពិភពលោក**.......... ១
II- **ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា**.......... ២
១- កំណើនសេដ្ឋកិច្ច.......... ២
២- ស្ថានភាពអតិផរណា.......... ៦
៣- អត្រាប្តូរប្រាក់.......... ៧
៤- ស្ថានភាពជញ្ជីងទូទាត់.......... ៨
៥- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ.......... ១១
III- **ការគ្រប់គ្រងរូបិយវត្ថុ**.......... ១២
១- ស្ថានភាពរូបិយវត្ថុ.......... ១២
២- ការអនុវត្តនយោបាយរូបិយវត្ថុ.......... ១៣
IV- **ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា**.......... ១៧
១- ស្ថានភាពទូទៅ.......... ១៧
២- វិស័យធនាគារ.......... ១៩
៣- វិស័យមីក្រូហិរញ្ញវត្ថុ.......... ២១
៤- វិស័យភតិសន្យាហិរញ្ញវត្ថុ.......... ២២
៥- គ្រឹះស្ថានឥណទានជនបទ.......... ២៣
៦- អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន.......... ២៣
៧- ការត្រួតពិនិត្យ និងបញ្ញត្តកម្ម.......... ២៤
៨- កិច្ចការពារអតិថិជន និងបរិយាបន្នហិរញ្ញវត្ថុ.......... ២៤
V- **ការផ្គត់ផ្គង់សេវាធនាគារកណ្តាល**.......... ២៦
១- ប្រព័ន្ធទូទាត់សងប្រាក់.......... ២៦
២- សេវាផ្ទេរប្រាក់តាមរយៈធនាគារជាតិនៃកម្ពុជា.......... ២៧
៣- សេវាផាត់ទាត់ឧបករណ៍ទូទាត់សងប្រាក់.......... ៣១
៤- សេវាគ្រប់គ្រងគណនី.......... ៣៥
៥- ការគ្រប់គ្រងចរាចរណ៍ធនបត្រ.......... ៣៦

**VI-ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម** ..................... ៣៧
១- ការពង្រឹងក្របខ័ណ្ឌនិងការអនុវត្តច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ..................... ៣៨
២- ការងារវិភាគប្រតិបត្តិការ ..................... ៣៩
៣- កិច្ចសហប្រតិបត្តិការរបស់ ស.ហ.ក ..................... ៣៩
**VII- កិច្ចសហប្រតិបត្តិការអន្តរជាតិ** ..................... ៤១
១- កិច្ចសហប្រតិបត្តិការពហុភាគី ..................... ៤១
២- កិច្ចសហប្រតិបត្តិការទ្វេភាគី ..................... ៤៤
**VIII- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា** ..................... ៤៥
១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល ..................... ៤៥
២- ការអភិវឌ្ឍធនធានមនុស្ស ..................... ៤៦
៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ..................... ៤៨
៤- ការគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា ..................... ៤៨
**សន្និដ្ឋាន** ..................... ៥០
**ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារឆ្នាំ២០២២**
១- ការអនុវត្តនយោបាយរូបិយវត្ថុ ..................... ៥៣
២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ..................... ៥៣
៣- ការអភិវឌ្ឍប្រព័ន្ធទូទាត់ ..................... ៥៣
៤- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ..................... ៥៤
៥- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ..................... ៥៤
៦- ការងារប្រតិបត្តិការ ..................... ៥៥
៧- ការងារបោះផ្សាយនិងឃ្លាំងបេឡា ..................... ៥៥
៨- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ..................... ៥៥
៩- ការគ្រប់គ្រងសាខា ..................... ៥៦
១០- គណនេយ្យ ..................... ៥៦
១១- ការគ្រប់គ្រង និងបណ្តុះបណ្តាល ..................... ៥៦
១២- កិច្ចសហប្រតិបត្តិការអន្តរជាតិ ..................... ៥៧
១៣- ការស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច ..................... ៥៧
១៤- ការងារស្ថិតិ ..................... ៥៧

## ផ្នែកទី៣ - ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ ១ តារាង ១- ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវា ........................ ៥៨

ឧបសម្ព័ន្ធ ២ តារាង ២- ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រាទិញចុងខែ)....... ៥៩

ឧបសម្ព័ន្ធ ៣ តារាង ៣- ស្ថិតិស្ថានភាពធនាគារកណ្តាល ............................................... ៦០

ឧបសម្ព័ន្ធ ៤ តារាង ៤- ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត .................. ៦១

ឧបសម្ព័ន្ធ ៥ តារាង ៥- ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើ .................................. ៦២

ឧបសម្ព័ន្ធ ៦ តារាង ៦- ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ............................. ៦៣

ឧបសម្ព័ន្ធ ៧ តារាង ៧- ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុ.............................................. ៦៤

ឧបសម្ព័ន្ធ ៨ តារាង ៨- ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច .......................... ៦៥

ឧបសម្ព័ន្ធ ៩ តារាង ៩- សរុបប្រតិបត្តិការប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ ...................... ៦៦

ឧបសម្ព័ន្ធ ១០ តារាង ១០- ជញ្ជីងទូទាត់ប្រទេសកម្ពុជា .................................................. ៦៧

ឧបសម្ព័ន្ធ ១១ តារាង ១១- បណ្តាញព័ត៌មានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពីឆ្នាំ២០១៦ កញ្ញា ២០២១......................................................................... ៦៨

# អារម្ភកថា

នៅឆ្នាំ២០២១នេះ ពិភពលោកនៅបន្តប្រឈមនឹងវិបត្តិជំងឺកូវីដ-១៩ ប៉ុន្តែមានភាពប្រសើរជាងឆ្នាំមុន ដោយសារការចាក់វ៉ាក់សាំងនិងការពង្រឹងវិធានការការពារ។ ជាមួយនឹងលទ្ធភាពខ្ពស់ក្នុងការអនុវត្តគោលនយោបាយគាំទ្រ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍បានងើបឡើងវិញលឿន ហើយបានរួមចំណែកនាំឱ្យកំណើនសេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍កើនឡើងផងដែរ។ ដោយឡែក ប្រទេសក្នុងតំបន់អាស៊ានបាននិងកំពុងប្រឈមនឹងរលកនៃការឆ្លងជំងឺកូវីដ-១៩ ដែលធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចកើនឡើងយឺតជាងការរំពឹងទុក។

នៅកម្ពុជា រលកនៃការឆ្លងជំងឺកូវីដ-១៩ បានកើតឡើងកាលពីដើមឆ្នាំ ហើយបានបង្កផលប៉ះពាល់ដល់សន្ទុះងើបឡើងនៃកំណើនសេដ្ឋកិច្ច ដែលធ្វើឱ្យចំណូលក្រុមហ៊ុន-សហគ្រាសនិងប្រជាជនធ្លាក់ចុះ ជាមួយនឹងការបន្តថមថយលំហូរមូលធនបរទេស។ វិស័យទេសចរណ៍ទទួលរងផលប៉ះពាល់ខ្លាំងជាងគេ ចំណែកឯវិស័យសំណង់ សកម្មភាពសាងសង់នៅតែបន្តមាន ប៉ុន្តែគម្រោងសំណង់ថ្មីៗបានបន្តធ្លាក់ចុះ ស្របនឹងការថមថយនៃវិស័យអចលនទ្រព្យ។ វិស័យកាត់ដេរបានងើបឡើងដោយសារកំណើនតម្រូវការនាំចេញ បើទោះបីជារងការរំខានមួយចំនួនក៏ដោយ។ ជាមួយគ្នានេះ វិស័យកសិកម្មបានទទួលផលវិជ្ជមានពីកត្តាអាកាសធាតុនិងគោលនយោបាយគាំទ្រដែលធ្វើឱ្យផលិតកម្មកើនឡើង ទោះជាក្នុងល្បឿនយឺតក៏ដោយ។

ក្រោមការដឹកនាំប្រកបដោយទស្សនវិស័យវែងឆ្ងាយនិងគិតគូរហ្មត់ចត់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគាំទ្រជាបន្តបន្ទាប់និងអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងយ៉ាងឆាប់រហ័ស។ បច្ចុប្បន្ន កម្ពុជាស្ថិតក្នុងចំណោមប្រទេសមានអត្រាប្រជាពលរដ្ឋទទួលបានវ៉ាក់សាំងខ្ពស់ទាំងក្នុងតំបន់និងពិភពលោក។ វិធានការគាំទ្ររបស់រាជរដ្ឋាភិបាលត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងការជួយប្រជាជនក្រីក្រ និងក្រុមហ៊ុន-សហគ្រាសដែលរងផលប៉ះពាល់។ ស្របតាមនយោបាយរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តនយោបាយរូបិយវត្ថុវិត្ថារកម្ម និងការបន្ធូរបន្ថយបទប្បញ្ញត្តិមួយចំនួន ដោយថ្លឹងថ្លែងពីការរក្សាស្ថិរភាពថ្លៃ ស្ថិរភាពហិរញ្ញវត្ថុ និងការចូលរួមគាំទ្រសកម្មភាពសេដ្ឋកិច្ចនិងសម្រាលបន្ទុកប្រជាជនងាយរងគ្រោះ។

ទោះយ៉ាងណា ផលប៉ះពាល់នៃវិបត្តិនិងផលរំខាន (side-effects) ពីគោលនយោបាយមួយចំនួន បានបង្កផលវិបាកដល់ស្ថានភាពរូបិយវត្ថុនិងធនាគារផងដែរ។ ដោយសារតម្រូវការថយចុះក្រោមស្ថានភាពទន់ខ្សោយនៃសេដ្ឋកិច្ចក្នុងស្រុក ការបង្កើនចំណាយសាធារណៈ និងការរក្សាកម្រិតសន្ទនីយភាពខ្ពស់ក្នុងប្រព័ន្ធធនាគារ គួបផ្សំនឹងការថមថយនៃលំហូរមូលធនបរទេស តម្លៃប្រាក់រៀលបានបន្តរងសម្ពាធធ្លាក់ថ្លៃ ចាប់តាំងពីពេលដែលជំងឺកូវីដ-១៩ កើតមាននៅកម្ពុជានាដើមឆ្នាំ២០២០មក។ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍តាមស្ថានភាពចាំបាច់ ដើម្បីគ្រប់គ្រងសម្ពាធមកលើតម្លៃប្រាក់រៀល តាមរយៈការទិញប្រាក់រៀល (ឬលក់ប្រាក់ដុល្លារអាមេរិក) និងការបោះផ្សាយមូលបត្រ

អាចជួញដូរបាន (NCD) ជាមួយនឹងការបន្ថយល្បឿននៃការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ជាប្រាក់រៀល។ ការប្រើប្រាស់ឧបករណ៍នយោបាយរូបិយវត្ថុនិងអត្រាប្តូរប្រាក់សមស្រប ជាពិសេសមានសង្គតិភាពជាមួយនយោបាយសារពើពន្ធ បានរក្សាអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកឱ្យមានស្ថិរភាព ដោយប្រែប្រួលប្រមាណតែ ១% ប៉ុណ្ណោះ បើធៀបនឹងការប្រែប្រួលរូបិយប័ណ្ណក្នុងតំបន់ដែលមានរហូតដល់ ៥%។ ស្ថិរភាពអត្រាប្តូរប្រាក់បានរក្សាអំណាចទិញប្រាក់រៀល និងរួមចំណែកយ៉ាងសំខាន់ដល់ការរក្សាអត្រាអតិផរណាឱ្យនៅទាបអាចគ្រប់គ្រងបាន។ គួររំលេចថា ទោះបីជាទីផ្សារហិរញ្ញវត្ថុនិងសេដ្ឋកិច្ចពិភពលោកប្រឈមនឹងភាពមិនច្បាស់លាស់ក៏ដោយ ទុនបម្រុងអន្តរជាតិបានបន្តមានកម្រិតខ្ពស់គ្រប់គ្រាន់ ដែលបានពង្រឹងប្រសិទ្ធភាពនយោបាយអត្រាប្តូរប្រាក់ និងរក្សាជំនឿទុកចិត្តរបស់សាធារណជនមកលើការអនុវត្តនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា។

ការថយចុះចំណូលរបស់ក្រុមហ៊ុន-សហគ្រាសនិងប្រជាពលរដ្ឋ ដែលប៉ះពាល់ដល់លទ្ធភាពសងនិងខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គឺជាបញ្ហាប្រឈមដ៏ស្រួចស្រាល់មួយ។ ក្នុងស្ថានភាពនេះ អត្រាឥណទានមិនដំណើរការបានរងសម្ពាធកើនឡើង ហើយអាចបង្កជាហានិភ័យពាក់ព័ន្ធផ្សេងទៀត ដូចជាទៅលើលទ្ធភាពស្វែងរកប្រាក់ចំណេញជាដើម។ ដោយសារការពង្រឹងប្រព័ន្ធធនាគារក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ធនាគារជាតិនៃកម្ពុជាមានលទ្ធភាពបន្តអនុវត្តវិធានការគាំទ្របុរេសកម្ម ដើម្បីបង្កើនសន្ទនីយភាពទាំងប្រាក់រៀលនិងដុល្លារអាមេរិក និងបន្ធូរបន្ថយបទប្បញ្ញត្តិមួយចំនួន ដែលអនុញ្ញាតឱ្យប្រព័ន្ធធនាគាររក្សាបាននិរន្តរភាពនៃការផ្តល់ឥណទានគាំទ្រសកម្មភាពសេដ្ឋកិច្ច និងអាចផ្តល់ការអនុគ្រោះដល់ការរៀបចំឥណទានឡើងវិញប្រកបដោយពិលាស។ ការចូលរួមចំណែកយ៉ាងសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេសការគាំទ្ររបស់រាជរដ្ឋាភិបាល បានធ្វើឱ្យការអនុវត្តវិធានការទាំងនេះទទួលបានជោគជ័យខ្ពស់ និងបានចៀសវាងហានិភ័យចិត្តសាស្ត្រ (Moral Hazard)។ លើសពីនេះ វិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគតត្រូវបានពង្រឹង ដែលធានាបានស្ថិរភាពនិងការគ្រប់គ្រងបានទាន់ពេលវេលានូវហានិភ័យដែលអាចកើតឡើងជាយថាហេតុ។ គួររំលេចថា វិធានការពង្រឹងដើមទុនតាមរយៈការហាមឃាត់បណ្តោះអាសន្ននៃការបែងចែកភាគលាភ បានរួមចំណែកបង្កើនវិនិយោគផ្ទាល់បរទេសនៅក្នុងប្រព័ន្ធធនាគារផងដែរ ខណៈដែលលំហូរមូលធនបានថមថយ។

ធនាគារជាតិនៃកម្ពុជាបានចាប់យកឱកាសនៃការរីកចម្រើនបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយបានធ្វើទំនើបកម្មប្រព័ន្ធធនាគារ ជាពិសេសប្រព័ន្ធទូទាត់ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ២០១០មក។ អត្ថប្រយោជន៍នៃការអភិវឌ្ឍនេះ បានបង្ហាញកាន់តែជាក់ស្បាន់ នៅក្នុងអំឡុងពេលនៃការរាលដាលជំងឺកូវីដ-១៩ ដែលបានកាត់បន្ថយការទាក់ទងដោយផ្ទាល់។ ការទូទាត់តាមប្រព័ន្ធទំនើបពិតជាបានរួមចំណែករក្សានិរន្តរភាពនៃអាជីវកម្ម ពាណិជ្ជកម្ម ការវិនិយោគ និងការទូទាត់ទូទៅរបស់ប្រជាជន ដោយបានបន្ថយថ្លៃចំណាយប្រតិបត្តិការនិងបង្កើនល្បឿនទូទាត់ប្រកបដោយសុវត្ថិភាព។ យ៉ាងណាមិញ ប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់កន្លោងមួយ បានជួយសម្រួលដល់ការតភ្ជាប់ការទូទាត់របស់អតិថិជន

ពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយ ទៅគ្រឹះស្ថានមួយទៀតដោយងាយស្រួល ជាមួយនឹងកម្រៃសេវាសមរម្យ។ លើសពីនេះ ប្រព័ន្ធទូទាត់ទំនើបដែលកំពុងដំណើរការ ក៏បានបង្កើនការតភ្ជាប់ប្រព័ន្ធទូទាត់ថ្នាក់តំបន់ផងដែរ ដែលធ្វើឱ្យការបង្វែរប្រាក់រវាងកម្ពុជានិងតំបន់ប្រព្រឹត្តទៅដោយងាយស្រួល និងគាំទ្រដល់ការបង្វែរប្រាក់របស់ប្រជាពលករក្រៅប្រទេស ការដោះដូរ និងវិនិយោគឆ្លងដែន។

ជោគជ័យនៃការចាក់វ៉ាក់សាំង ការគ្រប់គ្រងបានលើការឆ្លងរាលដាល និងការអនុវត្តគោលនយោបាយនិងវិធានការគាំទ្រនានារបស់រាជរដ្ឋាភិបាលបានផ្តល់កាលានុវត្តភាពឱ្យសេដ្ឋកិច្ចកម្ពុជាងើបឡើងដោយភាពជឿជាក់នាឆ្នាំ២០២២ ខាងមុខ។ វិស័យសេដ្ឋកិច្ចចម្បងៗ ត្រូវបានរំពឹងថានឹងកើនឡើង បើទោះបីជាវិស័យទេសចរណ៍នៅទាមទារពេលវេលា ដើម្បីអាចត្រឡប់មករកកំណើនដូចមុនវិបត្តិក៏ដោយ។ ស្ថិរភាពថ្លៃនិងអត្រាប្តូរប្រាក់រំពឹងថានឹងរក្សាបាន ជាមួយភាពរឹងមាំនៃប្រព័ន្ធធនាគារ ដែលនឹងផ្តល់សហថាមភាពដល់កំណើនសេដ្ឋកិច្ច ប្រកបដោយនវានុវត្តន៍ បរិយាបន្ន និងចីរភាព។ ជាមួយគ្នានេះ សេដ្ឋកិច្ចកម្ពុជា ក៏អាចប្រឈមនឹងហានិភ័យមួយចំនួនផងដែរ ជាពិសេសប្រសិនបើមានរលកនៃជំងឺកូវីដ-១៩ ជាមួយនឹងមេរោគបំប្លែងថ្មី ការធ្វើប្រក្រតីកម្មលឿនជាងការរំពឹងទុកនៃនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍ដែលបង្កភាពមិនច្បាស់លាស់ក្នុងទីផ្សារហិរញ្ញវត្ថុ ឧក្រិដ្ឋកម្មសាយប័រ (Cybercrime) និងការប្រែប្រួលអាកាសធាតុ។

នៅចំពោះមុខសុទិដ្ឋិនិយមលើកំណើនសេដ្ឋកិច្ចពិភពលោកនិងកម្ពុជា រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយស្តារ កែទម្រង់ និងពង្រឹងភាពធន់នៃសេដ្ឋកិច្ច។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តវិធានការគាំទ្រដល់កំណើន និងបានរៀបចំយុទ្ធសាស្ត្រចាកចេញពីវិបត្តិ (Exit Strategy) ដែលនឹងត្រូវធ្វើឡើងតាមដំណាក់កាល ប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់និងស្របតាមការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចជាក់ស្តែង។ ដើម្បីរក្សាភាពធន់នៃប្រព័ន្ធធនាគារ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏ត្រូវបន្តពង្រឹងផែនការនិរន្តរភាពអាជីវកម្ម (Business Continuity Plan) និងផែនការអនុវត្តជាយថាហេតុ (Contingency Plan) ជាមួយនឹងការធ្វើស្ត្រេសតេស្តលើភាពរឹងមាំជាប្រចាំ។ ម៉្យាងទៀត ការបំពេញកាតព្វកិច្ចរួមចំណែកអនុវត្តវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មត្រូវបន្តលើកកម្ពស់ជាប្រចាំ ស្របតាមច្បាប់ បទប្បញ្ញត្តិ និងការណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនយោបាយរូបិយវត្ថុ ក្នុងបរិការណ៍ដុល្លារូបនីយកម្មខ្ពស់ ធនាគារជាតិនៃកម្ពុជាគាំទ្រនិងត្រៀមខ្លួនរួមចំណែកក្នុងដំណើរការបោះផ្សាយមូលបត្ររដ្ឋជាប្រាក់រៀល និងដាក់ចេញនូវវិធានការគាំទ្រការប្រើប្រាស់ប្រាក់រៀលបន្ថែមទៀត ស្របតាមយន្តការទីផ្សារ។ ទន្ទឹមនេះ ការជំរុញការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ការយល់ដឹងផ្នែកហិរញ្ញវត្ថុរបស់សាធារណជន និងកិច្ចការពារអតិថិជន នឹងត្រូវបន្តយកចិត្តទុកដាក់ជាប្រចាំ សំដៅអភិវឌ្ឍប្រព័ន្ធធនាគារប្រកបដោយចីរភាពនិងបរិយាបន្ន។

នៅក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិ ការពង្រឹងសមាហរណកម្ម បរិយាបន្ន និងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់ នឹងដើរតួនាទីកាន់តែសកម្មក្នុងការរក្សាភាពធន់នៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងនាមកម្ពុជាជាប្រធានអាស៊ាននៅឆ្នាំ២០២២ ធនាគារជាតិនៃកម្ពុជាបានត្រៀមខ្លួនធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធផ្សេងទៀត ឱ្យប្រព្រឹត្តទៅដោយជោគជ័យ ដោយបានដាក់ទិសដៅអាទិភាពក្នុងការពង្រឹងភាពធន់ ឌីជីថលូបនីយកម្ម បរិយាបន្ន និងហិរញ្ញប្បទានប្រកបដោយចីរភាព។

លទ្ធផលដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន កើតចេញពីការរួមចំណែកពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ហើយត្រូវបានទទួលស្គាល់ដោយមតិជាតិនិងអន្តរជាតិ។ នៅឆ្នាំ២០២១នេះ ខណៈពេលដែលសេដ្ឋកិច្ចពិភពលោកកំពុងប្រឈមនឹងការលំបាកនៃវិបត្តិ ធនាគារជាតិនៃកម្ពុជាត្រូវបានទទួលស្គាល់ថាជាស្ថាប័នដែលបំពេញមុខងារភារកិច្ចប្រកបដោយជោគជ័យនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាដែលតែងតែផ្តល់ការគាំទ្រ និងមន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ដែលបានខិតខំបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមគ្នាកសាងប្រព័ន្ធធនាគារឱ្យមានការអភិវឌ្ឍជឿនលឿន និងប្រកបដោយចីរភាព។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អនាពេលកន្លងមក។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ និងភាគីពាក់ព័ន្ធនានានឹងបន្តគាំទ្រ និងរួមចំណែកសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀតក្នុងប្រព័ន្ធធនាគារ ដែលនឹងបម្រើជាប្រយោជន៍រួមសម្រាប់ជាតិមាតុភូមិនិងប្រជាជនកម្ពុជា។

ទេសាភិបាល

ជា ចាន់តូ

# អក្សរកាត់

| | | |
|---|---|---|
| គ.ស.ហ. | គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និង ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហា-ប្រល័យ | National Coordination Committee on Anti-Money-Laundering and Combating the Financing of Terrorism and Financing of Proliferation of Weapons of Mass Destruction |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product (GDP) |
| ស.ហ.ក | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | Cambodia Financial Intelligence Unit (CAFIU) |
| អ.វ.ហ | អនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | National Risk Assessment Sub-Committee for Combating Money Laundering and Countering Financing Terrorism and Financing of Proliferation |
| ABIF | ក្របខ័ណ្ឌសមាហរណកម្មវិស័យធនាគារអាស៊ាន | ASEAN Banking Integration Framework |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank |
| AFI | សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ | Alliance for Financial Inclusion |
| APG | ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ | Asia/Pacific Group on Money Laundering |
| AMRO | អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ | The ASEAN+3 Macroeconomic Research Office |
| APRACA | សមាគមឥណទានកសិកម្ម និងជនបទសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក | Asia-Pacific Rural and Agricultural Credit Association |
| ATM | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ | Automated Teller Machine |
| BCP | ផែនការនិរន្តរភាពធុរកិច្ច | Business Continuity Plan |
| BIS | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ | Bank for International Settlements |
| CBS | មណ្ឌលសិក្សាបច្ចេកទេសធនាគារ | Center for Banking Studies |

| | | |
|---|---|---|
| CFtP | វិជ្ជាជីវៈផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ | Chartered Fintech Professional |
| CMIM | ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ | Chiang Mai Initiative Multilateralization |
| CSS | ប្រព័ន្ធខេមបូឌានស៊ែស្វីច | Cambodian Shared Switch |
| CUFA | សហព័ន្ធឥណទានមូលដ្ឋានអូស្ត្រាលី | Credit Union Foundation Australia |
| ECS | ប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក | Electronic Clearing System |
| EGMONT | ក្រុមអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ | Egmont Group of Financial Intelligence Units |
| ENEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចេញ | Export-weighted Nominal Effective Exchange Rate |
| EREER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ | Export-weighted Real Effective Exchange Rate |
| FATF | ក្រុមការងារហិរញ្ញវត្ថុ | Financial Action Task Force |
| FAST | ប្រព័ន្ធសេវាទូទាត់រហ័ស | Fast System |
| FCD | អនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណ | Foreign Currency Deposit |
| FICG | ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ | Financial Intelligence Consultative Group |
| FMIS | ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ | Financial Management Information System |
| FPP | កម្មវិធីនិងគោលនយោបាយហិរញ្ញវត្ថុ | Financial Programing and Policies |
| FSI Connect | កម្មវិធីសិក្សារបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុ | Financial Stability Institute Connect |
| IADI | សមាគមអន្តរជាតិសម្រាប់អង្គភាពការពារប្រាក់បញ្ញើ | International Association of Deposit Insurers |
| ICRG-JG | ក្រុមការងារត្រួតពិនិត្យរួមគ្នានៃប្រទេសអាស៊ី-ប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ | International Cooperation Review Group- Joint Group |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ | International Finance Corporation |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ | International Monetary Fund |
| INEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចូល | Import-weighted Nominal Effective Exchange Rate |

| | | |
|---|---|---|
| IREER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល | Import-weighted Real Effective Exchange Rate |
| LPCO | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា | Liquidity-Providing Collateralized Operation |
| MLF | ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី | Marginal Lending Facility |
| MPS | ប្រព័ន្ធទូទាត់ចល័ត | Mobile Payment System |
| MSDS | ប្រព័ន្ធទិន្នន័យសម្រាប់ការតាមដានម៉ាក្រូសេដ្ឋកិច្ច | Macroeconomic Surveillances Database System |
| NCD | មូលបត្រអាចជួញដូរបាន | Negotiable Certificate of Deposit |
| NCS | ប្រព័ន្ធផាត់ទាត់ជាតិ | National Clearing System |
| OBS | ប្រព័ន្ធធនាគារអនឡាញ | Online Banking System |
| POS | ប្រតិបត្តិការទិញទំនិញ | Point of Sale |
| QPS | ប្រព័ន្ធទូទាត់តាមរយៈ QR កូដ | QR Code Payment System |
| RFT | ប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ | Real Time Fund Transfer |
| RPPI | សន្ទស្សន៍ថ្លៃលំនៅឋាន | Residential Property Price Indices |
| SCCB | គណៈកម្មាធិការកសាងសមត្ថភាព | Steering Committee on Capacity Building |
| SEACEN | មជ្ឈមណ្ឌលស៊ាសិន | South East Asian Central Banks |
| UNCDF | មូលនិធិអភិវឌ្ឍន៍មូលធនរបស់អង្គការសហ-ប្រជាជាតិ | United Nations Capital Development Fund |
| UNDP | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ | United Nations Development Programme |
| UNESCAP | គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក | United Nations Economic and Social Commission for Asia and the Pacific |
| WB | ធនាគារពិភពលោក | World Bank |

| | | |
|---|---|---|
| WC-ABIF | គណៈកម្មាធិការក្របខ័ណ្ឌសមាហរណកម្មវិស័យធនាគារអាស៊ាន | Working Committee on ASEAN Banking Integration Framework |
| WC-CAL | គណៈកម្មាធិការសេរីភាវូបនីយកម្មគណនីមូលធន | Working Committee on Capital Account Liberation |
| WC-CMD | គណៈកម្មាធិការអភិវឌ្ឍទីផ្សារទុន | Working Committee on Capital Market Development |
| WC-FINC | គណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុ | Working Committee on Financial Inclusion |
| WC-FSL | គណៈកម្មាធិការសេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ | Working Committee on Financial Service Liberalization |
| WC-PSS | គណៈកម្មាធិការប្រព័ន្ធទូទាត់ | Working Committee on Payment and Settlement System |

## ខ្លឹមសារសង្ខេប

នៅឆ្នាំ២០២១ សេដ្ឋកិច្ចពិភពលោកបានងើបឡើងវិញក្នុងអត្រា ៥,៩% ដែលត្រូវបានគាំទ្រដោយនយោបាយសារពើពន្ធនិងរូបិយវត្ថុរិត្តារកម្ម និងការបន្ធូរបន្ថយវិធានការរឹតត្បិតលើការធ្វើដំណើរនិងអាជីវកម្ម។ ប៉ុន្តែ ភាពខុសគ្នានៃលំហនយោបាយសេដ្ឋកិច្ចនិងលទ្ធភាពទទួលបានវ៉ាក់សាំង បានធ្វើឱ្យការងើបឡើងវិញនៃសេដ្ឋកិច្ចតាមតំបន់នានាមានល្បឿនខុសគ្នា ដោយសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍កើនពី -៤,៥% ដល់ ៥,២% ខណៈដែលសេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ កើនពី -២,១% ដល់ ៦,៨%។ ដោយឡែក កំណើនសេដ្ឋកិច្ចក្នុងតំបន់អាស៊ាន-៥ អាចកើនត្រឹម ២,៩% ដោយសារការរាលដាលនៃជំងឺកូវីដ-១៩ ក្នុងតំបន់បានបង្អាក់សកម្មភាពសេដ្ឋកិច្ច ជាពិសេសវិស័យទេសចរណ៍។

ការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក ជាពិសេសប្រទេសអភិវឌ្ឍន៍ដែលជាដៃគូពាណិជ្ជកម្មសំខាន់របស់កម្ពុជា និងយុទ្ធនាការចាក់វ៉ាក់សាំងឆាប់រហ័សដែលបានបង្កើតភាពស៊ាំក្នុងសហគមន៍ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាអាចសម្រេចបានកំណើនវិជ្ជមានវិញក្នុងអត្រា ៣% ក្នុងឆ្នាំ២០២១ បន្ទាប់ពីបានធ្លាក់ចុះ -៣,១% កាលពីឆ្នាំកន្លងទៅ។ ផលិតផលកម្មន្តសាលសម្រាប់ឧស្សាហកម្មនាំចេញបានកើនឡើង ១២,៧% ស្របពេលដែលវិស័យសំណង់កើនឡើងបន្តិចក្នុងអត្រា ១,៤% ទន្ទឹមនឹងការងើបឡើងវិញនៃលំហូរទុនវិនិយោគបរទេសនិងតម្រូវការក្នុងស្រុក។ វិស័យកសិកម្មក៏បន្តមានវឌ្ឍនភាពល្អជាមួយអត្រាកំណើន ១,៤% ដោយសារវិធានការគាំទ្រផលិតកម្មកសិកម្មនិងអំណោយផលពីអាកាសធាតុ។ ចំណែកឯវិស័យទេសចរណ៍បន្តទទួលរងផលប៉ះពាល់ជាមួយការធ្លាក់ចុះភ្ញៀវទេសចរអន្តរជាតិ -៨៥% ស្របពេលដែលភ្ញៀវទេសចរក្នុងស្រុកបានធ្លាក់ចុះ -៣៥,៥%។ ចំពោះវិស័យខាងក្រៅ ជញ្ជីងទូទាត់កម្ពុជាបន្តមានអតិរេក ១៩៧ លានដុល្លារអាមេរិក ដោយសារកម្រិតខ្ពស់នៃលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុបានផាត់ទាត់នូវការកើនឡើងឱនភាពគណនីចរន្តនិងដើមទុន និងបានរួមចំណែករក្សាទុនបម្រុងអន្តរជាតិឱ្យបន្តស្ថិតក្នុងកម្រិតខ្ពស់ ២០,៥ ប៊ីលានដុល្លារអាមេរិក ដែលអាចធានាការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់បានប្រមាណ ៨ខែ។

អតិផរណាបន្តមានកម្រិតទាបក្នុងអត្រា ២,៩% ប្រហាក់ប្រហែលនឹងឆ្នាំ២០២០ (២,៩%) ស្របពេលដែលអត្រាប្តូរប្រាក់បន្តមានស្ថិរភាពក្នុងអត្រាមធ្យម ៤.០៩៩ រៀលក្នុងមួយដុល្លារអាមេរិក ដោយបានថយថ្លៃបន្តិចធៀបនឹងឆ្នាំមុន (៤.០៩៣ រៀល)។ ស្ថិរភាពថ្លៃនិងអត្រាប្តូរប្រាក់សម្រេចបានដោយសារការអនុវត្តនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ និងការគ្រប់គ្រងបាននូវសម្ពាធលើអត្រាប្តូរប្រាក់។ រូបិយវត្ថុទូទៅ (M2) បានកើនឡើង ១៤,៧% ទាបជាងកំណើនឆ្នាំមុន (១៥,៣%) និងស្ថិតក្នុងកម្រិតសមស្របនឹងតម្រូវការរូបិយវត្ថុក្នុងសេដ្ឋកិច្ច។ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍លក់ប្រាក់ដុល្លារអាមេរិកដល់គ្រឹះស្ថានហិរញ្ញវត្ថុនិងអាជីវករប្តូរប្រាក់ចំនួន ៥៩១,២ លានដុល្លារអាមេរិក ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់។ ទន្ទឹមនេះ ទំហំទឹកប្រាក់ដែលធនាគារជាតិនៃកម្ពុជាឱ្យខ្ចីដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ត្រូវបានកាត់បន្ថយជិត២ដងធៀបនឹងឆ្នាំកន្លងទៅ ដោយថ្លឹងថ្លែងពីសម្ពាធលើតម្លៃប្រាក់រៀល និងអត្រាការប្រាក់ឥណទានជាប្រាក់រៀល។ ការចេញផ្សាយមូលបត្រអាចជួញដូរបាន (NCD) ជារៀល

និងជាដុល្លារអាមេរិកមានចំនួន ១៨,១ ទ្រីលានរៀល (កើន ៦៦,៧%) និង ៣០,៣ ប៊ីលានដុល្លារអាមេរិក (កើនឡើង ២,៥%) រៀងគ្នា។ គួររំលេចថា ដុល្លារូបនីយកម្មបន្តមានកម្រិតខ្ពស់ ដោយអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ (FCD/M2) បន្តស្ថិតក្នុងកម្រិតខ្ពស់ ៨១,៩%។

ប្រព័ន្ធធនាគារបន្តមានភាពធន់ បើទោះជារងសម្ពាធនៃឥទ្ធិពលវិបត្តិជំងឺកូវីដ-១៩ ក៏ដោយ ហើយមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញតម្រូវការហិរញ្ញប្បទាន និងទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច។ ទ្រព្យសកម្មប្រព័ន្ធធនាគារបានកើនឡើង ១៦% ឥណទានអតិថិជនកើន ២១,២% ប្រាក់បញ្ញើអតិថិជនកើន ១៥,៤% និងដើមទុនកើន ១៨%។ ស្ថានភាពដើមទុនមានភាពរឹងមាំ ដោយអនុបាតសាធនភាពមានកម្រិត ២៣,៤% សម្រាប់វិស័យធនាគារ និង ២១,៣% សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ (ធៀបនឹងកម្រិតកំណត់ ១៥%) សន្ទនីយភាពមានកម្រិតខ្ពស់ ១៥៥,៩% សម្រាប់វិស័យធនាគារពាណិជ្ជ និង ១២៥% សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (ធៀបនឹងកម្រិតកំណត់ ១០០%) ហើយអនុបាតឥណទានមិនដំណើរការក្នុងវិស័យធនាគារនិងវិស័យមីក្រូហិរញ្ញវត្ថុ មានកម្រិតទាបប្រហាក់ប្រហែលគ្នាប្រមាណ ២,៤%។ ម៉្យាងទៀត ការរៀបចំឥណទានឡើងវិញរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានចំនួន ៣៧០.៧៨៥ គណនី ស្មើនឹង ២២,៤ ទ្រីលានរៀល (៥,៥ ប៊ីលានដុល្លារអាមេរិក) ដែលបានរួមចំណែកសម្រាលបន្ទុកប្រជាពលរដ្ឋនិងក្រុមហ៊ុន-សហគ្រាសដែលរងផលប៉ះពាល់។ បរិយាបន្នហិរញ្ញវត្ថុត្រូវបានលើកកម្ពស់ជាប្រចាំ ដោយចំនួនគណនីប្រាក់បញ្ញើអតិថិជនកើនដល់ ១២,១ លានគណនី និងគណនីឥណទានអតិថិជនកើនដល់ ៣,៣ លានគណនី ជាមួយនឹងការពង្រឹងការយល់ដឹងលើសេវាហិរញ្ញវត្ថុនិងកិច្ចការពារអតិថិជន។ ម៉្យាងទៀត ការរៀបចំប្រព័ន្ធការពារអ្នកដាក់ប្រាក់បញ្ញើនៅកម្ពុជាកំពុងត្រូវបានបន្តសិក្សា ដែលនឹងរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើស្ថិរភាពប្រព័ន្ធធនាគារបន្ថែមទៀត។

ក្នុងបរិកាណ៌នៃវិបត្តិជំងឺកូវីដ-១៩ ប្រព័ន្ធទូទាត់សងប្រាក់អេឡិចត្រូនិកបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកទ្រទ្រង់និរន្តរភាពនៃអាជីវកម្ម។ ការបន្តអភិវឌ្ឍនិងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ដូចជា ប្រព័ន្ធរីធែលផេ ប្រព័ន្ធបាគង ប្រព័ន្ធខេមបូឌានស៊ែស្វីច ប្រព័ន្ធសេវាទូទាត់រហ័ស ប្រព័ន្ធទូទាត់តម្លៃធំ និងការសម្រួលដល់ការផ្ទេរប្រាក់និងការទូទាត់ពាណិជ្ជកម្មឆ្លងដែន បានពង្រឹងការទូទាត់ឱ្យកាន់តែមានសុវត្ថិភាព ឆាប់រហ័ស និងតម្លៃសមរម្យ។ អតិថិជនចុះឈ្មោះប្រើប្រាស់កម្មវិធីបាគងមានចំនួនសរុប ២៥៤ ពាន់គណនី ជាមួយប្រតិបត្តិការធ្វើឡើងជាប្រាក់រៀលចំនួន ១,៧ ទ្រីលានរៀល និងជាប្រាក់ដុល្លារអាមេរិកចំនួន ១,៩ ប៊ីលានដុល្លារអាមេរិក។

ដោយឡែក ចំពោះការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) បានបន្តពង្រឹងការតាមដានការអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ ការវិភាគនិងការបញ្ជូនរបាយការណ៍ទៅអាជ្ញាធរអនុវត្តច្បាប់ ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ការចូលរួមនិងសម្របសម្រួលការអនុវត្តផែនការសកម្មភាពរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ការងាររបស់ក្រុមអ៊ិកម៉ុង (Egmont Group) និងការរៀបចំការវាយតម្លៃហានិភ័យថ្នាក់ជាតិ។

# ផ្នែកទី១- របាយការណ៍ប្រចាំឆ្នាំ២០២១

## I- ស្ថានភាពសេដ្ឋកិច្ចពិភពលោក

សេដ្ឋកិច្ចពិភពលោកបានងើបឡើងវិញបណ្តើរៗក្នុងល្បឿនខុសៗគ្នាទៅតាមប្រទេសនីមួយៗ ដែលគាំទ្រដោយនយោបាយសារពើពន្ធនិងរូបិយវត្ថុវិត្ថារកម្ម និងការចាប់ផ្តើមបើកប្រទេសឡើងវិញ ទោះបីជាមានភាពមិនច្បាស់លាស់ពីការវិវត្តនិងការរាលដាលនៃជំងឺកូវីដ-១៩ ក៏ដោយ។ យោងតាម ការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) សេដ្ឋកិច្ចពិភពលោកកើនពី -៣,១% នៅឆ្នាំ២០២០ ដល់ ៥,៩% ក្នុងឆ្នាំ២០២១ ក្នុងនោះសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍កើនពី -៤,៥% ដល់ ៥,២% ស្របពេលដែល សេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍កើនពី -២,១% ដល់ ៦,៤%។ ចំណែកឯ សេដ្ឋកិច្ច អាស៊ាន-៥[១] កើនពី -៣,៤% ដល់ ២,៩% ក្នុងឆ្នាំ២០២១ ដែលជាកំណើនទាបជាងការរំពឹងទុក ដោយសារ ការរាលដាលខ្លាំងនៃជំងឺកូវីដ-១៩ ក្នុងតំបន់។

ទំហំពាណិជ្ជកម្មពិភពលោកកើនពី -៨,២% នៅឆ្នាំ២០២០ ដល់ ៩,៧% នៅឆ្នាំ២០២១ ដោយសារ ការងើបឡើងវិញនៃតម្រូវការនិងសកម្មភាពសេដ្ឋកិច្ច ស្របពេលដែលការវិនិយោគផ្ទាល់ត្រូវបាន រំពឹងថាងើបឡើងវិញក្នុងរង្វង់ពី ១០% ដល់ ១៥%[២] ក្នុងឆ្នាំ២០២១ បន្ទាប់ពីបានធ្លាក់ដល់កម្រិតទាប បំផុតនៅក្នុងឆ្នាំ២០២០ កន្លងមក។

**ក្រាហ្វ ១៖ កំណើនសេដ្ឋកិច្ចពិភពលោក និងតំបន់**
(គិតជាភាគរយ, ឆ្នាំ២០២០ - ២០២២ព)




**ក្រាហ្វ ២ ៖ បម្រែបម្រួលការព្យាករកំណើនសេដ្ឋកិច្ច សម្រាប់ឆ្នាំ២០២១ របស់ IMF**
(គិតជាភាគរយ)




ប្រភព៖ IMF, ខែតុលា ឆ្នាំ២០២១, *ព=ព្យាករណ៍

ការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកបាននាំឱ្យតម្រូវការទីផ្សារវត្ថុធាតុដើមបានកើនឡើង ព្រមទាំងបានបង្កើនថ្លៃនៃក្រុមទំនិញទាំងនេះ ជាពិសេសប្រេងឥន្ធនៈចាប់តាំងពីត្រីមាសទី៣មក។ អតិផរណាពិភពលោកបានកើនឡើងពី ៣,២% នៅឆ្នាំ២០២០ ដល់ ៤,៣%[៣] នៅឆ្នាំ២០២១ ក្នុងនោះ ប្រទេសអភិវឌ្ឍន៍កើនពី ០,៧% ដល់ ២,៨% ស្របពេលដែលប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ កើនពី ៥,១% ដល់ ៥,៥%។ ទោះយ៉ាងណា ធនាគារកណ្តាលភាគច្រើននៅបន្តរក្សាអត្រាការប្រាក់

---

[១] រួមមាន៖ ប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាម
[២] របាយការណ៍វិនិយោគសកលចេញផ្សាយខែមិថុនា ឆ្នាំ២០២១របស់អង្គការ UNTAD។
[៣] របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក របស់ IMF ចេញផ្សាយខែតុលា ឆ្នាំ២០២១។

គោលនៅក្នុងកម្រិតទាប ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច។ នៅប្រទេសអភិវឌ្ឍន៍ ធនាគារកណ្តាលអាមេរិកបន្តរក្សាអត្រាការប្រាក់គោល ០,២៥% ស្របពេលដែលធនាគារកណ្តាលអឺរ៉ុប និងធនាគារកណ្តាលអង់គ្លេសបានសម្រេចរក្សាអត្រាការប្រាក់គោល 0% និង ០,១% រៀងគ្នា ហើយធនាគារកណ្តាលជប៉ុន បានសម្រេចបន្តរក្សាអត្រាការប្រាក់គោល -០,១%។ ចំណែកឯ ធនាគារកណ្តាលប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ភាគច្រើនបានបន្តរក្សាអត្រាការប្រាក់គោលក្នុងកម្រិតដដែល លើកលែងធនាគារកណ្តាលមួយចំនួនដូចជា ប្រេស៊ីល ហុងគ្រី ម៉ិកស៊ិក និងរុស្ស៊ី[៤] ដែលបានដំឡើងអត្រាការប្រាក់គោលចាប់ពីត្រីមាសទី៣ ក្នុងឆ្នាំ២០២០ ដោយសារការព្រួយបារម្ភចំពោះសម្ពាធអតិផរណា។

**ក្រាហ្វ ៣៖ អត្រាការប្រាក់គោលនៃប្រទេសកំពុងលូតលាស់ និងកំពុងអភិវឌ្ឍន៍**
(គិតជាភាគរយ, ខែមករា ឆ្នាំ២០១៨ - ខែតុលា ឆ្នាំ២០២១)




**ក្រាហ្វ ៤៖ អត្រាការប្រាក់គោលនៃប្រទេសអភិវឌ្ឍន៍**
(គិតជាភាគរយ, ខែមករា ឆ្នាំ២០១៨ - ខែតុលា ឆ្នាំ២០២១)




ប្រភព៖ Trading Economics

## II- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា

### ១- កំណើនសេដ្ឋកិច្ច

ក្នុងឆ្នាំ២០២១នេះ សេដ្ឋកិច្ចកម្ពុជាបន្តទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ជាពិសេសដោយសារការអូសបន្លាយនៃការឆ្លងក្នុងសហគមន៍ ២០ កុម្ភៈ។ ប៉ុន្តែបើធៀបនឹងឆ្នាំ២០២០កន្លងទៅ សកម្មភាពសេដ្ឋកិច្ចមានភាពប្រសើរជាង ជាពិសេស ចាប់ពីឆមាសទី២ ឆ្នាំ២០២១នេះមក ជាចម្បងគាំទ្រដោយការងើបមកវិញនៃកំណើនសេដ្ឋកិច្ចពិភពលោក ការសម្របខ្លួនទៅនឹងប្រក្រតីភាពថ្មី និងជោគជ័យនៃការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋរបស់រាជរដ្ឋាភិបាល។ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថាមានកំណើន ៣% ក្នុងឆ្នាំ២០២១។

---

[៤] យោងតាម Trading Economics ចាប់ពីត្រីមាសទី២ ឆ្នាំ២០២១ ធនាគារកណ្តាលប្រេស៊ីល បានដំឡើងការប្រាក់គោលពី ២% ដល់ ៦,២៥% ធនាគារកណ្តាលហុងគ្រីពី ០,៦% ដល់ ១,៨% ធនាគារកណ្តាលម៉ិកស៊ិកពី ៤% ដល់ ៤,៧៥% និងធនាគារកណ្តាលរុស្ស៊ីពី ៤,២៥% ដល់ ៧,៥% (ទិន្នន័យគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២២)។

**ក្រាហ្វ ៥ ៖ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ**
(ឆ្នាំ២០០៤ - ២០២២ព)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

## ក- វិស័យកម្មន្តសាល

កំណើនតម្រូវការពីខាងក្រៅបានធ្វើឱ្យស្ថានភាពផលិតកម្មក្នុងវិស័យកម្មន្តសាល មានភាពប្រសើរឡើងវិញ។ ផលិតផលកម្មន្តសាលសម្រាប់ឧស្សាហកម្មនាំចេញ (គិតជាតម្លៃ) កើនឡើង ១២,៧% ក្នុងនោះផលិតផលកាត់ដេរកើនឡើង ៩% ស្របពេលផលិតផលមិនមែនកាត់ដេរបានកើនឡើងខ្ពស់ ២១,៦%។ ដោយឡែក ផលិតផលសម្រាប់បម្រើទីផ្សារក្នុងស្រុកធ្លាក់ចុះ -២៣,៣%។ ចំនួនរោងចក្រសរុប[៩]បានថយចុះ ៤ រោងចក្រ (បើកថ្មី ១៤៤ រោងចក្រ និងបិទទ្វារ ១៤៨ រោងចក្រ) មកត្រឹម ១.៨៦០ រោងចក្រ ដែលរោងចក្របិទទ្វារភាគច្រើនជារោងចក្រកាត់ដេរ កាបូប និងស្បែកជើង ហើយបានធ្វើឱ្យចំនួនកម្មករក្នុងវិស័យនេះថយចុះប្រមាណ ២,៣ ម៉ឺននាក់។

**ក្រាហ្វ ៦ ៖ ផលិតផលសរុបសម្រេចបាន**
(ប៊ីលានដុល្លារអាមេរិក, ឆ្នាំ២០១៧ - ២០២១ប)




**ក្រាហ្វ ៧ ៖ ចំនួនរោងចក្រសរុប**
(ឆ្នាំ២០១៧ - ឆ្នាំ២០២១ប)




ប្រភព៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា,*សម្គាល់៖ ប=ប៉ាន់ស្មាន

[៩] រោងចក្រធុនធំស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

### ខ- វិស័យសំណង់និងអចលនទ្រព្យ

វិស័យសំណង់ត្រូវបានប៉ាន់ស្មានថាមានកំណើនប្រមាណ ១,៥% ដែលគាំទ្រដោយគម្រោងសំណង់កំពុងដំណើរការ ក៏ប៉ុន្តែ ចំនួន តម្លៃ និងផ្ទៃក្រឡាគម្រោងសំណង់ស្នើសុំថ្មីនៅបន្តធ្លាក់ចុះ -៧% -២៥,៩% និង -១៧,៦% រៀងគ្នា។ វិស័យអចលនទ្រព្យ ជាពិសេសខុនដូ ដែលកន្លងមកបម្រើឱ្យតម្រូវការអនិវាសជន នៅតែបន្តទទួលរងសម្ពាធ ប៉ុន្តែក្នុងកម្រិតទាប។ តម្លៃលក់ខុនដូប្រភេទប្រណិត មធ្យម និងសមរម្យត្រូវបានប៉ាន់ស្មានថាថយចុះ -១,៦%[៦] ស្របពេលដែលតម្លៃជួលក៏បានថយចុះផងដែរ។ ចំពោះតម្លៃជួលការិយាល័យទាំងក្នុងនិងក្រៅតំបន់ពាណិជ្ជកម្មពុំសូវមានភាពប្រែប្រួលខ្លាំងនោះទេ។ ដោយឡែក តម្លៃជួលហាងទំនិញក្នុងអគារពាណិជ្ជកម្មត្រូវបានប៉ាន់ស្មានថាធ្លាក់ចុះ -៦,១% ខណៈតម្លៃជួលសម្រាប់ផ្សារបែបសហគមន៍ ហាងលក់ទំនិញនៅតាមដងផ្លូវធំៗពុំសូវមានភាពប្រែប្រួលខ្លាំងទេ។ ទោះយ៉ាងណា វិស័យសំណង់និងអចលនទ្រព្យអាចងើបឡើងវិញឆាប់រហ័សដោយសារការកើនមកវិញនៃការវិនិយោគនាពេលខាងមុខ។

**ក្រាហ្វ ៨ ៖ កំណើនវិស័យសំណង់និងអចលនទ្រព្យ**
(ឆ្នាំ២០១៧ - ២០២១ប)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, *សម្គាល់៖ ប=ប៉ាន់ស្មាន

**ក្រាហ្វ ៩ ៖ ចំនួននិងតម្លៃគម្រោងសំណង់**
(ឆ្នាំ២០១៨ - ២០២១ប)




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

### គ- វិស័យទេសចរណ៍

វិស័យទេសចរណ៍នៅតែបន្តទទួលរងផលប៉ះពាល់ខ្លាំងពីការរាលដាលនៃជំងឺកូវីដ-១៩។ ភ្ញៀវទេសចរអន្តរជាតិចូលមកកម្ពុជាធ្លាក់ចុះក្នុងអត្រា -៨៥% (ត្រឹម ១៩៦.៤៩៥ នាក់) ធៀបនឹងឆ្នាំមុន (-៨០,២%)។ ភ្ញៀវទេសចរក្នុងស្រុកផ្អែកលើគោលដៅអាទិភាព[៧] មានចំនួន ៤,៧លាននាក់ (សមាមាត្រ ៩៤,៣% នៃភ្ញៀវទេសចរសរុប) ធ្លាក់ចុះ -៣៥,៥% ធៀបនឹងឆ្នាំមុន (-២៩,១%)។ ការធ្លាក់ចុះនៃចំនួនភ្ញៀវទេសចរបានជះឥទ្ធិពលបន្តដល់វិស័យជាច្រើនដែលពឹងផ្អែកលើភ្ញៀវទេសចរ ជាពិសេសវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន ដែលត្រូវបានប៉ាន់ស្មានថាធ្លាក់ចុះ -៣១,២%។ ការប្រកាសទទួលភ្ញៀវ

---

[៦] យោងតាម CBRE និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា
[៧] រួមមាន៖ រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ និងតំបន់អេកូទេសចរណ៍

ទេសចរវ៉ាក់សាំង និងការបើកប្រទេសឡើងវិញគ្រប់វិស័យនៅដើមខែវិច្ឆិកាបាននិងកំពុងរួមចំណែកក្នុងការគាំទ្រការងើបឡើងវិញនៃវិស័យទេសចរណ៍នៅកម្ពុជា។

**ក្រាហ្វ ១០ ៖ ភ្ញៀវទេសចរអន្តរជាតិ**
(ឆ្នាំ២០១៥ - ២០២១)




**ក្រាហ្វ ១១ ៖ ភ្ញៀវទេសចរក្នុងស្រុក**
(ឆ្នាំ២០១៩ - ២០២១)




ប្រភព៖ ក្រសួងទេសចរណ៍

### ឃ- វិស័យកសិកម្ម

វិស័យកសិកម្មបន្តមានវឌ្ឍនភាពល្អជាមួយនឹងអត្រាកំណើនប្រមាណ ១,៩% ដែលគាំទ្រដោយវិធានការជំរុញផលិតកម្មកសិកម្ម គួបផ្សំនឹងអំណោយផលពីកត្តាអាកាសធាតុ។ ផ្ទៃដីដាំដុះ និងបរិមាណផលស្រូវរដូវវស្សាមានកំណើន[៨] ៤% និង ១៨,៣% រៀងគ្នា។ ទិន្នផលកៅស៊ូត្រូវបានប៉ាន់ស្មានថា កើន ៨,៨% ដោយសារកំណើនតម្រូវការ សម្រាប់ផលិតកម្មក្រោយការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក ហើយតម្លៃកៅស៊ូជាមធ្យមក្នុងមួយតោនកើន ២៣,៥% (ដល់ ១.៦៧៦ ដុល្លារអាមេរិកដែលជាតម្លៃខ្ពស់ចាប់ពីឆ្នាំ២០១៧មក)។ ដោយឡែក ទិន្នផលវារីវប្បកម្ម ជាពិសេសការចិញ្ចឹមត្រីនិងបង្គា ត្រូវបានព្យាករថានឹងមានកំណើនអវិជ្ជមាន -៤១% ដែលបណ្ដាលមកពីការធ្លាក់ចុះនៃតម្រូវការទីផ្សារក្នុងស្រុកសម្រាប់បម្រើឱ្យវិស័យសេវាកម្ម គួបផ្សំនឹងការប្រកួតប្រជែងជាមួយការនាំចូលពីប្រទេសជិតខាងផងដែរ។

**ក្រាហ្វ ១២ ៖ ផ្ទៃដីដាំដុះ និងបរិមាណស្រូវរដូវវស្សា**
(គិតត្រឹម ១១ខែ ឆ្នាំ២០១៧ - ១១ខែ ឆ្នាំ២០២១)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

---

[៨] យោងតាមទិន្នន័យពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទិន្នន័យ គិតត្រឹម ១១ខែឆ្នាំ២០២១

ក្រាហ្វ ១៣ ៖ ទិន្នផលកៅស៊ូនិងតម្លៃកៅស៊ូជាមធ្យម

(ឆ្នាំ២០១៧ - ២០២១ប)




ក្រាហ្វ ១៤ ៖ ទិន្នផលវារីវប្បកម្ម

(ឆ្នាំ២០១៧ - ២០២១ប)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *សម្គាល់៖ ប=ប៉ាន់ស្មាន

## ២- ស្ថានភាពអតិផរណា

អតិផរណារួមបន្តមានស្ថិរភាព ក្នុងកម្រិតជាមធ្យម ២,៩% ប្រហាក់ប្រហែលនឹងឆ្នាំ២០២០ (២,៩%) ជាចម្បងដោយសារការថយល្បឿននៃកំណើនថ្លៃក្រុមម្ហូបអាហារ ខណៈដែលថ្លៃក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានងើបឡើងវិញ (ដោយប្តូរពីបរិត្តផរណាទៅអតិផរណា)។

អតិផរណាក្រុមម្ហូបអាហារបានថយល្បឿនមក ២,៧% (៤,៦% នៅឆ្នាំ២០២០) ដែលរួមចំណែកជាចម្បងដោយការបន្តថយចុះនៃតម្រូវការ ដោយសារការផ្អាកកម្មវិធីជួបជុំនានាក្នុងរយៈពេល ១០ខែដើមឆ្នាំ២០២១ ហើយកំណើនថ្លៃម្ហូបអាហារនៅប្រទេសដៃគូនាំចូលមានកម្រិតទាប។ អតិផរណាស្នូលបានថយល្បឿនបន្តិចមក ១,៦% (២,១% នៅឆ្នាំ២០២០) ជាចម្បងដោយសារតម្រូវការនៅបន្តមានភាពទន់ខ្សោយ។ អតិផរណាក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានកើនឡើងដល់ ៨,៦% (-៣,២% ឆ្នាំមុន) ស្របតាមនិន្នាការនៃការងើបឡើងវិញនៃថ្លៃប្រេងឆៅពិភពលោក នៅពេលតម្រូវការប្រេងនៅលើពិភពលោកមានការកើនឡើង។

ក្រាហ្វ ១៥ ៖ អតិផរណារួម និងការរួមចំណែកក្នុងអតិផរណារួម

(ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៩ - ខែធ្នូ ឆ្នាំ២០២១)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា (*ទិន្នន័យខែធ្នូ ឆ្នាំ២០២១ជាទិន្នន័យប៉ាន់ស្មាន)

ក្រាហ្វ ១៦ ៖ អតិផរណារួម និងអតិផរណាក្រុមធាតុចំបង

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៩ - ខែធ្នូ ឆ្នាំ២០២១)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា (*ទិន្នន័យខែធ្នូ ឆ្នាំ២០២១ជាទិន្នន័យប៉ាន់ស្មាន)

- **អតិផរណាព្យាករណ៍សម្រាប់ឆ្នាំ២០២២**

អតិផរណារួមសម្រាប់ឆ្នាំ២០២២ ត្រូវបានព្យាករថានឹងមានអត្រា ២,៦%[១០] ទាបជាងឆ្នាំ២០២១បន្តិច (២,៩%) ក្រោមការសន្មតថា៖ i/-កំណើនថ្លៃម្ហូបអាហារនឹងបន្តថយចុះ ដែលជំរុញជាចម្បងដោយភាពប្រសើរឡើងនៃការផ្គត់ផ្គង់ ii/-អតិផរណាស្នូលនឹងងើបឡើងវិញបន្តិច ដោយសារការកើនឡើងវិញនៃប្រាក់ចំណូល និង iii/-កំណើនថ្លៃទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈនឹងថមថយមកវិញស្របតាមនិន្នាការថ្លៃប្រេងនៅពិភពលោក ដោយសារការផ្គត់ផ្គង់ប្រេងនៅលើទីផ្សារអន្តរជាតិមានការកើនឡើង។

**ក្រាហ្វ ១៧ ៖ អតិផរណាព្យាករណ៍**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆ្នាំ២០១៩ - ឆ្នាំ២០២២)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## ៣- អត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបន្តមានស្ថិរភាព ដោយប្រែប្រួលទាបជាង ១% ប៉ុណ្ណោះ។ អត្រាប្តូរប្រាក់មានកម្រិតជាមធ្យម ៤.០៩៩ រៀលក្នុងមួយដុល្លារអាមេរិក ដោយប្រាក់រៀលបានថយថ្លៃបន្តិច ០,១% ធៀបនឹងឆ្នាំមុន (៤.០៩៣ រៀល)។ ប្រាក់រៀលបានទទួលរងសម្ពាធធ្លាក់ថ្លៃដោយសារ៖ i/-ភាពទន់ខ្សោយនៃសកម្មភាពសេដ្ឋកិច្ចដែលធ្វើឱ្យតម្រូវការប្រាក់រៀលថយចុះ ii/-កំណើនចំណាយរបស់រាជរដ្ឋាភិបាលតាមរយៈកញ្ចប់អន្តរាគមន៍ដែលបានកើនឡើងជិតទ្វេដងធៀបនឹងឆ្នាំមុន និង iii/-ការថយចុះនៃលំហូរវិនិយោគផ្ទាល់បរទេស ការកើនឡើងនៃឱនភាពជញ្ជីងពាណិជ្ជកម្ម និងការធ្លាក់ចុះភ្ញៀវទេសចរអន្តរជាតិ។

---

[៩] ការព្យាករត្រូវបានធ្វើឡើងដោយប្រើម៉ូឌែល៖ i/- Multiple regression ដែលសិក្សាពីទំនាក់ទំនងរវាងអតិផរណា និងសូចនាករសំខាន់មួយចំនួន រួមមាន អតិផរណានៅត្រីមាសមុន អតិផរណាដៃគូនាំចូល បម្រែបម្រួលថ្លៃប្រេងឥន្ធនៈពិភពលោក កំណើនឥណទាន និងបម្រែបម្រួលអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ii/- ARIMA (p,d,q) ដែលធ្វើការព្យាករក្រុមទាំង ១២ នៅក្នុងកន្ត្រកទំនិញប្រើប្រាស់ដោយផ្អែកលើតម្លៃគ្រាមុននិងគន្លងរបស់អថេរទាំងនោះ iii/- VARX ដែលមានអត្រាអតិផរណា កំណើនឥណទាន ការប្រែប្រួលអត្រាប្តូរប្រាក់ អតិផរណាដៃគូនាំចូល និងដាក់ថ្លៃប្រេងជា exogenous variables iv/- ARIMA (៣,១,៣) អត្រាអតិផរណាគ្រាមុនៗចំនួន ៣ ត្រីមាស និង v/- VARX ដែលព្យាករអតិផរណាស្នូល អតិផរណាក្រុមម្ហូបអាហារ និងអតិផរណាក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ។

[១០] ក្រោមការសន្មតថា i/-តម្លៃប្រេងនៅពិភពលោកនឹងថយចុះដល់ ៧២ ដុល្លារអាមេរិកក្នុងមួយបារ៉ែល ii/-អត្រាប្តូរប្រាក់ជាមធ្យមនឹងបន្តមានស្ថិរភាពក្នុងកម្រិត ៤.០៩០ iii/-ផ.ស.សនឹងមានកំណើន ៤,៨% នៅឆ្នាំ២០២២ ហើយនឹងបន្តងើបឡើងវិញបន្តិចម្តងៗឆ្ពោះទៅនិន្នាការរយៈពេលវែង និង iv/-និន្នាការអតិផរណានៃក្រុមទាំងបីនឹងវិវត្តតាមការរំពឹងទុកដូចបានរៀបរាប់ខាងលើ។

អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល (IREER) បានកើនឡើង ១% ដែលបង្ហាញពីសម្ពាធអតិផរណាពីការនាំចូលបន្តិច ដោយសារអត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចូល (INEER)[១១] បានកើនឡើង បើទោះជាអត្រាអតិផរណានៅប្រទេសដៃគូនាំចូលមានកម្រិតទាបជាងកម្ពុជាក៏ដោយ។ ការកើនឡើង INEER បណ្តាលមកពីរូបិយប័ណ្ណមួយចំនួន រួមមាន ប្រាក់យ៉ន់ចិន រ៉ូពីឥណ្ឌូណេស៊ី វូនកូរ៉េ រីងហ្គីតម៉ាឡេស៊ី ដុល្លារសិង្ហបុរី ដុល្លារតៃវ៉ាន់ និងដុងវៀតណាម បានឡើងថ្លៃធៀបនឹងប្រាក់រៀល។

អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ (EREER) កើនឡើង ១,៤% ដែលបណ្តាលមកពីការកើនឡើងអត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចេញ (ENEER)[១២] ១,៣% ខណៈអត្រាអតិផរណានៅប្រទេសដៃគូនាំចេញមានកម្រិតប្រហាក់ប្រហែលនឹងកម្ពុជា[១៣]។ ការកើនឡើង ENEER បណ្តាលមកពីរូបិយប័ណ្ណមួយចំនួនបានឡើងថ្លៃធៀបនឹងប្រាក់រៀលរួមមាន ដុល្លារអាមេរិក ផោនអង់គ្លេស អឺរ៉ូ ដុល្លារកាណាដា យ៉ន់ចិន និងដុងវៀតណាម ដែលការណ៍នេះបង្ហាញថាឧត្តមភាពប្រកួតប្រជែងលើការនាំចេញរបស់កម្ពុជាមានភាពប្រសើរជាងឆ្នាំមុន។

**ក្រាហ្វ ១៨៖ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក**
(គិតជារៀលក្នុងមួយដុល្លារអាមេរិក, មករា ឆ្នាំ២០១៨ - ធ្នូ ឆ្នាំ២០២១ប)




**ក្រាហ្វ ១៩ ៖ អត្រាប្តូរប្រាក់ប្រសិទ្ធភាព**
(សន្ទស្សន៍ ២០១៥=១០០, ឆ្នាំ២០១៥ - ២០២១ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

## ៤- ស្ថានភាពជញ្ជីងទូទាត់

ជញ្ជីងទូទាត់មានអតិរេក ០,៥% នៃផ.ស.ស. (១៤៧ លានដុល្លារអាមេរិក) ទាបជាងឆ្នាំមុន (២,៤% នៃផ.ស.ស.) ដែលបណ្តាលមកពីការកើនឡើងឱនភាពគណនីចរន្តនិងដើមទុន និងកំណើនទាបនៃលំហូរចូលគណនីហិរញ្ញវត្ថុ។

---

[១១] ប្រទេសដៃគូនាំចូលមកកម្ពុជាចម្បងៗរួមមាន៖ ចិន ថៃ វៀតណាម តៃវ៉ាន់ សិង្ហបុរី ជប៉ុន ហុងកុង កូរ៉េ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី និងសហរដ្ឋអាមេរិក។

[១២] ប្រទេសគោលដៅនាំចេញរបស់កម្ពុជាជាចម្បងៗរួមមាន៖ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អាល្លឺម៉ង់ ជប៉ុន កាណាដា ចិន ថៃ អេស្ប៉ាញ បែលហ្ស៊ិក បារាំង ហូឡង់ វៀតណាម ហុងកុង អ៊ីតាលី។

[១៣] ប្រទេសដៃគូនាំចេញរបស់កម្ពុជាទាំងអស់មានអត្រាអតិផរណាទាបជាងកម្ពុជា លើកលែងប្រទេសវៀតណាម។

**ក្រាហ្វ ២០ ៖ ជញ្ជីងទូទាត់កម្ពុជា**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១១ - ២០២១ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

## ក- គណនីចរន្ត និងដើមទុន

ឱនភាពគណនីចរន្តនិងដើមទុនបានកើនឡើង ៣៦,៩% នៃផ.ស.ស. (១០,៣ ប៊ីលានដុល្លារអាមេរិក) ធៀបនឹង ៧,២% នៃផ.ស.ស. ឆ្នាំមុន ដោយសារការកើនឡើងឱនភាពពាណិជ្ជកម្មទំនិញ ឱនភាពគណនីសេវាសុទ្ធ[១៤] ឱនភាពចំណូលបឋម[១៥] ការថយចុះអតិរេកគណនីចំណូលបន្ទាប់បន្សំ[១៦] និងការថយចុះលំហូរចូលគណនីដើមទុន[១៧]។

**ក្រាហ្វ ២១ ៖ គណនីចរន្ត និងដើមទុន**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១១ - ២០២១ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

[១៤] ឱនភាពគណនីសេវាសុទ្ធបានកើនឡើង ៩ដង (ឆ្នាំលើឆ្នាំ) ជាចម្បងដោយសារការថយចុះចំណូលពីសេវា ៦២% ក្នុងនោះចំណូលពីសេវាធ្វើដំណើរបានថយចុះ -៨៩% ដោយសារការថយចុះភ្ញៀវទេសចរ ៨៥%។

[១៥] ឱនភាពចំណូលបឋមបានកើនឡើង ៣១% ដោយសារការកើនឡើងការទូទាត់ទៅក្រៅប្រទេស ៥% ក្នុងនោះចំណាយការប្រាក់របស់រាជរដ្ឋាភិបាលកើនឡើង ២៩% និងការបែងចែកភាគលាភ និងប្រាក់ចំណេញពីការវិនិយោគផ្ទាល់ក្នុងស្រុកកើនឡើង ២% ខណៈដែលចំណូលពីទុនបម្រុងបរទេសបានថយចុះ -២៥%។

[១៦] អតិរេកគណនីចំណូលបន្ទាប់បន្សំបានថយចុះបន្តិច -0,៥% ជាចម្បងបណ្ដាលមកពីការថយចុះប្រាក់បង្វែររបស់ពលករពីក្រៅប្រទេស ៣% ខណៈដែលជំនួយរបស់រាជរដ្ឋាភិបាលបានកើនឡើង ៨%។

[១៧] គណនីដើមទុនមានលំហូរចូលសុទ្ធ ២៩៩ លានដុល្លារអាមេរិក បានថយចុះ -៦% ធៀបនឹងឆ្នាំមុន។

ឱនភាពពាណិជ្ជកម្មទំនិញបានកើនឡើង ៣៤% នៃផ.ស.ស. ធៀបនឹង ៩,៥% នៃផ.ស.ស. ឆ្នាំមុន ដោយសារការនាំចូលកើនឡើងលឿនជាងការនាំចេញ។ ការនាំចូលសរុបបានកើនឡើង ៣៨,៧% (ឆ្នាំមុន ៥,៣%) ជាចម្បងដោយសារការកើនឡើងការនាំចូលមាស (៣,៧ដង) វត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរ (២៣,១%) ប្រេងឥន្ធនៈ (៣២,២%) សម្ភារសំណង់ (២៩,៣%) ម្ហូបអាហារនិងភេសជ្ជៈ (១,១%) និងយានយន្ត (០,៤%)។ ការនាំចេញសរុបបានកើនឡើង ៦,៤% (ឆ្នាំមុន ២៣,៦%) ដែលគាំទ្រដោយការនាំចេញផលិតផលកាត់ដេរ[១៨] (១៣,៦%) គ្រឿងអេឡិចត្រូនិក (៦០,២%) កៅស៊ូ (៧២,២%) និងទោចក្រយាន (២៣,២%) ខណៈដែលការនាំចេញមាសនិងអង្ករថយចុះ (-៨៨,៣% និង -១២,៤% រៀងគ្នា)។

ក្រៅពីឱនភាពជញ្ជីងពាណិជ្ជកម្មទំនិញ ការកើនឡើងឱនភាពគណនីសេវាសុទ្ធ (៣,៧% នៃផ.ស.ស.) ឱនភាពគណនីចំណូលបឋម (១% នៃផ.ស.ស.) ការថយចុះអតិរេកគណនីចំណូលបន្ទាប់បន្សំ (-០,៣% នៃផ.ស.ស.) និងលំហូរចូលថយចុះគណនីដើមទុន (-០,១% នៃផ.ស.ស.) ក៏បានរួមចំណែកក្នុងការកើនឡើងឱនភាពគណនីចរន្តនិងដើមទុនផងដែរ។

## ខ- គណនីហិរញ្ញវត្ថុ[១៩]

សមតុល្យគណនីហិរញ្ញវត្ថុមានលំហូរចូលសមតុល្យទ្រព្យអកម្មបរទេសសុទ្ធ ១០,៣ ប៊ីលានដុល្លារអាមេរិក ដែលបានកើនឡើង ២,៤ដង ធៀបនឹងឆ្នាំមុន (៣ ប៊ីលានដុល្លារអាមេរិក)។ ការកើនឡើងនេះ បណ្ដាលមកពីគណនីវិនិយោគផ្សេងទៀតបានប្តូរពីសមតុល្យទ្រព្យសកម្មបរទេសសុទ្ធ ៣៨៥ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២០ មកជាសមតុល្យទ្រព្យអកម្មបរទេសសុទ្ធ ៦,៨ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១នេះ ខណៈដែលគណនីវិនិយោគផ្ទាល់សុទ្ធបានថយចុះបន្តិច។

**ក្រាហ្វ ២២ ៖ គណនីហិរញ្ញវត្ថុ**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១១ - ២០២១ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

[១៨] ក្នុងនោះការនាំចេញសម្លៀកបំពាក់ បានកើនឡើង ៧,២% ស្បែកជើង ១៧,១% និងផលិតផលកាត់ដេរផ្សេងទៀត ៤៦,៦%។
[១៩] ទ្រព្យសកម្មបរទេសសុទ្ធមានន័យថា មានលំហូរចេញសុទ្ធ។ មានទ្រព្យអកម្មបរទេសសុទ្ធមានន័យថា មានលំហូរចូលសុទ្ធ។

វិនិយោគផ្ទាល់បរទេសសុទ្ធមានទ្រព្យអកម្មបរទេសសុទ្ធ ៣,៥ ប៊ីលានដុល្លារអាមេរិក (១២% នៃ ផ.ស.ស.) ទាបជាងឆ្នាំមុន (១,៥%) ដែលបណ្តាលមកពីការថយចុះវិនិយោគលើវិស័យធនាគារ (-៥,៣%) ខណៈដែលវិស័យមិនមែនធនាគារបានកើនឡើង ១,៦% ក្នុងនោះរួមមាន៖ វិស័យកម្មន្តសាល[២០] ៩% និងវិស័យសំណង់ ២៦% ប៉ុន្តែវិស័យសំខាន់ៗមួយចំនួនទៀតបានថយចុះ ដូចជាវិស័យសណ្ឋាគារ និងការកម្សាន្ត -២៥% អចលនទ្រព្យ -១១% និងកសិកម្ម -១៩%។

វិនិយោគផ្សេងទៀតមានទ្រព្យអកម្មបរទេសសុទ្ធ ៦,៨ ប៊ីលានដុល្លារអាមេរិក ដែលបានប្តូរពីទ្រព្យសកម្មបរទេសសុទ្ធ ៣៨៥ លានដុល្លារអាមេរិកនៅឆ្នាំមុន ដោយសារការកើនឡើងទ្រព្យអកម្មបរទេសរបស់វិស័យធនាគារ ១,៦ ប៊ីលានដុល្លារអាមេរិក (៣,៨ដង) ការខ្ចីរបស់រាជរដ្ឋាភិបាលសុទ្ធ ២៣៦ លានដុល្លារអាមេរិក (២៩%) និងខ្ចង់វិនិយោគផ្សេងៗ ៥,៤ ប៊ីលានដុល្លារអាមេរិក (៣,៣ដង)។

## ៥- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

ទុនបម្រុងអន្តរជាតិមានចំនួន ២០,៥ ប៊ីលានដុល្លារអាមេរិក ដែលអាចធានាការនាំចូលទំនិញ និងសេវាសម្រាប់គ្រាបន្ទាប់បាន ៨ ខែ ដែលជាកម្រិតខ្ពស់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (កម្រិតគួរមានត្រឹម ៣ ខែ)។

**ក្រាហ្វ ២៣ ៖ ទុនបម្រុងអន្តរជាតិ និងចំនួនខែនៃការនាំចូលទំនិញនិងសេវាគ្រាបន្ទាប់**
(ឆ្នាំ២០១១ - ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទីផ្សារហិរញ្ញវត្ថុសកលមានការប្រែប្រួលខ្លាំងនៅឆ្នាំ២០២១ ដោយសារការបន្តអនុវត្តគោលនយោបាយរូបិយវត្ថុរិត្តារកម្មរបស់ធនាគារកណ្តាល និងវិធានការបិទប្រទេសជាបន្តបន្ទាប់របស់ប្រទេសអភិវឌ្ឍន៍ធំៗ ដើម្បីឆ្លើយតបទៅនឹងឥទ្ធិពលនៃការរាលដាលនៃជំងឺកូវីដ-១៩។ វិធានការ

---

[២០] ការកើនឡើងនេះដោយសារតែការវិនិយោគក្នុងវិស័យកម្មន្តសាលផ្សេងៗបានកើនឡើង ៣ដង ខណៈដែលការវិនិយោគក្នុងវិស័យសំខាន់ៗបានថយចុះ ដូចជា វិស័យកាត់ដេរសម្លៀកបំពាក់ -៩% ស្បែកជើង -១៥% និងកាបូប -៥%។

ទាំងនេះ បាននាំឱ្យអត្រាការប្រាក់នៅលើទីផ្សារបន្តមានកម្រិតទាប និងអវិជ្ជមានខុសពីការរំពឹងទុករបស់ទីផ្សារកន្លងមក ដែលថាអត្រាការប្រាក់នៅលើទីផ្សារនឹងត្រឡប់មករកប្រក្រតីភាពវិញនៅឆ្នាំ២០២១នេះ។ ស្ថានភាពអត្រាចំណូលទាប និងហានិភ័យឥណទានកើនឡើងគឺជាបញ្ហាប្រឈមចម្បងក្នុងការគ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីសម្រេចបាននូវគោលដៅលំដាប់អាទិភាព តាមរយៈការរក្សាបាននូវការគរពូនទុនបម្រុងអន្តរជាតិមានសន្ទនីយភាពគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការបានទាន់ពេលវេលា និងទទួលបានចំណូលសមស្របតាមផែនការ។

ដើម្បីធានាបានការវិនិយោគទុនបម្រុងអន្តរជាតិប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់ ការវិនិយោគត្រូវបានអនុវត្តដោយមានភាពបត់បែន ហានិភ័យនៃការវិនិយោគត្រូវបានគ្រប់គ្រង និងតាមដានយ៉ាងហ្មត់ចត់ ព្រមទាំងធានាថាការវិនិយោគត្រូវស្ថិតនៅក្នុងដែនកម្រិតហានិភ័យដែលកំណត់នៅក្នុងសេចក្តីណែនាំការវិនិយោគរបស់ធនាគារជាតិនៃកម្ពុជា។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបាន និងកំពុងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអនុវត្តតាមគោលនយោបាយវិនិយោគប្រកបដោយការទទួលខុសត្រូវទៅលើបរិស្ថាន សង្គម និងអភិបាលកិច្ចល្អ ក្នុងគោលដៅពង្រឹងចីរភាព សុវត្ថិភាពការវិនិយោគទុនបម្រុង និងស្របតាមនិន្នាការនៃការវិនិយោគសកល។

## III- ការគ្រប់គ្រងរូបិយវត្ថុ

### ១- ស្ថានភាពរូបិយវត្ថុ

រូបិយវត្ថុទូទៅ (M2) បានកើនឡើង ១៤,៧% (ដល់ ១៥៦,៦ ទ្រីលានរៀល) ស្មើនឹង ១៣៥,៩% នៃផ.ស.ស. ទាបជាងកំណើនឆ្នាំមុនបន្តិច (១៥,៣%) និងមធ្យមរយៈពេល៥ឆ្នាំចុងក្រោយ (២១%)។ កំណើនរូបិយវត្ថុទូទៅត្រូវបានគាំទ្រដោយកំណើនប្រាក់បញ្ញើសរុបរបស់និវាសជន (ទាំងជាប្រាក់ដុល្លារអាមេរិកនិងប្រាក់រៀល) ក្នុងអត្រា ១៤,៨% (ធៀបនឹងកំណើនឆ្នាំមុន ១៥,៥%) និងកំណើនរូបិយវត្ថុក្នុងចរាចរណ៍[២១]ក្នុងអត្រា ១៣,៦% (ប្រហាក់ប្រហែលនឹងឆ្នាំមុន ១៣,២%)។

បើទោះបីជាស្ថិតក្នុងកម្រិតខ្ពស់ ដុល្លាវូបនីយកម្មបានថយចុះបន្តិច ដោយអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ (FCD/M2) មានកម្រិត ៨១,៩% (ឆ្នាំមុន ៨៣,៩%)។ ប្រាក់រៀលក្នុងចរាចរណ៍មានសមាមាត្រ ៩,៨% (៣,៨ ប៊ីលានដុល្លារអាមេរិក) នៃរូបិយវត្ថុទូទៅ ប្រាក់បញ្ញើជារៀលមានសមាមាត្រ ៩,២% នៃប្រាក់បញ្ញើសរុប ហើយឥណទានជារៀលមានសមាមាត្រ ១១,២% នៃសំពៀតឥណទានសរុប។

[២១] ស្មើនឹងរូបិយវត្ថុដែលធនាគារកណ្តាលបោះផ្សាយ ដកនឹងរូបិយវត្ថុក្នុងបេឡានៃបណ្តាធនាគារទទួលប្រាក់បញ្ញើរួមមាន ធនាគារកណ្តាល ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

ក្រាហ្វ ២៤ ៖ សមាសធាតុ និងកំណើនរូបិយវត្ថុទូទៅ
(ឆ្នាំ២០១០ - ២០២១ប)




ក្រាហ្វ ២៥ ៖ ប្រាក់បញ្ញើជារៀល និងរូបិយវត្ថុក្នុងចរាចរណ៍
(ឆ្នាំ២០១០ - ២០២១ប)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=បឋាន់ស្មាន

## ២- ការអនុវត្តនយោបាយរូបិយវត្ថុ

### ក- ការធ្វើអន្តរាគមន៍ទីផ្សារប្តូរប្រាក់

ក្នុងគោលដៅរក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀល ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ ដោយបានលក់ប្រាក់ដុល្លារអាមេរិកសុទ្ធ[២២] ៥៥៤,២ លានដុល្លារអាមេរិក ក្នុងនោះការទិញមាន ៣៧ លានដុល្លារអាមេរិក និងលក់ ៥៩១,២ លានដុល្លារអាមេរិក ធៀបនឹងការលក់សុទ្ធ ៦៣,២ លានដុល្លារអាមេរិកកាលឆ្នាំមុន (ទិញ ១៧ លានដុល្លារអាមេរិក)។ ការអន្តរាគមន៍នេះត្រូវបានធ្វើឡើងតាមរយៈការប្រកាសដេញថ្លៃចំនួន ៤៦០ លានដុល្លារអាមេរិក និងផ្លែតហ្វមធនាគារជាតិនៃកម្ពុជា (NBCP) ចំនួន ១៣១,២ លានដុល្លារអាមេរិក។ ចំណែកការទិញ-លក់ជាមួយស្ថាប័នវេរិញ ការទិញប្រាក់ដុល្លារអាមេរិកសុទ្ធមានចំនួន ៤៨,២ លានដុល្លារអាមេរិក (លក់មាន ៧,១ លានដុល្លារអាមេរិក និងទិញមាន ៥៥,៣ លានដុល្លារអាមេរិក) ខណៈឆ្នាំមុនមានការលក់ប្រាក់ដុល្លារអាមេរិកសុទ្ធប្រមាណ ១៤៧,១ លានដុល្លារអាមេរិក។

[២២] លក់សុទ្ធ = លក់-ទិញ

**ក្រាហ្វ ២៦ ៖ អន្តរាគមន៍ទិញ-លក់ប្រាក់ដុល្លារអាមេរិក**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៨ - ២០២១)




**ក្រាហ្វ ២៧ ៖ ការទិញលក់ប្រាក់ដុល្លារអាមេរិកជាមួយស្ថាប័នរដ្ឋ**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៨ - ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ- អត្រាប្រាក់បម្រុងកាតព្វកិច្ច

អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានរក្សានៅត្រឹម ៧% ទាំងប្រាក់បញ្ញើជារៀល និងរូបិយប័ណ្ណ និងការខ្ចីអនិវាសជន ចាប់តាំងពីចុងត្រីមាសទី១ ឆ្នាំ២០២០ (ថយចុះពី ៨% និង ១២,៥% រៀងគ្នា) ដើម្បីបន្តគាំទ្រដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យមានសន្ទនីយភាពបន្ថែម។ កម្រិតទាបនៃអត្រាប្រាក់បម្រុងកាតព្វកិច្ចនេះ បានផ្តល់ភាពអំណោយផលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការពង្រឹងការគ្រប់គ្រងហានិភ័យសន្ទនីយភាព ផ្តល់លទ្ធភាពបង្កើនឥណទាន និងផ្តល់ការអនុគ្រោះនានាដល់អតិថិជនដែលទទួលរងផលប៉ះពាល់ពីឥទ្ធិពលនៃជំងឺកូវីដ-១៩។

**ក្រាហ្វ ២៨ ៖ ទំហំនិងអត្រាប្រាក់បម្រុងកាតព្វកិច្ច**
(ឆ្នាំ១៩៩៣ - ឆ្នាំ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### គ- ការចេញផ្សាយមូលបត្រអាចជួញដូរបាន (NCD)

មូលបត្រអាចជួញដូរបាន បានបំពេញតួនាទីជាឧបករណ៍ស្រូបយកសន្ទនីយភាពលើសពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងផ្តល់ជាវត្ថុធានាសម្រាប់ប្រតិបត្តិការអន្តរធនាគារ។ NCD ដែលបានចេញផ្សាយសរុបមាន ៣៦ ប៊ីលានដុល្លារអាមេរិក ដោយបានកើនឡើង ៧,៧% ធៀបនឹងឆ្នាំមុន ក្នុងនោះ NCD ចារឹកជាប្រាក់ដុល្លារអាមេរិកមានប្រមាណ ៣០,៣ ប៊ីលានដុល្លារអាមេរិក ដែលកើនឡើង ២,៥% និងការចេញផ្សាយ NCD ចារឹកជាប្រាក់រៀលមាន ១៨,១ ទ្រីលានរៀល ដែលបានកើនឡើង ៦៦,៧%។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ និងបន្តអភិវឌ្ឍ NCD ឱ្យក្លាយជាឧបករណ៍គ្រប់គ្រងសន្ទនីយភាពកាន់តែមានប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបានសម្រេចបន្ថយគម្លាតនៃអត្រាទិញ-លក់ NCD ចារឹកជាប្រាក់រៀល ដែលមានឥណប្រតិទានខ្លីៗបន្ថែមទៀត។

**ក្រាហ្វ ២៩ ៖ អត្រាការប្រាក់ NCD ជាប្រាក់រៀល និងដុល្លារអាមេរិក**
(គិតជាភាគរយ, ជាមធ្យមប្រចាំថ្ងៃ, ឆ្នាំ២០២១)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

**ក្រាហ្វ ៣០ ៖ ចំនួន និងទំហំទឹកប្រាក់ NCD ជាដុល្លារអាមេរិក ដែលបានចេញផ្សាយ និងមិនទាន់ដល់ឥណប្រតិទាន**
(ឆ្នាំ២០១៣ - ២០២១)




**ក្រាហ្វ ៣១ ៖ ចំនួន និងទំហំទឹកប្រាក់ NCD ជារៀល ដែលបានចេញផ្សាយ និងមិនទាន់ដល់ឥណប្រតិទាន**
(ឆ្នាំ២០១៤ - ២០២១)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### ឃ- ប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា (LPCO)

ទន្ទឹមនឹងការស្រុបសន្ទនីយភាពពីប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាក៏បានបញ្ចេញសន្ទនីយភាពជាប្រាក់រៀលតាមរយៈប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា។ LPCO ត្រូវបានធ្វើឡើងពីរដងក្នុងមួយខែ ដែលបានផ្ដល់សន្ទនីយភាពសរុបក្នុងឆ្នាំ២០២១នេះចំនួន ៤,៣ ទ្រីលានរៀល ដែលថយចុះជិត ២ដង ធៀបនឹងឆ្នាំមុនជាមួយនឹងអត្រាការប្រាក់ដេញថ្លៃឈ្នះជាមធ្យមគឺ ៤,៤៨% (៣,៤៦% នៅឆ្នាំ២០២០)។ ឥណប្រតិទាន៩១ថ្ងៃមានចំនួន ១,២ ទ្រីលានរៀល ក្នុងអត្រា ៤,១៥% (៣,១០% នៅឆ្នាំមុន) ឥណប្រតិទាន១៨២ថ្ងៃមានចំនួន ១,៥ ទ្រីលានរៀល ក្នុងអត្រា ៤,៣៧% (៣,៤៧% នៅឆ្នាំមុន) និងឥណប្រតិទាន ៣៦៤ថ្ងៃមានចំនួន ១,៦ ទ្រីលានរៀល ក្នុងអត្រា ៤,៩០% (៣,៧៨% នៅឆ្នាំមុន)។ ទំហំទឹកប្រាក់ប្រតិបត្តិការ LPCO ដែលមិនទាន់ដល់ឥណប្រតិទានមានចំនួន ២ ទ្រីលានរៀល ថយចុះ -៤៧,៧%។

**ក្រាហ្វ ៣២ ៖ ការផ្ដល់សន្ទនីយភាពជារៀលតាមរយៈ ប្រតិបត្តិការ LPCO ប្រចាំខែ**
(គិតជាប៊ីលានរៀល, ឆ្នាំ២០២១)




**ក្រាហ្វ ៣៣ ៖ ការផ្ដល់សន្ទនីយភាពជារៀលតាមរយៈ ប្រតិបត្តិការ LPCO ប្រចាំឆ្នាំ**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៧ - ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ង- ប្រតិបត្តិការផ្ដល់សន្ទនីយភាពរយៈពេលខ្លី (MLF)

ឧបករណ៍ផ្ដល់សន្ទនីយភាពរយៈពេលខ្លីគឺជាឧបករណ៍នយោបាយរូបិយវត្ថុថ្មីមួយ ដែលទើបដាក់ឱ្យប្រើប្រាស់នៅចុងត្រីមាសទី៣ ឆ្នាំ២០២១។ MLF ត្រូវបានរំពឹងថានឹងជួយបំពេញតម្រូវការសន្ទនីយភាពជាប្រាក់រៀលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានតម្រូវការសម្រាប់រយៈពេលមួយថ្ងៃ និងអាចបន្តបានរយៈពេលប្រាំថ្ងៃក្នុងអត្រាការប្រាក់ ៤% ក្នុងមួយឆ្នាំដោយមានវត្ថុធានាជា NCD ក្នុងនោះ NCD ជាប្រាក់ដុល្លារអាមេរិកមានអត្រា Haircut ២%។ MLF ត្រូវបានចាត់ទុកជាប្រភពសន្ទនីយភាពជាប្រាក់រៀល ដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចទទួលបានភ្លាមៗនិងអាចដើរតួនាទីយ៉ាងសកម្មក្នុងការកំណត់អត្រាការប្រាក់ឥណទានក្នុងទីផ្សារអន្តរធនាគារនាពេលអនាគត។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា សម្រាប់ការប្រើប្រាស់ MLF មាន ២២[២៣]។

[២៣] ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ, ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក, វឌ្ឍនៈអាស៊ី ចំកាត់, មេយប៊ែង (ខេមបូឌា) ភីអិលស៊ី, អេស៊ីលីដា ភីអិលស៊ី, ស៊ិនហាន (ខេមបូឌា) ម.ក, វីង (ខេមបូឌា) ម.ក, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី, ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក, ហ្វីលីព ភីអិលស៊ី, អាយ ស៊ី ប៊ី ស៊ី លីមីតធីត សាខាភ្នំពេញ, គូកមីន កម្ពុជា ភីអិលស៊ី, វឌ្ឍនៈ, តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ, ព្រីនស៍ ម.ក, ពាណិជ្ជទីមួយ សាខាភ្នំពេញ, ប្រេដ ប៊ែង (ខេមបូឌា) ម.ក, ស្ថាបនា ភីអិលស៊ី, ស៊ីអាយអិមប៊ី ភីអិលស៊ី, ពាណិជ្ជកម្មក្រៅប្រទេស, កម្ពុជាពាណិជ្ជ ម.ក, និងមេហ្គា អ៊ិនធើណេសិនណល ខមមើសសល ប៊ែង ខូអិលធីឌី សាខាភ្នំពេញ

## IV- ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា

### ១- ស្ថានភាពទូទៅ

ប្រព័ន្ធធនាគារកម្ពុជាមានធនាគារពាណិជ្ជ ៥៤ ធនាគារឯកទេស ១០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៧៩ គ្រឹះស្ថានឥណទានជនបទ ២៣៤ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៧ អ្នកដំណើរការតតិយភាគី ៤ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ២៨ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ១ ការិយាល័យតំណាងធនាគារបរទេស ៦ និងអាជីវកម្មប្តូរប្រាក់ ២.៤៤៧។

**ក្រាហ្វ ៣៤ ៖ ប្រព័ន្ធធនាគារកម្ពុជា**

(គិតជាចំនួនគ្រឹះស្ថាន, ឆ្នាំ២០២០ - ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារមានកំណើន ១៦% (ដល់ ២៧៨,៦ ទ្រីលានរៀល ស្មើនឹង ៦៨,២ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះឥណទានអតិថិជនកើន ២១,២% (ដល់ ១៨៦,៤ ទ្រីលានរៀល ស្មើនឹង ៤៥,៧ ប៊ីលានដុល្លារអាមេរិក)។ ប្រាក់បញ្ញើអតិថិជនមានកំណើន ១៥,៤% (ដល់ ១៥៧,១ ទ្រីលានរៀល ស្មើនឹង ៣៨,៥ ប៊ីលានដុល្លារអាមេរិក) និងដើមទុនមានកំណើន ១៨% (ដល់ ៣១,២ ទ្រីលានរៀល ស្មើនឹង ៧,៦ ប៊ីលានដុល្លារអាមេរិក)។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃចំនួនគណនីប្រាក់បញ្ញើអតិថិជន ដល់ ១២,១ លានគណនី និងគណនីឥណទានអតិថិជនដល់ ៣,៣ លានគណនី។ ទីស្នាក់ការកណ្តាលនិងសាខាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានចំនួន ២.៦០០ ទីតាំង និងមានម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ចំនួន ៣.៥១២។ លើសពីនេះ ដើម្បីរួមចំណែកជួយសម្រាលបន្ទុកប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានផ្តល់ការអនុគ្រោះដល់អ្នកខ្ចីប្រាក់ តាមរយៈការរៀបចំឥណទានឡើងវិញចំនួន ៣៧០.៧៨៥ គណនី ស្មើនឹង ២២,៤ ទ្រីលានរៀល (៥,៥ ប៊ីលានដុល្លារអាមេរិក)។

**ក្រាហ្វ ៣៥ ៖ សមាមាត្រទ្រព្យសកម្ម**

(ឆ្នាំ២០១៧ - ២០២១ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

ប្រព័ន្ធធនាគារមានភាពធន់នឹងវិបត្តិ ដែលឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗ រួមមាន៖ i/-ភាពរឹងមាំនៃដើមទុន ដោយអនុបាតសាធនភាពមានកម្រិត ២៣,៤% សម្រាប់វិស័យធនាគារ និង ២១,៣% សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ (កម្រិតបទប្បញ្ញត្តិអប្បបរមា ១៥%) ii/-កម្រិតខ្ពស់នៃអនុបាតគ្របខ័ណ្ឌសន្ទនីយភាព ដោយគ្រឹះស្ថានធនាគារពាណិជ្ជមានកម្រិត ១៥៥,៩% និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ១២៥% (កម្រិតបទប្បញ្ញត្តិអប្បបរមា ១០០%) iii/-កម្រិតទាបនៃអនុបាតឥណទានមិនដំណើរការរបស់វិស័យធនាគារនិងវិស័យមីក្រូហិរញ្ញវត្ថុ ក្នុងកម្រិតប្រហាក់ប្រហែលគ្នា ប្រមាណ ២,៤% និង iv/-លទ្ធភាពស្វែងរកប្រាក់ចំណេញមានស្ថិរភាពល្អ ដោយអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មមានកម្រិត ១,៨% សម្រាប់វិស័យធនាគារ និង ៣% សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ។

**ក្រាហ្វ ៣៦ ៖ អនុបាតសាធនភាព**

(គិតជាភាគរយ, ឆ្នាំ២០១៧ - ខែវិច្ឆិកា ឆ្នាំ២០២១)




**ក្រាហ្វ ៣៧ ៖ អនុបាតគ្របខ័ណ្ឌសន្ទនីយភាព**

(គិតជាភាគរយ, ឆ្នាំ២០១៧ - ខែវិច្ឆិកា ឆ្នាំ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣៨ ៖ ប្រាក់បញ្ញើ និងឥណទានរបស់ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៤ - ២០២១ប)




**ក្រាហ្វ ៣៩ ៖ គណនីប្រាក់បញ្ញើ និងគណនីឥណទានរបស់ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**
(គិតជាគណនី, ឆ្នាំ២០១៤ - ២០២១ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

**តារាង ១ ៖ ការរៀបចំឥណទានឡើងវិញរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**
(ឆ្នាំ២០២១ប)

អត្រាប្តូរប្រាក់ ១ ដុល្លារអាមេរិក = ៤.០៧៩រៀល

| លេខ | វិស័យអាទិភាព | វិស័យធនាគារ | វិស័យមីក្រូហិរញ្ញវត្ថុ | ភតិសន្យាហិរញ្ញវត្ថុ | គិតជាប៊ីលានរៀល | គិតជាប៊ីលានដុល្លារអាមេរិក | ចំនួនគណនី |
|---|---|---|---|---|---|---|---|
| ១ | ទេសចរណ៍ | ៣.៦៤៧,៣៤ | ៣៣២,០៦ | ១៩,៨១ | ៣.៩៩៨,៨១ | ០,៩៨ | ៣១.៣៧០ |
| ២ | កាត់ដេរ | ៣៤៤,៣៦ | ៥០២,៨៦ | ៥,៩៨ | ៨៥២,៨០ | ០,២១ | ៦១.៥១៥ |
| ៣ | សំណង់ | ២.៩៥៧,៩៤ | ៣៥១,៨៦ | ៤,៦៩ | ៣.៣១៤,០៩ | ០,៨១ | ៣២.៦៧៨ |
| ៤ | ការដឹកជញ្ជូន និងឡជីស្ទីក | ៨៣០,៣៦ | ២៧៥,៩៩ | ២៨,៨៦ | ១.១៣៥,២១ | ០,២៨ | ១៩.៨៨៨ |
| ៥ | ផ្សេងៗ | ១០.៥០៩,៥២ | ២.៤៦៤,៨៨ | ១៣៤,០៦ | ១៣.១០៨,៨១ | ៣,២១ | ២២៥.៣៣៤ |
| សរុប | | **១៨.២៨៩,៥១** | **៣.៩២៦,៨០** | **១៩៣,០១** | **២២.៤០៩,៣២** | **៥,៤៩** | **៣៧០.៧៨៥** |

## ២- វិស័យធនាគារ

ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារបានកើនឡើង ១៥,៩% (ដល់ ២៣៦,៧ ទ្រីលានរៀល ស្មើនឹង ៥៨ ប៊ីលានដុល្លារអាមេរិក) ហើយឥណទានអតិថិជនកើន ២០,៣% (ដល់ ១៥០,៤ ទ្រីលានរៀល ស្មើនឹង ៣៦,៨ ប៊ីលានដុល្លារអាមេរិក) ជាមួយនឹងចំនួន ១,២ លានគណនី។ ឥណទានត្រូវបានបែងចែកទៅកាន់វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច ដូចជា៖ ការជួញដូររាយ ១៥,៥% (មានកំណើន២៧,៩%) ការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ១៣,២% (មានកំណើន ៣៧,៧%) ការជួញដូរដុំ ៩,៧% (មានកំណើន ១៣,៦%) ការឱ្យខ្ចីជាបុគ្គល ១០% (មានកំណើន ១៣,៤%) សំណង់ ៩,៧% (មានកំណើន ៣០,១%) ការជួញដូរអចលនទ្រព្យ ៨,៩% (មានកំណើន ២៣,៥%) កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៧,៩%

(មានកំណើន ១៩,៩%) និងផ្សេងៗ ២៦,១% (មានកំណើន ២០,៥%)។ ប្រាក់បញ្ញើបានកើនឡើង ១៤,៩% ដល់ ១៣៩,៤ ទ្រីលានរៀល (ស្មើនឹង ៣៤,១ ប៊ីលានដុល្លារអាមេរិក) និងមានចំនួន ៩,២ លានគណនី។ ទីស្នាក់ការកណ្តាលនិងសាខារបស់គ្រឹះស្ថានធនាគារមាន ១.៣៤៩ ទីតាំង និងម៉ាស៊ីនដក និងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) មាន ៣.២៣៥។

**ក្រាហ្វ ៤០ ៖ ឥណទានគ្រឹះស្ថានធនាគារតាមវិស័យក្នុងសេដ្ឋកិច្ច**
(ឆ្នាំ២០២១ប)




**ក្រាហ្វ ៤១ ៖ កំណើនឥណទានធនាគារតាមវិស័យក្នុងសេដ្ឋកិច្ច**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ២០២១ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

អត្រាការប្រាក់បញ្ញើជារៀលរបស់គ្រឹះស្ថានធនាគារជាមធ្យមបានកើនឡើងដល់ ៦,១៦% ធៀបនឹង ៥,៩៩% ក្នុងឆ្នាំ២០២០ ខណៈប្រាក់បញ្ញើជាដុល្លារអាមេរិកមានអត្រា ៤,៧៤% ទាបជាងឆ្នាំមុន (៤,៨០%)។ ដោយឡែក អត្រាការប្រាក់ឥណទានជារៀលជាមធ្យមបានថយចុះមក ១២,៤៨% ធៀបនឹងឆ្នាំ២០២០ (១២,៩៨%) ខណៈឥណទានជាដុល្លារអាមេរិកមានអត្រា ១០,៦៨% កើនឡើងពី ១០,៣១% នៅឆ្នាំ២០២០។

**ក្រាហ្វ ៤២ ៖ អត្រាការប្រាក់ជាមធ្យមរបស់គ្រឹះស្ថានធនាគារ**
(គិតជាភាគរយ, ឆ្នាំ២០១៤ - ខែវិច្ឆិកា ឆ្នាំ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៣- វិស័យមីក្រូហិរញ្ញវត្ថុ

ទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើង ១៧% (ដល់ ៨០,១ ទ្រីលានរៀល ស្មើនឹង ១៩,៨ ប៊ីលានដុល្លារអាមេរិក) ដែលក្នុងនោះឥណទានអតិថិជនបានកើនឡើង ២៥,៦% (ដល់ ៣៤,៦ ទ្រីលានរៀល ស្មើនឹង ៨,៥ ប៊ីលានដុល្លារអាមេរិក) ជាមួយនឹងគណនីចំនួន ២ លានគណនី។ ឥណទានទាំងនេះបានផ្តល់ទៅកាន់វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច រួមមាន៖ ក្រុមគ្រួសារ ៣៣,៣% (មានកំណើន ២,៨%) ពាណិជ្ជកម្មនិងជំនួញ ២១,៨% (មានកំណើន ១៩,៩%) កសិកម្ម ១៨,៨% (មានកំណើន ១៣,៦%) សេវាកម្ម ១៤,១% (មានកំណើន ០,៥%) ដឹកជញ្ជូន ៥,៥% (មានកំណើន ១,៥%) សំណង់ ៣,៨% (មានកំណើន ៨,១%) កម្មន្តសាល ១,៥% (មានកំណើន ៧៩,៨%) និងផ្សេងៗ ១,២% (ថយចុះ -២១,៣%)។ ទន្ទឹមនេះ ប្រាក់បញ្ញើវិស័យមីក្រូហិរញ្ញវត្ថុកើន ២០,២% ដល់ ១៧,៧ ទ្រីលានរៀល (ស្មើនឹង ៤,៣ ប៊ីលានដុល្លារអាមេរិក) ដោយមានគណនីចំនួន ២,៨ លានគណនី។

**ក្រាហ្វ ៤៣ ៖ ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមវិស័យក្នុងសេដ្ឋកិច្ច**
(ឆ្នាំ២០២១ប)




**ក្រាហ្វ ៤៤ ៖ កំណើនឥណទានមីក្រូហិរញ្ញវត្ថុតាមវិស័យក្នុងសេដ្ឋកិច្ច**
(ឆ្នាំ២០១៧ - ២០២១ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានបណ្តាញប្រតិបត្តិការគ្របដណ្តប់ទូទាំងប្រទេស ដែលមានការិយាល័យចំនួន ១.១៩៩ ទីតាំង និងបានធ្វើទំនើបកម្មលើសេវាកម្មរបស់ខ្លួន ដូចជា ឥណទានប្រាក់បញ្ញើ ការផ្ទេរប្រាក់ ធនាគារចល័ត និងការដកនិងដាក់ប្រាក់តាមម៉ាស៊ីន ATM ជាដើម ដែលធ្វើឱ្យអតិថិជនមានលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការបានកាន់តែច្រើន។

អត្រាការប្រាក់បញ្ញើជាមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជារៀលនិងជាដុល្លារអាមេរិកបានថយចុះមក ៧,១៩% និង ៦,៩២% រៀងគ្នា ធៀបនឹងឆ្នាំ២០២០ (៧,៥៩% និង ៧,៤៩%)។ ទន្ទឹមនេះ អត្រាការប្រាក់ឥណទានជាមធ្យមជារៀលនិងដុល្លារអាមេរិកក៏មានការថយចុះផងដែរពី ១៧,១៣% និង ១៥,២៦% នៅឆ្នាំ២០២០ មក ១៦,៧២% និង ១៤,៧២% រៀងគ្នា។

**ក្រាហ្វ ៤៥ ៖ អត្រាការប្រាក់ជាមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
(គិតជាភាគរយ, ឆ្នាំ២០១៤ - ខែវិច្ឆិកា ឆ្នាំ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤- វិស័យភតិសន្យាហិរញ្ញវត្ថុ

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុភាគច្រើនមានស្ថានភាពហិរញ្ញវត្ថុ និងការអនុវត្តច្បាប់និងបទប្បញ្ញត្តិល្អ។ ទ្រព្យសកម្មរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុបានកើនឡើង ៧,៣% (ដល់ ១,៧ ទ្រីលានរៀល ស្មើនឹង ៤២៤,៨ លានដុល្លារអាមេរិក)។ ឥណទានភតិសន្យាហិរញ្ញវត្ថុសរុបបានកើនឡើង ៨,៥% (ដល់ ១,៥ ទ្រីលានរៀល ស្មើនឹង ៣៥៨,៨ លានដុល្លារអាមេរិក) ដោយមាន ១០២.៣៨១ គណនី ហើយត្រូវបានផ្តល់ទៅវិស័យជាច្រើនរួមមាន៖ ក្រុមគ្រួសារ ២១% (ថយចុះ -៥,៨%) កសិកម្ម ២១,៧% (មានកំណើន ៨៩%) សេវាកម្ម ១៩,១% (មានកំណើន ១៥,៧%) ដឹកជញ្ជូន ១៤,៦% (មានកំណើន ៤,៩%) សំណង់ ៦,៩% (មានកំណើន ២២,២%) ពាណិជ្ជកម្មនិងជំនួញ ៤,១% (ថយចុះ -៦,៤%) និងវិស័យផ្សេងៗ ១២,៦% (ថយចុះ -២៧,៣%)។ ប្រភពទុនចម្បងនៃឥណទានភតិសន្យាដែលបានមកពីមូលនិធិភាគទុនិក បានកើនឡើង ៩,៨% (ដល់ ៦១៤,៦ ប៊ីលានរៀល ស្មើនឹង ១៥០,៥ លានដុល្លារអាមេរិក)។ ទីស្នាក់ការកណ្តាល និងសាខារបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមានចំនួន ៥២ ទីតាំង។

**ក្រាហ្វ ៤៦ ៖ បរិមាណនិងកំណើនទ្រព្យសកម្ម ភតិសន្យាហិរញ្ញវត្ថុ**
(ឆ្នាំ២០១៧ - ២០២១ប)




**ក្រាហ្វ ៤៧ ៖ កំណើនឥណទានភតិសន្យាហិរញ្ញវត្ថុតាមវិស័យ**
(ឆ្នាំ២០១៧ - ២០២១ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

### ៥- គ្រឹះស្ថានឥណទានជនបទ

គ្រឹះស្ថានឥណទានជនបទរួមចំណែកផ្តល់សេវាឥណទានខ្នាតតូច ជាពិសេសនៅតាមតំបន់ជនបទ ដើម្បីបំពេញតម្រូវការឥណទានទៅតាមប្រភេទអាជីវកម្មរបស់ប្រជាពលរដ្ឋ។ គ្រឹះស្ថានឥណទានជនបទបានផ្តល់ឥណទានសរុប ២៤៤,៦ ប៊ីលានរៀល (ស្មើនឹង ៦០ លានដុល្លារអាមេរិក) និងមានគណនីចំនួន ៤០.៥៧០ គណនី។

គ្រឹះស្ថានឥណទានជនបទ ក៏បានចូលរួមអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាដោយបន្ធូរបន្ថយអត្រាការប្រាក់ និងអនុគ្រោះដល់អតិថិជនដែលរងផលប៉ះពាល់ដោយសារការរាលដាលនៃជំងឺកូវីដ-១៩។

### ៦- អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន

ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ដែលជាអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានទ្រព្យសកម្មសរុបប្រមាណ ៦៧,៥ ប៊ីលានរៀល (១៦,៥ លានដុល្លារអាមេរិក) និងមានគ្រឹះស្ថានជាសមាជិកចំនួន ១៦៨[២៤] គ្រឹះស្ថាន។ គ្រឹះស្ថានជាសមាជិកបានបញ្ចូលទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានចំនួន ៣.៦៩៥.៣៦០ គណនី (ប្រមាណ ១៧៨,៥ ទ្រីលានរៀល ស្មើនឹង ៤៣,៧ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះ៖ i/-ឯកត្តបុគ្គលមាន ៣.៦៩០.៥១៤ គណនី ជាមួយនឹងអតិថិជនសរុបចំនួន ៤.៥០៣.២២៦ នាក់ ក្នុងនោះជាបុរសចំនួន ២.០៧៧.០៩៩ នាក់ (៤៦%) និងជាស្ត្រីចំនួន ២.៤២៦.១២៧ នាក់ (៥៤%) និង ii/-ក្រុមហ៊ុនមាន ៤.៨៤៦ គណនី ជាមួយនឹងអតិថិជនសរុបចំនួន ១.៤៦២ ក្រុមហ៊ុន។

បន្ទាប់ពីការកែសម្រួលប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន នៅខែមិថុនា ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឱ្យអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានដាក់ដំណើរការជាផ្លូវការនូវការបញ្ចូលទិន្នន័យព័ត៌មានមូលប្បទានប័ត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ក្នុងខែមេសា ឆ្នាំ២០២១។ គ្រឹះស្ថានបានបញ្ចូលទិន្នន័យនៃមូលប្បទានប័ត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីសរុបមានចំនួន ៩១៣ ប្រតិបត្តិការ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបន្តតាមដាននិងត្រួតពិនិត្យលើទិន្នន័យរបស់គ្រឹះស្ថានជាសមាជិកដែលរាយការណ៍ប្រចាំគ្រា ដោយអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានពាក់ព័ន្ធនឹងការអនុវត្តស្របតាមខ្លឹមសារបទប្បញ្ញត្តិជាធរមានក្នុងការធានាគុណភាពទិន្នន័យ និងនិរន្តរភាពនៃដំណើរការប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅកម្ពុជា។

[២៤] ក្នុងនោះមាន ធនាគារពាណិជ្ជ ៥៤ ធនាគារឯកទេស ១០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៧៤ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៦ និងគ្រឹះស្ថានឥណទានជនបទ ៨។

## ៧- ការត្រួតពិនិត្យ និងបញ្ញត្តកម្ម

### ក-សកម្មភាពត្រួតពិនិត្យ

ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានពង្រឹងតាមវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត តាមរយៈការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ការវាយតម្លៃប្រសិទ្ធភាពនៃអភិបាលកិច្ច និងការវាយតម្លៃហានិភ័យសំខាន់ៗ រួមមានៈ ហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យយុទ្ធសាស្ត្រ ហានិភ័យប្រតិបត្តិការ ហានិភ័យសន្ទនីយភាព និងហានិភ័យប្រាក់ចំណេញ ជាដើម។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាកំពុងរៀបចំសេចក្តីណែនាំ និងនីតិវិធីថ្មីក្នុងការពិនិត្យ តាមដាន និងវាយតម្លៃ (Supervisory Review and Evaluation Process) គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដោយផ្អែកលើហានិភ័យនិងទស្សនៈអនាគត។

ការត្រួតពិនិត្យនិងតាមដានត្រូវបានធ្វើឡើងជាប្រចាំទៅលើការអនុវត្តការរៀបចំឥណទានឡើងវិញក្នុងគោលបំណងតាមដានស្ថានភាពរួមរបស់ប្រព័ន្ធធនាគារទាំងមូល តាមរយៈការធ្វើស្រ្តេសតេស្ត និងស្រ្តេសតេស្តត្រឡប់ (Reverse Stress Test)។ លទ្ធផលជារួមពីការធ្វើស្រ្តេសតេស្ត និងស្រ្តេសតេស្តត្រឡប់នេះបានបង្ហាញថា ប្រព័ន្ធធនាគារនៅតែរក្សាបានភាពរឹងមាំ និងមានភាពធន់ តាមរយៈការរក្សាបាននូវអនុបាតសាធនភាព អនុបាតក្របខ័ណ្ឌសន្ទនីយភាព និងអនុបាតប្រុងប្រយ័ត្នផ្សេងៗទៀត ដែលកំណត់ដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជា។

### ខ- ការរៀបចំបទប្បញ្ញត្តិ

ប្រកាស សារាចរណែនាំ និងសេចក្តីណែនាំមួយចំនួន ដែលត្រូវបានដាក់ឱ្យអនុវត្ត រួមមានៈ i/-ប្រកាសស្តីពី លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការធ្វើអាជីវកម្ម បេ៉ងកាស្សួរេន (Bancassurance) (នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១) ii/-សារាចរណែនាំស្តីពី ការវាយតម្លៃ ការធ្វើចំណាត់ថ្នាក់ និងការធ្វើសំវិធានធនចំពោះឥណទានរៀបចំឡើងវិញ (នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១) និង iii/-សេចក្តីណែនាំអំពី ការអនុវត្តប្រកាសស្តីពី ក្របខ័ណ្ឌសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១)។

លើសពីនេះ ធនាគារជាតិនៃកម្ពុជាកំពុងរៀបចំសេចក្តីព្រាងប្រកាសចំនួន ៥ ទៀតនៃក្របខ័ណ្ឌសាធនភាពស្របតាមស្តង់ដាបាសែល៣ ដែលជាផ្នែកមួយនៃការអនុវត្តផែនការត្រួតពិនិត្យផ្អែកលើហានិភ័យ ក្នុងនោះរួមមានៈ ប្រកាសទាក់ទងនឹងដើមទុនបទប្បញ្ញត្តិ ហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យប្រតិបត្តិការ និងអនុបាតសាធនភាព ឬភាពគ្រប់គ្រាន់នៃដើមទុន ព្រមទាំងសេចក្តីព្រាងប្រកាសស្តីពីហាយភើឆេស (Hire Purchase) និងសេចក្តីណែនាំមួយចំនួន ដូចជា សេចក្តីណែនាំលើហានិភ័យឥណទាន និងសេចក្តីណែនាំលើទ្រព្យធានា។

## ៨- កិច្ចការពារអតិថិជន និងបរិយាបន្នហិរញ្ញវត្ថុ

### ក- កិច្ចការពារអតិថិជន និងការដោះស្រាយបណ្តឹង

យន្តការសម្របសម្រួលដោះស្រាយបណ្តឹងអតិថិជន ត្រូវបានបន្តពង្រឹងតាមរយៈលេខទូរស័ព្ទហាត់ឡាញ (Hotline) របស់ធនាគារជាតិនៃកម្ពុជា ប្រកបដោយប្រសិទ្ធភាព ទាន់ពេលវេលា និងមានសង្គតិភាព ដើម្បីធានាពីកិច្ចគាំពារអតិថិជន។ ក្នុងឆ្នាំ២០២១ បណ្តឹង និងការសាកសួរព័ត៌មានមានចំនួន ៥១៤ ករណី ដែលក្នុងនោះ ៥០២ ករណីដោះស្រាយរួចរាល់ ៧ ករណីកំពុងដោះស្រាយ និង ៥ ករណីស្ថិតក្នុងនីតិវិធីតុលាការ។

ប្រព័ន្ធការពារអ្នកដាក់ប្រាក់បញ្ញើនៅកម្ពុជាត្រូវបានសិក្សានិងរៀបចំក្នុងគោលបំណង៖ i/-ការពារអ្នកដាក់ប្រាក់បញ្ញើ ii/-ពង្រឹងជំនឿទុកចិត្តរបស់សាធារណជន និង iii/-រួមចំណែកក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ។ សេចក្តីព្រាងបទប្បញ្ញត្តិទាក់ទងនឹងកិច្ចការពារប្រាក់បញ្ញើ ដែលត្រូវបានរៀបចំជាភាសាខ្មែរ និងអង់គ្លេស ត្រូវបានពិនិត្យ ពិភាក្សា និងកែសម្រួលដោយក្រុមផ្តល់យោបល់ ហើយក៏បានឆ្លងការពិភាក្សាជាមួយគណៈកម្មការបញ្ញត្តកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធនាគារជាតិនៃកម្ពុជារួចរាល់ផងដែរ។

## ខ- ការរៀបចំក្របខ័ណ្ឌតាមដាននិងវាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥

ក្រោមកិច្ចសហការជាមួយមូលនិធិ UNCDF មូលដ្ឋានទិន្នន័យត្រូវបានរៀបចំឡើងសម្រាប់ធ្វើជាសូចនាករក្នុងការអនុវត្តនិងវាស់វែងយុទ្ធសាស្ត្រជាតិ ដោយផ្តោតលើការទទួលបាន ការប្រើប្រាស់និងគុណភាពសេវាហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់។ លទ្ធផលនៃការប្រមូលទិន្នន័យ តាមរយៈការសិក្សាលើផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ក៏នឹងត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃលើដំណើរការជំរុញកម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ ទន្ទឹមនេះ សិក្ខាសាលាស្តីពីការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ក៏ត្រូវបានរៀបចំឡើងដើម្បីផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយផងដែរ ។

## គ- ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ

### - ការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ និងការគាំទ្រយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ

ការបន្តកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ Credit Union Foundation Australian (CUFA) បានគាំទ្រការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដំណាក់កាលទី២ តាមរយៈការរៀបចំឯកសារសម្រាប់គ្រូនិងសិស្ស និងការបង្រៀនសាកល្បងសម្រាប់ថ្នាក់ទី៤ និងទី៧។ សៀវភៅណែនាំសម្រាប់គ្រូបង្រៀន និងសៀវភៅមេរៀនសម្រាប់សិស្សលើមុខវិជ្ជាពាក់ព័ន្ធនឹងចំណេះដឹងហិរញ្ញវត្ថុ ត្រូវបានសហការរៀបចំឡើង ក្នុងនោះថ្នាក់ទី៤ មានមុខវិជ្ជាគណិតវិទ្យា សិក្សាសង្គម និងបំណិនជីវិត ហើយថ្នាក់ទី៧ មានមុខវិជ្ជាគេហសេដ្ឋកិច្ចវិទ្យា សីលធម៌ពលរដ្ឋវិទ្យា គណិតវិទ្យា និងបំណិនជីវិត។ បច្ចុប្បន្ន ក្របខ័ណ្ឌអប់រំផ្នែកហិរញ្ញវត្ថុ សេចក្តីព្រាងលទ្ធផលសិក្សាលើគ្រប់មុខវិជ្ជាពាក់ព័ន្ធ និងការកំណត់និងរៀបចំប្រធានបទសិក្សាពាក់ព័ន្ធនឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ត្រូវបាននិងកំពុងរៀបចំ។

ធនាគារជាតិនៃកម្ពុជាបានគាំទ្រដល់យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់គណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុនៃសមាគមធនាគារនៅកម្ពុជា ដែលត្រូវបានអនុវត្តនៅរៀងរាល់ថ្ងៃចន្ទនៃសប្តាហ៍ទី១ក្នុងខែនីមួយៗ តាមរយៈការផ្តល់ឯកសារ និងសារគន្លឹះជាវីដេអូ ឬពាក្យស្លោកដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុដែលធនាគារជាតិនៃកម្ពុជាកំពុងប្រើប្រាស់ដើម្បីឱ្យគណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកធ្វើការផ្សព្វផ្សាយបន្តនៅក្នុងយុទ្ធនាការនេះ។

- ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនភាពស្ត្រី

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តកិច្ចសហការជាមួយក្រសួងកិច្ចការនារី ដើម្បីបញ្ចប់គម្រោង "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនភាពស្ត្រី"។ ក្នុងឆ្នាំ២០២១ ក្រោមកិច្ចសហការជាមួយក្រសួងកិច្ចការនារី វេទិកាចំនួន ២ លើកត្រូវបានរៀបចំឡើងសម្រាប់សហគ្រិនស្ត្រីនិងនិស្សិតជាស្ត្រីនៅតាមវិទ្យាស្ថាននិងសាកលវិទ្យាល័យពាក់ព័ន្ធនឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់បង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចនិងអភិវឌ្ឍសហគ្រិនភាពដល់ស្ត្រីក្នុងបរិការណ៍ជំងឺកូវីដ-១៩។ ជាមួយគ្នានេះ អង្គការ UNESCAP បានសហការលើការអនុវត្តគម្រោង "ការជំរុញសហគ្រិនភាពរបស់ស្ត្រី (Catalyzing Women's Entrepreneurship)" ដើម្បីបង្កើតនូវវគ្គបណ្តុះបណ្តាលដល់ស្ត្រី និងសហគ្រិនជាស្ត្រី ក្នុងគោលដៅបង្កើនការយល់ដឹងពីលទ្ធភាពទទួលបាន និងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការដែលគ្រោងនឹងចាប់ផ្តើមអនុវត្តនៅឆ្នាំ២០២២។

- យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "តោះ! និយាយពីលុយ"

អង្គការ Good Return បានសហការអនុវត្តគម្រោងរៀបចំយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "តោះ! និយាយពីលុយ៖ តក់ៗពេញបំពង់" ដែលបានចាប់ផ្តើមក្នុងឆ្នាំ២០២០ និងបានដាក់ឱ្យដំណើរការជាផ្លូវការ កាលពីថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២១។ យុទ្ធនាការនេះ មានគោលដៅពង្រឹងការយល់ដឹងរបស់ប្រជាជនពាក់ព័ន្ធនឹងបញ្ហាហិរញ្ញវត្ថុ ដូចជា ការថ្លឹងថ្លែងជម្រើសផលិតផល និងសេវាហិរញ្ញវត្ថុ ការយល់ដឹងអំពីសិទ្ធិនិងការទទួលខុសត្រូវ ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ រួមគ្នារវាងបុរស និងស្ត្រី ក្នុងគ្រួសារជាដើម។ បច្ចុប្បន្ន គេហទំព័រ "តោះ! និយាយពីលុយ" សម្រាប់កម្មការិនីនិងសហគ្រិនស្ត្រីកំពុងត្រូវបានអភិវឌ្ឍ ហើយកម្មវិធីទូរស័ព្ទ NBC-Edu សម្រាប់ផ្តល់ការអប់រំចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅកាន់កុមារក៏កំពុងត្រូវបានធ្វើទំនើបកម្ម។

## V- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល

### ១- ប្រព័ន្ធទូទាត់សងប្រាក់

ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធវីធែលផេជាផ្លូវការ កាលពីខែមករា ឆ្នាំ២០២១ ដើម្បីផ្តល់ជម្រើសបន្ថែមទៀតដល់អតិថិជនក្នុងការធ្វើប្រតិបត្តិការទូទាត់ឌីជីថលក្នុងអំឡុងពេលនៃការរាលដាលនៃជំងឺកូវីដ-១៩។ លើសពីនេះ ប្រព័ន្ធសេវាទូទាត់រហ័សក៏ត្រូវបានធ្វើបច្ចុប្បន្នកម្មជាប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មីតាមដំណាក់កាល ដោយមានបន្ថែមមុខងារថ្មីៗ និងបានដាក់ឱ្យគ្រឹះស្ថានសមាជិកប្រើប្រាស់ក្នុងដំណាក់កាលដំបូងកាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១។ ប្រព័ន្ធទូទាត់តម្លៃធំក៏កំពុងត្រូវបានអភិវឌ្ឍដើម្បីសម្រួល និងកាត់បន្ថយហានិភ័យចំពោះប្រតិបត្តិការទូទាត់សងប្រាក់តម្លៃធំអន្តរធនាគារ ជាពិសេសប្រតិបត្តិការទូទាត់ក្នុងទីផ្សារហិរញ្ញវត្ថុ។ ដើម្បីសម្រួលដល់ការផ្ទេរប្រាក់ និងការទូទាត់ពាណិជ្ជកម្មឆ្លងដែនរវាងកម្ពុជានិងម៉ាឡេស៊ីឱ្យកាន់តែមានប្រសិទ្ធភាពនិងកម្រៃសមរម្យ

ជំរុញបរិយាបន្នហិរញ្ញវត្ថុ ជាពិសេសការផ្ទេរប្រាក់របស់ពលករកម្ពុជាដែលធ្វើការនៅប្រទេសម៉ាឡេស៊ី ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍការភ្ជាប់ការទូទាត់ឆ្លងដែនរវាងប្រទេសទាំងពីរតាមរយៈប្រព័ន្ធបាគង និងប្រព័ន្ធ M2U របស់ធនាគារមេយប៉ែង។ គម្រោងទូទាត់ឆ្លងដែននេះត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១។

ក្នុងគោលបំណងជំរុញនិងលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា ធនាគារជាតិនៃកម្ពុជាបានរៀបចំ "ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុឆ្នាំ២០២០-២០២៥" ក្នុងក្របខ័ណ្ឌវិស័យធនាគារ។ លើសពីនេះ ពិធី CamTech Summit ក៏ត្រូវបានរៀបចំក្រោមកិច្ចសហការជាមួយអាជ្ញាធររូបិយវត្ថុសិង្ហបុរី (ក្នុងនាមជាប្រទេសដៃគូនៃកម្មវិធីបច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី) សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងសមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជាក្នុងគោលបំណងផ្តល់ជាវេទិកាសម្រាប់ភាគីពាក់ព័ន្ធពិភាក្សានិងស្វែងយល់អំពីការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ ជាពិសេសបច្ចេកវិទ្យាហិរញ្ញវត្ថុទាំងក្នុងប្រទេស និងសកលលោក។

ដើម្បីពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ សារាចរណែនាំស្តីពី "នីតិវិធីស្គាល់អត្តសញ្ញាណអតិថិជន និងការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់សេវាទូទាត់សងប្រាក់ក្នុងប្រទេសកម្ពុជា" ត្រូវបានរៀបចំឡើង ដែលផ្តល់ការណែនាំអំពីនីតិវិធីរួមក្នុងការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់នៅពេលចុះឈ្មោះបង្កើតគណនី ក៏ដូចជាកំណត់អំពីទំហំប្រាក់ប្រតិបត្តិការស្របតាមកម្រិតហានិភ័យរបស់អ្នកប្រើប្រាស់នីមួយៗ ដើម្បីរួមចំណែកសម្រួលការទូទាត់ជាអេឡិចត្រូនិក។ ការបន្តតាមដាន និងត្រួតពិនិត្យទាំងប្រព័ន្ធទូទាត់សងប្រាក់និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ក៏ត្រូវបានពង្រឹងដើម្បីទប់ស្កាត់ហានិភ័យផ្សេងៗដែលអាចកើតឡើងជាយថាហេតុ និងការអនុវត្តតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

## ២- សេវាផ្ទេរប្រាក់តាមរយៈធនាគារជាតិនៃកម្ពុជា

### ក- សេវាផ្ទេរប្រាក់ក្នុងស្រុក

#### - សេវាផ្ទេរប្រាក់រវាងគណនីនៅទីស្នាក់ការកណ្តាល

សេវាផ្ទេរប្រាក់នៅស្នាក់ការកណ្តាល គឺជាសេវាផ្ទេរប្រាក់ក្នុងចំណោមគណនីដែលបើកនៅស្នាក់ការកណ្តាល។ ប្រតិបត្តិការផ្ទេរប្រាក់នៅស្នាក់ការកណ្តាលមិនត្រូវបានគិតកម្រៃសេវាទេ។ ប្រតិបត្តិការផ្ទេរប្រាក់នៅស្នាក់ការកណ្តាលមានចំនួន ៩.៧៣២ ប្រតិបត្តិការ ក្នុងនោះការផ្ទេរប្រាក់រៀលមានចំនួន ៧.១៤៧ ប្រតិបត្តិការ ស្មើនឹង ១៥,៣ ទ្រីលានរៀល និងការផ្ទេរប្រាក់ដុល្លារអាមេរិកចំនួន ២.៥៨៥ ប្រតិបត្តិការ ស្មើនឹង ៦,១ ប៊ីលានដុល្លារអាមេរិក។ បើប្រៀបធៀបនឹងឆ្នាំ២០២០ ការផ្ទេរប្រាក់រៀលបានថយចុះចំនួន ៣.២៤២ ប្រតិបត្តិការ (ថយ -៣១,២%) ចំនួនប្រាក់ថយចុះ ១,៨ ទ្រីលានរៀល (ថយ -១០,៦%)។ ចំពោះការផ្ទេរប្រាក់ដុល្លារអាមេរិកវិញ ចំនួនប្រតិបត្តិការបានថយចុះ ៩៣៩ ប្រតិបត្តិការ (ថយ -២៦,៧%) ចំនួនប្រាក់កើនឡើង ២៧៨,៥ លានដុល្លារអាមេរិក (កើន ៤,៨%)។

ក្រាហ្វ ៤៨ ៖ ការផ្ទេរប្រាក់រៀលនៅស្នាក់ការកណ្តាល
(ឆ្នាំ២០១៧ - ២០២១)




ក្រាហ្វ ៤៩ ៖ ការផ្ទេរប្រាក់ដុល្លារអាមេរិកនៅស្នាក់ការកណ្តាល
(ឆ្នាំ២០១៧ - ២០២១)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

- **សេវាផ្ទេរប្រាក់ជាមួយសាខារាជធានី-ខេត្ត**

ការផ្ទេរប្រាក់ជាមួយសាខារាជធានី-ខេត្តគឺជាការផ្ទេរប្រាក់ទៅ-មក រវាងស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាជាមួយនឹងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត។ ប្រតិបត្តិការផ្ទេរប្រាក់ជាមួយនឹងសាខារាជធានី-ខេត្ត ត្រូវបានគិតកម្រៃសេវាក្នុងមួយប្រតិបត្តិការចំនួន ០,១% នៃចំនួនប្រាក់ផ្ទេរ ដោយយកកម្រៃអប្បបរមាត្រឹម ១២.០០០រៀល និងអតិបរមាមិនលើស ៤លានរៀល ដោយឡែកការផ្ទេរប្រាក់ ដែលជាថវិការដ្ឋមិនត្រូវបានគិតកម្រៃសេវាទេ។ ការផ្ទេរប្រាក់ជាមួយនឹងសាខារាជធានី-ខេត្តមាន ៣.០៩២ ប្រតិបត្តិការ ដែលក្នុងនោះប្រាក់រៀលមាន ១.៩៣៥ ប្រតិបត្តិការ និងប្រាក់ដុល្លារអាមេរិក មាន ១.១៥៧ ប្រតិបត្តិការ។ ចំពោះការផ្ទេរប្រាក់រៀលចេញទៅសាខាមាន ៣១៣ ប្រតិបត្តិការ (៧២,៩ ប៊ីលានរៀល) ហើយការផ្ទេរប្រាក់រៀលចូលមាន ១.៦២២ ប្រតិបត្តិការ (៣,២ ទ្រីលានរៀល)។ បើធៀបនឹងឆ្នាំមុន ការផ្ទេរប្រាក់រៀលចេញបានថយចុះ ៥១ ប្រតិបត្តិការ ស្មើនឹង ៦៩,៣ ប៊ីលានរៀល (ថយ -៤៨,៧%) ហើយការផ្ទេរប្រាក់ចូលបានកើនឡើង ២០២ ប្រតិបត្តិការ ស្មើនឹង ១,៣ ទ្រីលានរៀល (កើនឡើង ៦៥,៦%)។

ចំណែកឯ ការផ្ទេរប្រាក់ដុល្លារអាមេរិកចេញមាន ៨០ ប្រតិបត្តិការ (១៦៣,៣ លានដុល្លារអាមេរិក) ហើយការផ្ទេរប្រាក់ដុល្លារអាមេរិកចូលមាន ១.០៧៧ ប្រតិបត្តិការ (២,៣ ប៊ីលានដុល្លារអាមេរិក)។ ធៀបនឹងឆ្នាំមុន ការផ្ទេរប្រាក់ដុល្លារអាមេរិកចេញបានថយចុះ ២៥១ ប្រតិបត្តិការ ស្មើនឹង ១៦២ លានដុល្លារអាមេរិក (ថយ -៤៩,៨%) ហើយការផ្ទេរប្រាក់ដុល្លារអាមេរិកចូលបានថយចុះ ២៣៧ ប្រតិបត្តិការ ស្មើនឹង ៦៨៥,៨ លានដុល្លារអាមេរិក (ថយ -២៣%)។

**ក្រាហ្វ ៥០ ៖ ការផ្ទេរប្រាក់រៀលនៅស្នាក់ការកណ្តាលនិងសាខា**
(ឆ្នាំ២០១៧ - ២០២១)




**ក្រាហ្វ ៥១ ៖ ការផ្ទេរប្រាក់ដុល្លារអាមេរិកនៅស្នាក់ការកណ្តាលនិងសាខា**
(ឆ្នាំ២០១៧ - ២០២១)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

- **សេវាផ្ទេរប្រាក់តាមប្រព័ន្ធធនាគារអនឡាញ** (OBS)

បច្ចុប្បន្នសមាជិករបស់ប្រព័ន្ធធនាគារអនឡាញមានចំនួន ៦៨ ក្នុងនោះ មានធនាគារពាណិជ្ជ ៤៦ ធនាគារឯកទេស ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៧ គ្រឹះស្ថានទូទាត់សងប្រាក់ ១២ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការផ្ទេរប្រាក់តាមប្រព័ន្ធ OBS មាន ៤៣.៩១០ ប្រតិបត្តិការ ដែលក្នុងនោះការផ្ទេរប្រាក់ក្នុងចំណោមគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាមាន ៤២.១៥៥ ប្រតិបត្តិការ និងការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្តមាន ១.៧៥៥ ប្រតិបត្តិការ។

ការផ្ទេរប្រាក់នៅស្នាក់ការកណ្តាលជាប្រាក់រៀលមាន ២៦.៩០៨ ប្រតិបត្តិការ ស្មើនឹង ៨០,៩ ទ្រីលានរៀល និងជាប្រាក់ដុល្លារអាមេរិកមាន ១៥.២៤៧ ប្រតិបត្តិការ ស្មើនឹង ៤២,៩ ប៊ីលានដុល្លារអាមេរិក។ បើធៀបនឹងឆ្នាំមុន ការផ្ទេរប្រាក់រៀលកើន ១០.៦៤០ ប្រតិបត្តិការ ស្មើនឹង ២៣,៣ ទ្រីលានរៀល (កើន ៤០,៣%) ហើយការផ្ទេរប្រាក់ដុល្លារអាមេរិកកើន ១៤.៣០១ ប្រតិបត្តិការ ស្មើនឹង ១២,៧ ប៊ីលានដុល្លារអាមេរិក (កើន ៤១,៩%)។

ចំពោះការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្ត ជាប្រាក់រៀលមាន ៩២១ ប្រតិបត្តិការ ស្មើនឹង ៣,៣ ទ្រីលានរៀល ហើយការផ្ទេរប្រាក់ជាដុល្លារអាមេរិកមាន ៨៣៤ ប្រតិបត្តិការ ស្មើនឹង ១ ប៊ីលានដុល្លារអាមេរិក។ បើធៀបនឹងឆ្នាំមុន ការផ្ទេរប្រាក់រៀលបានកើនឡើង ១៧៦ ប្រតិបត្តិការ ស្មើចំនួនប្រាក់ ៩១១,៨ ប៊ីលានរៀល (៣៧,៧%) ហើយការផ្ទេរប្រាក់ដុល្លារអាមេរិកបានកើនឡើង ២៣៧ ប្រតិបត្តិការ ស្មើនឹង ៤៩៥,១ លានដុល្លារអាមេរិក (៩០,៥%)។

**ក្រាហ្វ ៥២ ៖ ការផ្ទេរប្រាក់រៀលតាមរយៈប្រព័ន្ធ OBS**

(ឆ្នាំ២០១៧ - ២០២១)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៥៣ ៖ ការផ្ទេរប្រាក់ដុល្លារអាមេរិកតាមរយៈប្រព័ន្ធ OBS**

(ឆ្នាំ២០១៧ - ២០២១)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ខ-សេវាផ្ទេរប្រាក់ក្រៅប្រទេស

ការផ្ទេរប្រាក់ក្រៅប្រទេស ត្រូវបានគិតកម្រៃសេវាទៅតាមបរិមាណផ្ទេរ[២៥] ចំណែកការផ្ទេរប្រាក់ដែលជាថវិការដ្ឋ កម្រៃសេវាគឺគិតយកតែកម្រៃសេវាក្រៅប្រទេស និងកម្រៃ SWIFT ប៉ុណ្ណោះ។

ការផ្ទេរប្រាក់ក្រៅប្រទេសមាន ៣.០០៤ ប្រតិបត្តិការ ដែលក្នុងនោះការផ្ទេរប្រាក់ចេញមាន ២.១៥៤ ប្រតិបត្តិការ ស្មើនឹង ៧,៨ ប៊ីលានដុល្លារអាមេរិក និងការផ្ទេរប្រាក់ចូលមាន ៨៥០ ប្រតិបត្តិការ ស្មើនឹង ០,៧ ប៊ីលានដុល្លារអាមេរិក។ បើធៀបនឹងឆ្នាំមុន ចំនួនប្រតិបត្តិការផ្ទេរប្រាក់ចេញកើនឡើង ៦៣២ ប្រតិបត្តិការ ស្មើនឹង ៥,៨ ប៊ីលានដុល្លារអាមេរិក (កើន ៣ដង) ខណៈដែលការផ្ទេរប្រាក់ចូលបានថយចុះ ៣១៥ ប្រតិបត្តិការ ស្មើនឹង ៦៥២,៤ លានដុល្លារអាមេរិក (ថយ -៤៩,៥%) ។

---

[២៥] មានបីប្រភេទគឺ Commission ចំនួន ០,១២% នៃបរិមាណប្រាក់ផ្ទេរ (អតិបរមា ៩ លានរៀល និងអប្បបរមា ៣០.០០០រៀល) កម្រៃសេវាក្រៅប្រទេស ១០០.០០០ រៀល និងកម្រៃ SWIFT ១២០.០០០រៀល ក្នុងមួយប្រតិបត្តិការ។

**ក្រាហ្វ ៥៤ ៖ ការផ្ទេរប្រាក់ក្រៅប្រទេស**

(ឆ្នាំ២០១៧ - ២០២១)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ៣- សេវាផាត់ទាត់ឧបករណ៍ទូទាត់សងប្រាក់

ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងលើប្រព័ន្ធទូទាត់សងប្រាក់ចំនួន ៥ រួមមាន៖ ប្រព័ន្ធផាត់ទាត់ជាតិ (NCS) ប្រព័ន្ធសេវាទូទាត់រហ័ស (FAST) ប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS) ប្រព័ន្ធរីថៃលផេ (Retail Pay) និងប្រព័ន្ធបាគង។

**ក- ប្រព័ន្ធផាត់ទាត់ជាតិ៖** ប្រព័ន្ធផាត់ទាត់ជាតិមានដំណើរការទូទាត់លើប្រតិបត្តិការនៃឧបករណ៍ទូទាត់មូលប្បទានប័ត្រ និងបញ្ជាផ្ទេរឥណទាន។ នៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា ប្រព័ន្ធផាត់ទាត់ជាតិមានសមាជិកផ្ទាល់ ៣៦ និងសមាជិកមិនផ្ទាល់ ១៨ និងមានសមាជិកចូលរួមតាមមណ្ឌលដោះដូរមូលប្បទានប័ត្រទាំង ៧ ដូចជា៖ ខេត្តសៀមរាប ២៧ កំពង់ចាម ១៨ ព្រះសីហនុ ១៩ បាត់ដំបង ២០ បន្ទាយមានជ័យ ៨ ស្វាយរៀង ៧ និង កំពង់ធំ ៦។ ដោយសារដំណើរការទូទាត់នៃប្រព័ន្ធផាត់ទាត់ជាតិមានលក្ខណៈមជ្ឈការនៅស្នាក់ការកណ្តាល ដូច្នេះមណ្ឌលដោះដូរមូលប្បទានប័ត្រទាំង ៧ មានភារកិច្ចដោះដូរមូលប្បទានប័ត្ររូបវន្តប៉ុណ្ណោះ។ ប្រព័ន្ធផាត់ទាត់ជាតិធ្វើការទូទាត់ប្រតិបត្តិការ ២ ដង ក្នុង ១ ថ្ងៃ គឺ ពេលព្រឹកម៉ោង ១១និង១៥នាទី ទូទាត់លើប្រតិបត្តិការបញ្ជាផ្ទេរឥណទាន និងម៉ោង ៣និង១៥នាទីរសៀល ទូទាត់រួមគ្នាលើប្រតិបត្តិការបញ្ជាផ្ទេរឥណទាន និងប្រតិបត្តិការមូលប្បទានប័ត្រ។

- **ទូទាត់តាមមូលប្បទានប័ត្រ៖** សកម្មភាពទូទាត់មូលប្បទានប័ត្រនៅក្នុងប្រព័ន្ធផាត់ទាត់ជាតិបានដំណើរការចំនួន ២៤២ថ្ងៃ។ ការទូទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀលមាន ៣១,៧ ពាន់សន្លឹក បានថយចុះ -១០,៧% (ពី ៣៥,៥៧ ពាន់សន្លឹក) និងទំហំប្រាក់ទូទាត់មាន ១៩,១ ទ្រីលានរៀលបានថយចុះ -១៦,៨% ធៀបនឹងឆ្នាំមុន (ពី ២២,៩ ទ្រីលានរៀល)។ ចំណែកឯការទូទាត់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិកមាន ១,០៧ លានសន្លឹក បានថយចុះ -១០,៣% (ពី ១,២ លានសន្លឹក) និងទំហំប្រាក់ទូទាត់បានថយចុះ -៧,៦% (ពី ៥០,២ ប៊ីលានដុល្លារអាមេរិក មក ៤៦,៤ ប៊ីលានដុល្លារអាមេរិក)។

**ក្រាហ្វ ៥៥ ៖ ចំនួនមូលប្បទានប័ត្រជាប្រាក់រៀល និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ២០២១)




**ក្រាហ្វ ៥៦ ៖ ទំហំទឹកប្រាក់មូលប្បទានប័ត្រជាប្រាក់រៀល និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៥៧ ៖ ចំនួនមូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ២០២១)




**ក្រាហ្វ ៥៨ ៖ ទំហំទឹកប្រាក់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

- **សេវាទូទាត់បញ្ជាផ្ទេរឥណទាន៖** ការប្រើប្រាស់បញ្ជាផ្ទេរឥណទានដែលជាឧបករណ៍ទូទាត់សងប្រាក់អេឡិចត្រូនិក មានការកើនឡើងគួរឱ្យកត់សម្គាល់។ កំណើននេះបង្ហាញពីកំណើនទូទាត់ក្នុងសកម្មភាពសេដ្ឋកិច្ច ដោយប្រើប្រាស់ឧបករណ៍ទូទាត់អេឡិចត្រូនិកជំនួសឱ្យការប្រើប្រាស់មូលប្បទានប័ត្រ និងសាច់ប្រាក់។ ប្រតិបត្តិការបញ្ជាផ្ទេរឥណទានជាប្រាក់រៀលមានចំនួន ១៥,៩ ពាន់ប្រតិបត្តិការ ដោយបានកើនឡើង ៥៧,៤% (ពី ១០,១ ពាន់ប្រតិបត្តិការ) និងទំហំប្រាក់ផ្ទេរមានចំនួន ៤,៩ ទ្រីលានរៀលដោយបានកើនឡើង ៥,២% (ពី ៤,៧ ទ្រីលានរៀល)។ បញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិកមានចំនួន ៥៦៣,១ ពាន់ប្រតិបត្តិការ ដោយបានកើនឡើង ៧១,៤% (ពី ៣២៨,៤ ពាន់ប្រតិបត្តិការ) ប៉ុន្តែទំហំប្រាក់ផ្ទេរមានចំនួន ១០,៤ ប៊ីលានដុល្លារអាមេរិក ដោយថយចុះ -១៨,១% (ពី ១២,៧ ប៊ីលានដុល្លារអាមេរិក) ធៀបនឹងឆ្នាំមុន។

**ក្រាហ្វ ៥៩ ៖ ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់រៀល និង បម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ២០២១)




**ក្រាហ្វ ៦០ ៖ ទំហំទឹកប្រាក់បញ្ជាផ្ទេរឥណទានជាប្រាក់រៀល និង បម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៦១ ៖ ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ២០២១)




**ក្រាហ្វ ៦២ ៖ ទំហំទឹកប្រាក់បញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ខ- ប្រព័ន្ធសេវាទូទាត់រហ័ស៖** ប្រព័ន្ធសេវាទូទាត់រហ័សមានសមាជិកសរុប ៥៥ ក្នុងនោះសមាជិកកំពុងដំណើរការ ៤៧ (មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៦)។ ប្រព័ន្ធសេវាទូទាត់រហ័សដំណើរការទូទាត់លើប្រតិបត្តិការផ្ទេរមូលនិធិជាប្រាក់រៀលតម្លៃតូច ដែលមានទំហំប្រាក់អតិបរមា ៤០ លានរៀល ក្នុងមួយប្រតិបត្តិការ។ ការទូទាត់របស់ប្រព័ន្ធនេះមានលក្ខណៈភ្លាមៗសម្រាប់អតិថិជន និងការរង់ចាំការទូទាត់សុទ្ធរវាងសមាជិកនៅពេលក្រោយក្នុងថ្ងៃតែមួយ។ ប្រព័ន្ធសេវាទូទាត់រហ័សបានដំណើរការទូទាត់ចំនួន ២០២ថ្ងៃ និងបានទូទាត់ប្រតិបត្តិការផ្ទេរមូលនិធិចំនួន ៦២ ពាន់ប្រតិបត្តិការ ដោយបានកើនឡើង ៣២,២% (ពី ៤៦,៩ ពាន់ប្រតិបត្តិការ) និងទំហំប្រាក់ទូទាត់មានចំនួន ១៤៣,២ ប៊ីលានរៀល ដោយបានថយចុះ -២២,៦% (ពី ១៨៥ ប៊ីលានរៀល)។

**គ- ប្រព័ន្ធខេមបូឌានស្វ៊ីច (CSS)៖** ប្រព័ន្ធ CSS បានដំណើរការទូទាត់លើឧបករណ៍ទូទាត់ប័ណ្ណឥណពន្ធ ដែលប្រតិបត្តិការផ្ទេរមូលនិធិនៃឧបករណ៍នេះ កើតឡើងដោយប្រើប្រាស់ម៉ាស៊ីនដក និងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) និងម៉ាស៊ីន POS ជាភ្នាក់ងារប្រតិបត្តិការ។ ប្រព័ន្ធ CSS បានដំណើរការ

ទូទាត់លើប្រតិបត្តិការ ៣ ប្រភេទគឺ៖ ប្រតិបត្តិការផ្ទេរប្រាក់ (ATM) ប្រតិបត្តិការដកប្រាក់ (ATM និង POS) ប្រតិបត្តិការទិញទំនិញ (POS) និងមានប្រតិបត្តិការមិនមែនហិរញ្ញវត្ថុ ៣ ទៀត ដូចជា៖ ប្រតិបត្តិការពិនិត្យសមតុល្យ ប្រតិបត្តិការរបាយការណ៍សង្ខេប និងប្រតិបត្តិការប្ដូរលេខសម្ងាត់។ បច្ចុប្បន្នប្រព័ន្ធ CSS មានសមាជិក ៥៣ ក្នុងនោះសមាជិកផ្ទាល់ដែលជាធនាគារពាណិជ្ជមាន ៤៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមាន ៦ ព្រមទាំងសមាជិកមិនផ្ទាល់ជាធនាគារពាណិជ្ជមាន ២។ ប្រព័ន្ធ CSS បានដំណើរការទូទាត់ចំនួន ២៤២ថ្ងៃ ដោយបានទូទាត់លើប្រតិបត្តិការជាប្រាក់រៀលសរុបចំនួន ៣៨៣,៥ ពាន់ប្រតិបត្តិការ ដោយបានកើនឡើង ៦២,១% (ពី ២៣៦,៦ ពាន់ប្រតិបត្តិការ) និងទំហំប្រាក់ទូទាត់មានចំនួន ៧៦,២ ប៊ីលានរៀល ដោយបានកើនឡើងជាង ៧៨,៤% (ពី ៤២,៧ ប៊ីលានរៀល) ធៀបនឹងឆ្នាំ ២០២០។ ប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៨៦,៥ ពាន់ប្រតិបត្តិការ ដោយកើនឡើង ៨១% (ពី ៤៧,៨ ពាន់ប្រតិបត្តិការ) និងទំហំប្រាក់ទូទាត់មានចំនួន ១០,៤ លានដុល្លារអាមេរិក ដោយកើនឡើង ១,១ ដង (ពី ៤,៩ លានដុល្លារអាមេរិក) ធៀបនឹងឆ្នាំ២០២០។

**ឃ- ប្រព័ន្ធរីថែលផេ៖** ប្រព័ន្ធរីថែលផេមានប្រព័ន្ធរងចំនួន ៣ គឺ៖ ប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ (RFT) ប្រព័ន្ធទូទាត់ចល័ត (MPS) និងប្រព័ន្ធទូទាត់តាមរយៈ QR Code (QPS) ដែលមានប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក (ECS) សម្រាប់ធ្វើការបញ្ចូលចំនួនប្រាក់ទូទាត់នៃចំនួនប្រតិបត្តិការនិងកម្រៃប្រតិបត្តិការដែលបានគណនាដោយប្រព័ន្ធកណ្ដាល RFT និង QPS។ ប្រព័ន្ធរីថែលផេមានសមាជិកសរុបចំនួន ២៣ ជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងត្រូវបានដាក់ឱ្យដំណើរការផ្លូវការកាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ដែលមានសមាជិកស្ថាបនិកចំនួន ១៤ កំពុងធ្វើប្រតិបត្តិការ។ ចំណែកឯ ប្រព័ន្ធ QPS និង MPS មិនទាន់ដំណើរការនៅឡើយ។ ប្រព័ន្ធរីថែលផេបានដំណើរការទូទាត់ចំនួន ២៤២ថ្ងៃ។ ប្រតិបត្តិការទូទាត់តាមប្រព័ន្ធ RFT ជាប្រាក់រៀលមានការកើនឡើងទាំងចំនួនប្រតិបត្តិការនិងទឹកប្រាក់ ដោយមាន ៣២,១ ពាន់ប្រតិបត្តិការ (កើន ២,៦ ដង) និង ៣៥៦,៩ ប៊ីលានរៀល (កើន ៧,២ ដង) រៀងគ្នា បើធៀបនឹងឆ្នាំមុន។ បន្ថែមពីនេះ ការទូទាត់លើប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកទាំងចំនួនប្រតិបត្តិការនិងទឹកប្រាក់កើនឡើង ៦១,៣ ពាន់ប្រតិបត្តិការ (កើន ៣ដង) និង ១៨៦,១ លានដុល្លារអាមេរិក (កើន ២,២ដង) រៀងគ្នា។

**ង- ប្រព័ន្ធបាគង៖** ចាប់តាំងពីត្រូវបានដាក់ឱ្យដំណើរការ ប្រព័ន្ធបាគងមានគ្រឹះស្ថានជាសមាជិកសរុបចំនួន ៥៥ ដោយក្នុងនោះមានគ្រឹះស្ថានចំនួន ២៧ បានដាក់ឱ្យដំណើរការជាផ្លូវការ និងគ្រឹះស្ថានចំនួន ២៨ ផ្សេងទៀតកំពុងរៀបចំសិក្សា និងធ្វើសន្ទានកម្មតភ្ជាប់ប្រព័ន្ធ។ប្រព័ន្ធបាគងមានអតិថិជនចុះឈ្មោះប្រើប្រាស់តាមរយៈកម្មវិធីបាគងមានចំនួន ២៥៤ ពាន់គណនី។ ដោយឡែក នៅក្នុងឆ្នាំ២០២១ ប្រតិបត្តិការធ្វើឡើងតាមប្រព័ន្ធបាគងមានចំនួនសរុប ៥,៧ លានប្រតិបត្តិការ (១,២ លានប្រតិបត្តិការជាប្រាក់រៀល និង ៤,៥ លានប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិក) និងទំហំសាច់ប្រាក់ប្រតិបត្តិការជាប្រាក់រៀលចំនួន ១,៧ ទ្រីលានរៀល និងជាប្រាក់ដុល្លារអាមេរិកចំនួន ១,៩ ប៊ីលានដុល្លារអាមេរិក។

### ៤- សេវាគ្រប់គ្រងគណនី

#### ក- ចំនួនគណនី

ធនាគារជាតិនៃកម្ពុជាបានគ្រប់គ្រងគណនីសរុបចំនួន ២.០៧៣ គណនី ដែលក្នុងនោះមានស្ថាប័នរដ្ឋចំនួន ៩៧៧ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ១.០៥៤ និងអង្គភាពផ្សេងៗ (ដូចជាធនាគារកណ្តាលបរទេស គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិសាធារណៈ និងមន្ទីរសាការី) ចំនួន ៤២។ បើធៀបនឹងឆ្នាំមុន ការបើកគណនីរបស់ស្ថាប័នខាងលើបានកើន ៦,១% (១១៩ គណនី) ដែលបណ្តាលមកពីការកើនឡើងនៃគណនីថ្មីៗ រួមមាន៖ i/-ស្ថាប័នរដ្ឋ ២៨ គណនី សម្រាប់អនុវត្តគម្រោងជាមួយដៃគូអភិវឌ្ឍន៍ និងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុក្នុងការទទួលថវិកាផ្ទាល់ពីអគ្គនាយកដ្ឋានរតនាគារជាតិ និង ii/-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៨៧ គណនី។




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

#### ខ- ការរួមចំណែកអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្នុងគោលដៅរួមចំណែកអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលក្នុងដំណាក់កាលទី៣ (+២) (២០២១-២០២២) ដែលជាដំណាក់កាល "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ធនាគារជាតិនៃកម្ពុជាបានបន្តគាំទ្រ និងសហការអនុវត្តន៍ តាមរយៈការដាក់ឱ្យប្រើប្រាស់សេវាប្រព័ន្ធ OBS ដែលបានធ្វើសន្ធានកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។

#### គ-សេវាទទួលប្រាក់បញ្ញើ

ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថាប័នរដ្ឋ និងអង្គភាពផ្សេងៗនៅធនាគារជាតិនៃកម្ពុជាមានការថយចុះធៀបនឹងឆ្នាំ២០២០ ក្នុងនោះប្រាក់បញ្ញើជាប្រាក់រៀលបានថយចុះចំនួន ៤,៧ ទ្រីលានរៀល (ថយ -៣០%) ស្របពេលដែលប្រាក់ដុល្លារអាមេរិកក៏មានការថយចុះដល់ ៦២១,១ លានដុល្លារអាមេរិក (ថយ -៤,៩%)។

**ក្រាហ្វ ៦៤៖ប្រាក់បញ្ញើជាដុល្លារអាមេរិកនៅធនាគារជាតិនៃកម្ពុជា**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៧ - ២០២១)




**ក្រាហ្វ ៦៥ ៖ ប្រាក់បញ្ញើជារៀលនៅធនាគារជាតិនៃកម្ពុជា**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៧ - ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៥- ការគ្រប់គ្រងចរាចរណ៍ធនបត្រ

### ក- សកម្មភាពបេឡាប្រតិបត្តិការ

ប្រតិបត្តិការទទួលនិងបើកប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា ជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងស្ថាប័នរដ្ឋបានកើនឡើង ១៨,៦% និង ១១,១% រៀងគ្នា។ ចំណែកឯការទទួលប្រាក់ដុល្លារអាមេរិកបានកើនឡើង ៤,២% ខណៈដែលការបើកប្រាក់ដុល្លារអាមេរិកបានថយចុះ -៣៧,២% ធៀបនឹងឆ្នាំ២០២០។

**ក្រាហ្វ ៦៦ ៖ ការទទួលនិងបើកប្រាក់រៀល**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៧ - ២០២១ប)




**ក្រាហ្វ ៦៧ ៖ ការទទួលនិងបើកប្រាក់ដុល្លារអាមេរិក**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៧ - ២០២១ប)




ប្រភព៖ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

### ខ- ការងារគ្រប់គ្រងសាច់ប្រាក់

ការផ្គត់ផ្គង់ក្រដាសប្រាក់ថ្មីគ្រប់ប្រភេទនិងការប្រមូលក្រដាសប្រាក់ចាស់ ទក់ រហែកត្រូវបានអនុវត្តជាប្រចាំ ដើម្បីបំពេញតម្រូវការសាធារណជន ស្របពេលដែលការពង្រឹងសោភ័ណភាពនិងគុណភាពក្រដាសប្រាក់ត្រូវបានបន្តយកចិត្តទុកដាក់ដើម្បីទប់ស្កាត់ការក្លែងបន្លំក្រដាសប្រាក់ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។

ការផ្គត់ផ្គង់ប្រាក់រៀលពីស្នាក់ការកណ្ដាលទៅឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត បានកើនឡើង ២៦,៤% ខណៈប្រាក់ដុល្លារអាមេរិកបានថយចុះ -១៥,៥%។ ចំណែកឯការដឹកជញ្ជូនប្រាក់រៀលចាស់និងលើសតម្រូវការមកស្នាក់ការកណ្ដាលវិញកើនឡើង ៣៨% រីឯប្រាក់ដុល្លារអាមេរិកបានថយចុះ -១៥,៧% ធៀបនឹងឆ្នាំមុន។

**ក្រាហ្វ ៦៨ ៖ ប្រាក់រៀលដឹកទៅ-មកសាខាធនាគារជាតិនៃកម្ពុជា**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៧ - ២០២១ប)




**ក្រាហ្វ ៦៩ ៖ ប្រាក់ដុល្លារអាមេរិកដឹកទៅ-មកសាខាធនាគារជាតិនៃកម្ពុជា**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៧ - ២០២១ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

ក្រោមកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការដកហូតក្រដាសប្រាក់ក្លែងក្លាយជារៀល (ប្រភេទចតចម្លង) និងជាប្រាក់ដុល្លារអាមេរិកបានថយចុះ -២៧,៨% និង -៧៣,៥% រៀងគ្នា ធៀបនឹងឆ្នាំ២០២០។ ដើម្បីអបអរសាទរខួប ៣០ឆ្នាំនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស (២៣ តុលា ១៩៩១ - ២៣ តុលា ២០២១) និងខួប ៣០ឆ្នាំនៃការយាងនិវត្តន៍របស់ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ" មកកាន់មាតុភូមិវិញ (១៤ វិច្ឆិកា ១៩៩១ - ១៤ វិច្ឆិកា ២០២១) រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាចេញផ្សាយធនបត្រអនុស្សាវរីយ៍ប្រភេទ ៣០.០០០រៀល ដើម្បីដាក់ឱ្យចរាចរ និងប្រើប្រាស់ទូទាំងព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១។

## VI- ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) អនុវត្តការងារជាប្រចាំ ដែលរួមមាន ការតាមដានការអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ ការវិភាគ ការរៀបចំនិងការបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុ និងការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង។ ជាមួយគ្នានេះដែរ ស.ហ.ក ក៏បាននិងកំពុងចូលរួមនិងសម្របសម្រួលការអនុវត្តផែនការសកម្មភាពរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ការងាររបស់ក្រុមអ៊ិកម៉ុង (Egmont Group) និងការវាយតម្លៃហានិភ័យថ្នាក់ជាតិ ព្រមទាំងការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ។

### ១- ការពង្រឹងក្របខ័ណ្ឌនិងការអនុវត្តច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ស.ហ.ក បានចេញសេចក្តីណែនាំស្តីពី វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ស្របតាមគោលការណ៍នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលតម្រូវឱ្យបុគ្គលរាយការណ៍អនុវត្តកាតព្វកិច្ចសំខាន់ៗ ដូចជា វិធីសាស្ត្រផ្អែកលើហានិភ័យ តាមដានជាប្រចាំនិងពិនិត្យឡើងវិញនៃវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ការរក្សាទុកកំណត់ត្រា និងការផ្តល់ព័ត៌មានមក ស.ហ.ក។

ស.ហ.ក បានបន្តការត្រួតពិនិត្យដល់ទីកន្លែង ចំពោះធនាគារពាណិជ្ជចំនួន ៨ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ២ ក្នុងអំឡុងពេលនៃការរាលដាលនៃជំងឺកូវីដ-១៩ នាឆ្នាំនេះ។ ទន្ទឹមនេះ ស.ហ.ក ក៏បានពង្រឹងការតាមដានជាប្រចាំ ផ្អែកលើលទ្ធផលនៃការវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ និងតាមដានអំពីលទ្ធផលការងារត្រួតពិនិត្យផ្ទៃក្នុង សវនកម្មផ្ទៃក្នុង និងការវាយតម្លៃគុណវុឌ្ឍិនិងបទពិសោធន៍របស់មន្ត្រីប្រតិបត្តិតាមរយៈប្រព័ន្ធអនឡាញ។

ស.ហ.ក បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយសេចក្តីណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន តាមរយៈប្រព័ន្ធអនឡាញ ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៥៦ ដែលមានអ្នកចូលរួមសរុបចំនួន ៦៨រូប។ ស.ហ.ក ក៏បានសហការជាមួយធនាគារពិភពលោករៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមរយៈប្រព័ន្ធអនឡាញចំនួន ៥លើក រួមមាន៖ i/-២លើក សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ១៥៦ រួមមាន ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងអាជីវកម្មប្តូរប្រាក់ ដែលមានអ្នកចូលរួមសរុបចំនួន ៧២០រូប ii/-២លើក សម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ និងមុខរបរវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុចំនួន ៣០គ្រឹះស្ថាន រួមមាន ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបរធនបាលកិច្ច ក្រុមហ៊ុនគណនេយ្យនិងសវនកម្ម ក្រុមហ៊ុនកាស៊ីណូ ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋាន ការិយាល័យមេធាវី ដែលមានអ្នកចូលរួមសរុបប្រមាណ ៨១រូប និង iii/-១លើក ជូនក្រសួង-ស្ថាប័នត្រួតពិនិត្យមានដូចជា និយ័តករនានានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកដ្ឋានត្រួតពិនិត្យ និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានអ្នកចូលរួមសរុបចំនួន ៦១រូប។

មន្ត្រីបុគ្គលិក ស.ហ.ក បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាពាក់ព័ន្ធនឹងប្រធានបទសំខាន់ៗ តាមរយៈប្រព័ន្ធអនឡាញ ដូចជា៖ បទល្មើសបច្ចេកវិទ្យាវគ្គទី១ ការស៊ើបអង្កេតអំពើពុករលួយនៅតំបន់អាស៊ីអាគ្នេយ៍ ការបណ្តុះបណ្តាលអ្នកវាយតម្លៃអញ្ញមញ្ញរបស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ និងទ្រព្យសកម្មនិម្មិត និងអ្នកផ្តល់សេវាកម្មទ្រព្យសកម្មនិម្មិត ជាដើម។ ស.ហ.ក ក៏បានចូលរួមសិក្ខាសាលា និងផ្តល់បទឧទ្ទេសនាមជូនមន្ត្រីនិងថ្នាក់ដឹកនាំ ក្រសួងមហាផ្ទៃ និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ពាក់ព័ន្ធច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ផងដែរ។

## ២- ការវិភាគប្រតិបត្តិការ

បន្ថែមពីលើការអនុវត្តការងារស្នូលក្នុងការទទួល និងវិភាគជាប្រចាំនូវប្រតិបត្តិការពីបុគ្គលរាយការណ៍ និងព័ត៌មានផ្សេងៗទៀត ស.ហ.ក សហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យា ក៏បានភ្ជាប់ប្រព័ន្ធរាយការណ៍តាមប្រព័ន្ធអនឡាញ (Web-Based Reporting) ឱ្យបុគ្គលរាយការណ៍ដែលទើបបង្កើតថ្មីចំនួន១២ ព្រមទាំងបានរៀបចំសិក្ខាសាលាចំនួន ២លើក ដល់បុគ្គលរាយការណ៍ឱ្យយកចិត្តទុកដាក់អនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ជាពិសេស ការប្រមូលព័ត៌មាន ការកំណត់ និងការរាយការណ៍ប្រតិបត្តិការឱ្យបានទាន់ពេលវេលា និងមានគុណភាពខ្ពស់មួយកម្រិតទៀត។ ស.ហ.ក ក៏បានសហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យា ដើម្បីរៀបចំបង្កើតប្រព័ន្ធផ្ទៃក្នុងមួយសម្រាប់សម្រួលការងារវិភាគប្រតិបត្តិការហិរញ្ញវត្ថុពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឱ្យកាន់តែល្អប្រសើរ។ ស.ហ.ក ក៏បានបន្តរៀបចំ និងបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុ ព្រមទាំងស្នើសុំព័ត៌មាន និងមតិឆ្លើយតប ដើម្បីកែលម្អរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុឱ្យបានកាន់តែមានគុណភាព។

## ៣- កិច្ចសហប្រតិបត្តិការរបស់ ស.ហ.ក

### ក- កិច្ចសហប្រតិបត្តិការក្នុងស្រុករបស់ ស.ហ.ក

ស.ហ.ក បានចុះអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ជាមួយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ទន្ទឹមនេះ ស.ហ.ក គ្រោងនឹងចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយអគ្គិសនីកម្ពុជា និងក្រសួង-ស្ថាប័នផ្សេងទៀតផងដែរ។ ស.ហ.ក បានចូលរួមការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនស្របតាមផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

ស.ហ.ក បានដឹកនាំនិងសម្របសម្រួលក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដើម្បីរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) និងផែនការសកម្មភាពនៃយុទ្ធសាស្ត្រជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣។ ជាមួយគ្នានេះ ស.ហ.ក រួមជាមួយក្រុមការងារបច្ចេកទេសអន្តរក្រសួង បានជួបប្រជុំតាមរយៈប្រព័ន្ធអនឡាញជាមួយក្រុមការងារត្រួតពិនិត្យរួមនៃប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (ICRG-JG) ចំនួន ៣លើក ដើម្បីពិភាក្សាអំពីលទ្ធផលនៃការអនុវត្តផែនការសកម្មភាពរបស់ FATF។ ទន្ទឹមនេះ គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និង ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.) ដែលមាន សម្តេចក្រឡាហោម ជាប្រធាន និង ឯកឧត្តម ទេសាភិបាល ជាអនុប្រធានប្រចាំការ បានចេញសេចក្តីសម្រេចបង្កើតអនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (អ.វ.ហ.)។ អនុគណៈកម្មាធិការនេះបាននិងកំពុងពិភាក្សា និងសម្របសម្រួលជាមួយធនាគារពិភពលោក ដើម្បីអនុវត្តការងារវាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី២ ដែលលទ្ធផលនៃការវាយតម្លៃនេះ នឹងឆ្លុះបញ្ចាំងពីហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់កម្ពុជា សម្រាប់រយៈពេល ៥ឆ្នាំម្តង បន្ទាប់ពីការវាយតម្លៃលើកទី១ ឆ្នាំ២០១៦។

## ខ- កិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ ស.ហ.ក

ស.ហ.ក បានចុះអនុស្សរណៈយោគយល់ស្ដីពីការផ្លាស់ប្ដូរព័ត៌មានពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុសេណេហ្គាល់ អេស្តូនី និងប្រេស៊ីល។ ទន្ទឹមនេះ ស.ហ.ក គ្រោងនឹងចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុហ្គាណា និងសហរដ្ឋអាមេរិក។

**ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្ដីពីការសម្អាតប្រាក់ (APG)** ៖ ក្នុងអំឡុងឆ្នាំ២០២១ នេះ ស.ហ.ក បានបន្តសហប្រតិបត្តិការជាមួយ APG លើការវាយតម្លៃវឌ្ឍនភាពលើការអនុវត្តអនុសាសន៍នៃការអនុលោមតាមផ្នែកបច្ចេកទេសក្នុងរបាយការណ៍វាយតម្លៃអញ្ញមញ្ញ ស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៧ ដោយទទួលបានការដំឡើងចំណាត់ថ្នាក់លើអនុសាសន៍ចំនួន ៦ គឺអនុសាសន៍ទី១ អនុសាសន៍ទី៧ អនុសាសន៍ទី១២ អនុសាសន៍ទី៣៣ អនុសាសន៍ទី៣៧ និង អនុសាសន៍ទី៣៨។ ទន្ទឹមនោះ ស.ហ.ក ក៏បានចូលរួមកិច្ចប្រជុំនានា របស់ APG ផងដែរ ពាក់ព័ន្ធនឹងការងារអភិបាលកិច្ច ការវាយតម្លៃអញ្ញមញ្ញ ការពិនិត្យឡើងវិញជាយុទ្ធសាស្ត្រលើស្តង់ដារបស់ FATF និងមហាសន្និបាតរបស់ APG និង FATF ជាដើម។ លើសពីនេះ មន្ត្រីជំនាញរបស់ ស.ហ.ក បានចូលរួមវគ្គបណ្ដុះបណ្ដាលនិងសិក្ខាសាលារបស់ APG តាមរយៈប្រព័ន្ធអនឡាញ ដើម្បីទទួលបានបទពិសោធន៍ និងឧត្តមានុវត្តល្អៗក្នុងការពង្រឹងវិធានការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**ក្រុមអ៊ិកម៉ុង (EGMONT Group)** ៖ ស.ហ.ក បានចូលរួមមហាសន្និបាតប្រចាំឆ្នាំលើកទី២៧ ដែលរៀបចំដោយលេខាធិការដ្ឋាន Egmont ក្រោមប្រធានបទ "ការអនុវត្តវិធីសាស្ត្រផ្អែកលើហានិភ័យនៃប្រតិបត្តិការរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ" ក្នុងគោលបំណងពិភាក្សា និងចែករំលែកបទពិសោធន៍ដល់សមាជិកក្រុម Egmont ពាក់ព័ន្ធនឹងការអនុវត្តវិធីសាស្ត្រផ្អែកលើហានិភ័យចំពោះការងារស្នូលរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ដូចជា ការរៀបចំនិងការវិភាគរបាយការណ៍ហិរញ្ញវត្ថុ និងការការពារសុវត្ថិភាពទិន្នន័យ។ ទន្ទឹមនេះ ស.ហ.ក ក៏បានចូលរួមកិច្ចប្រជុំក្រុមការងារ និងវគ្គបណ្ដុះបណ្ដាលបច្ចេកទេស ដើម្បីតាមដានពីវឌ្ឍនភាពនៃគម្រោងសិក្សាថ្មីៗ និងគម្រោងនានារបស់ក្រុម Egmont ដូចជា ការកែសម្រួលគោលនយោបាយនិងនីតិវិធី ការផ្លាស់ប្ដូរព័ត៌មាន ជំនួយបច្ចេកទេស និងការចូលជាសមាជិកក្រុមការងារផ្លាស់ប្ដូរព័ត៌មាន។

**ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ (Financial Intelligence Consultative Group-FICG)** ៖ សម្រាប់ក្របខ័ណ្ឌក្រុមការងារ FICG ដែលជាកិច្ចសហប្រតិបត្តិការរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុក្នុងតំបន់អាស៊ាន+អូស្ត្រាលីនិងនូវែលសេឡង់ ឆ្លើយតបនឹងបញ្ហានៃការផ្តល់ហិរញ្ញប្បទានភេរវកម្ម និងការគំរាមកំហែងលើវិស័យហិរញ្ញវត្ថុក្នុងតំបន់ ស.ហ.ក បានចូលរួមក្នុងគម្រោងសិក្សានានា ដូចជាការប្រឆាំងហិរញ្ញប្បទានភេរវកម្មក្នុងតំបន់អាស៊ីអាគ្នេយ៍ ការបង្កើតផ្លែតហ្វម (Platform) នៃការចែករំលែកព័ត៌មាន និងការប្រឆាំងការសម្អាតប្រាក់ ជាដើម។ ទន្ទឹមនេះ ស.ហ.ក ក៏បានចូលរួមកិច្ចប្រជុំក្រុមការងារជាប្រចាំ ដើម្បីពិនិត្យ តាមដាន និងចែករំលែកព័ត៌មានពីបច្ចុប្បន្នភាពការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដូចជា ច្បាប់និងបទប្បញ្ញត្តិថ្មីៗ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវថ្មីៗនៃការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ជាពិសេសយន្តការការងាររបស់សមាជិកនីមួយៗ ក្នុងស្ថានភាពនៃការរាលដាលនៃជំងឺកូវីដ-១៩ នាឆ្នាំនេះ។

VII- **កិច្ចសហប្រតិបត្តិការអន្តរជាតិ**

**១- កិច្ចសហប្រតិបត្តិការពហុភាគី**

ធនាគារជាតិនៃកម្ពុជា បានបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ ជាមួយស្ថាប័នអន្តរជាតិ និងធនាគារកណ្តាលនានា ដើម្បីចែករំលែកព័ត៌មាននិងចំណេះដឹង និងលើកកម្ពស់សមាហរណកម្ម ក្នុងតំបន់និងអន្តរជាតិ។

**មូលនិធិរូបិយវត្ថុអន្តរជាតិ** (IMF) បានបំពេញបេសកកម្មពិគ្រោះយោបល់មាត្រា IV ដើម្បីជួយតាមដានស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជានិងផ្តល់អនុសាសន៍លើគោលនយោបាយសេដ្ឋកិច្ច។ IMF បន្តផ្តល់ជំនួយបច្ចេកទេសលើការពង្រឹងការចងក្រងស្ថិតិវិស័យក្រៅប្រទេស ស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុ សន្ទស្សន៍ថ្លៃលំនៅឋាន និងការពង្រឹងគុណភាពរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុ ជាពិសេសបានជួយបង្កើនសមត្ថភាពមន្ត្រីជំនាញលើការវិភាគតាមដាននិងវាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាមួយគ្នានេះ IMF បានដំឡើងប្រាក់វិភាជន៍ SDR ថ្មីដល់ប្រទេសជាសមាជិក ដើម្បីត្រៀមដោះស្រាយវិបត្តិនៃជំងឺកូវីដ-១៩ ក្នុងនោះកម្ពុជាក៏ទទួលបានវិភាជន៍ SDR ថ្មី ចំនួន ១៦៧,៧៣ លាន SDR ដែលធ្វើឱ្យចំនួនវិភាជន៍សរុបរបស់កម្ពុជាមានចំនួនប្រមាណ ២៥១ លាន SDR។

**ធនាគារអភិវឌ្ឍន៍អាស៊ី** (ADB) បានអនុម័តផ្តល់ឥណទានសម្បទានផ្អែកលើគោលនយោបាយក្រោមអនុកម្មវិធីទី៣នៃកម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន។ ADB បាននិងកំពុងពិភាក្សាជាមួយរាជរដ្ឋាភិបាល លើគោលនយោបាយសកម្មភាពសម្រាប់កម្មវិធីកម្ចីឥណទានសម្បទានថ្មីស្តីពី ភាពប្រកួតប្រជែងនិងពាណិជ្ជកម្ម ដែលចែកជា ២ អនុកម្មវិធី។ ADB បន្តសហការអនុវត្តកម្មវិធីឆ្លើយតបនឹងការរាលដាលនៃជំងឺកូវីដ-១៩ និងការស្តារសម្បទានសេដ្ឋកិច្ចឡើងវិញ ដែលផ្តោតលើផ្នែកគន្លឹះសំខាន់ៗ ៣ រួមមាន សុខាភិបាល កិច្ចគាំពារសង្គម និងការគាំទ្រដល់ការងើបឡើងវិញនៃសេដ្ឋកិច្ច សំដៅទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ-១៩ និងការស្តារវិស័យដែលទទួលរងផលប៉ះពាល់ខ្លាំងក្នុងសេដ្ឋកិច្ច។ ADB ក៏បានសហការរៀបចំសិក្ខាសាលាអំពីការដោះស្រាយឥណទានមិនដំណើរការ ការចែករំលែកព័ត៌មានស្តីពីការពិនិត្យឡើងវិញទៅលើគោលនយោបាយគាំពារសេដ្ឋកិច្ច និងផ្លែតហ្វមឌីជីថលនិងការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញក្រោយវិបត្តិកូវីដ-១៩ ក៏ដូចជាសិក្ខាសាលារួមជាមួយសាកលវិទ្យាល័យ Cambridge ស្តីពី បច្ចេកវិទ្យាហិរញ្ញវត្ថុ និងនវានុវត្តន៍បទប្បញ្ញត្តិ។

**កិច្ចសហប្រតិបត្តិការអាស៊ាន៖** ធនាគារជាតិនៃកម្ពុជាបានបន្តរួមចំណែកពង្រឹងសមាហរណកម្មហិរញ្ញវត្ថុនិងសហការសម្រេចការងារសំខាន់ៗក្នុងតំបន់អាស៊ាន រួមមាន៖ i/-ការចូលរួមគាំទ្រដល់ការបង្កើតក្រុមប្រឹក្សា Taxonomy ដែលមានតួនាទីរៀបចំ ជ្រើសរើស និងកែសម្រួលក្របខ័ណ្ឌនិងគោលការណ៍ពាក់ព័ន្ធនានា ក្នុងកិច្ចការកំណត់អត្តសញ្ញាណ និង/ឬនិយមន័យនៃហិរញ្ញវត្ថុបៃតង សំដៅសម្រេចបាននូវការអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយចីរភាព ii/-ធ្វើជាសហប្រធានជាមួយធនាគារកណ្តាលឥណ្ឌូណេស៊ីលើគណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុ ដោយបានជួយជំរុញបរិយាបន្នក្នុងតំបន់អាស៊ាន និង iii/-ចូលរួមជំរុញការធ្វើសមាហរណកម្មវិស័យធនាគារ សេរីភាវូបនីយកម្មគណនីមូលធន ការអភិវឌ្ឍទីផ្សារទុន បរិយាបន្នហិរញ្ញវត្ថុ សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ និងការកសាងសមត្ថភាពរបស់មន្ត្រីធនាគារកណ្តាលក្នុងតំបន់អាស៊ាន។

**កិច្ចសហប្រតិបត្តិការអាស៊ាន+៣៖** ធនាគារជាតិនៃកម្ពុជាបានរួមចំណែក៖ i/-ពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុក្នុងតំបន់អាស៊ាន+៣ ក្រោយពីការសម្រេចដំឡើងទំហំទឹកប្រាក់ CMIM ដែលមិនភ្ជាប់ជាមួយកម្មវិធីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិពី ៣០% ទៅ ៤០% ជាមួយនឹងចំនួនទឹកប្រាក់ CMIM សរុប ២៤០ ប៊ីលានដុល្លារអាមេរិក និង ii/-បានចូលរួមពិភាក្សាលើយន្តការកំណត់អត្រាការប្រាក់យោង និងការប្រើរូបិយវត្ថុជាតិក្នុងយន្តការ CMIM ផងដែរ។ ធនាគារជាតិនៃកម្ពុជាក៏បានគាំទ្រដល់ការពង្រឹងតួនាទីរបស់ AMRO ក្នុងនាមស្ថាប័នអន្តរជាតិ ជាពិសេសការវាយតម្លៃស្ថានភាពសេដ្ឋកិច្ចរបស់សមាជិកអាស៊ាន+៣។

**មជ្ឈមណ្ឌលស៊ាសិន (SEACEN)** បានចូលរួមបណ្តុះបណ្តាលសមត្ថភាពជំនាញរបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា តាមរយៈវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា តាមប្រព័ន្ធអនឡាញ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាសមាជិកនៃមូលនិធិបរធនបាលរបស់ស៊ាសិន (SEACEN Trust Fund) ក៏បានចូលរួមចំណែកក្នុងការអនុម័តលើការគ្រប់គ្រងនិងប្រើប្រាស់មូលនិធិនេះឱ្យមានប្រសិទ្ធភាពផងដែរ។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាមានកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័នអន្តរជាតិដ៏ទៃទៀត។ អង្គការយូអិនឌីភីប្រចាំនៅកម្ពុជា (UNDP Cambodia) បានសហការសិក្សាស្រាវជ្រាវលើលទ្ធផលនៃការបោះមូលបត្ររដ្ឋជាប្រាក់រៀល ក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពី ការអភិវឌ្ឍមូលបត្ររដ្ឋ ២០២២-២០២៨។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានសហការលើការអភិវឌ្ឍទីផ្សារខ្សែច្រវាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុនៅកម្ពុជា និងការរៀបចំសិក្ខាសាលាតាមរយៈប្រព័ន្ធអនឡាញ ស្តីពីការរៀបចំឧបករណ៍ហិរញ្ញវត្ថុស្វប់រូបិយប័ណ្ណ (Foreign Currency SWAP)។ សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ (AFI) បានសហការជំរុញកម្រិតបរិយាបន្នហិរញ្ញវត្ថុ និងលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុ ដោយផ្តោតលើការលើកកម្ពស់ចំណេះដឹងសេវាហិរញ្ញវត្ថុឌីជីថល ការប្រមូលទិន្នន័យបរិយាបន្នហិរញ្ញវត្ថុតាមភេទ និងការផ្តល់ហិរញ្ញប្បទានប្រកបដោយបរិយាបន្ន យេនឌ័រ និងបៃតង។ អង្គការ PACT Cambodia បានសហការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ តាមរយៈការរៀបចំវីដេអូអប់រំចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងមគ្គុទ្ទេសក៍ហិរញ្ញវត្ថុ។ សមាគមឥណទានកសិកម្ម និងជនបទសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក (APRACA) បានសហការបណ្តុះបណ្តាលនិងការស្រាវជ្រាវពាក់ព័ន្ធនឹងហិរញ្ញប្បទានបៃតង និងបម្រែបម្រួលអាកាសធាតុ។

**ប្រអប់ ១ ៖ កិច្ចសហប្រតិបត្តិការអាស៊ាននិងអាស៊ាន+៣**

ក្រោមកិច្ចសហប្រតិបត្តិការអាស៊ានធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងការងារចម្បងរួមមានដូចជា ៖

i/-សមាហរណកម្មវិស័យធនាគារអាស៊ាន ABIF៖ គណៈកម្មាធិការក្របខ័ណ្ឌសមាហរណកម្មវិស័យធនាគារអាស៊ាន (WC-ABIF) បានបង្កើតការរៀបចំការងារ (ABIF arrangement) និងកិច្ចព្រមព្រៀងត្រួតពិនិត្យ (Supervisory Agreement) សិក្សាពីបរិបទហិរញ្ញវត្ថុ (Financial Landscape) នាពេលបច្ចុប្បន្ននិងពេលអនាគត សម្រាប់ពង្រឹងសមាហរណកម្មធនាគារក្នុងតំបន់ ពាក់ព័ន្ធនឹងប្រតិបត្តិការឌីជីថល ចែករំលែកបទពិសោធន៍ស្តីពីការគ្រប់គ្រងលំហូរទិន្នន័យឆ្លងប្រទេស និងរៀបចំកម្មវិធីពង្រឹងសមត្ថភាពដើម្បីពង្រឹងភាពស៊ីគ្នានៃបទប្បញ្ញត្តិរបស់ធនាគារក្នុងបណ្តាប្រទេសសមាជិកអាស៊ាន។

ii/-សេរីភាវូបនីយកម្មគណនីមូលធន៖ គណៈកម្មាធិការសេរីភាវូបនីយកម្មគណនីមូលធន (WC-CAL) បានធ្វើបច្ចុប្បន្នកម្មផែនការការងារនៃការធ្វើសេរីភាវូបនីយកម្មគណនីមូលធន លើកកម្ពស់កិច្ចពិភាក្សាគោលនយោបាយជាពិសេសការសិក្សាពីបទពិសោធន៍នៃការគ្រប់គ្រងលំហូរមូលធនរបស់ប្រទេសសមាជិក ធ្វើឱ្យប្រសើរឡើងនូវផែនទីវាយតម្លៃសេរីភាវូបនីយកម្មគណនីមូលធន និងដាក់របាយការណ៍និងឯកសារពាក់ព័ន្ធនឹងក្រុមការងារទៅក្នុងគេហទំព័រអាស៊ានដើម្បីផ្សព្វផ្សាយ និងចែករំលែកសម្រាប់សមាជិក។

iii/-ការអភិវឌ្ឍទីផ្សារទុន៖ គណៈកម្មាធិការអភិវឌ្ឍទីផ្សារទុន (WC-CMD) បានបង្កើតក្របខ័ណ្ឌពិគ្រោះដើម្បីចូលរួមជំរុញការអភិវឌ្ឍនិងលើកកម្ពស់ហិរញ្ញប្បទានប្រកបដោយចីរភាពក្នុងតំបន់ បង្កើតក្រុមប្រឹក្សាឧស្សាហកម្ម (Industry Advisory Panel-IAP) សម្រាប់កិច្ចប្រជុំរួមរវាងក្រុមការងារហិរញ្ញប្បទានប្រកបដោយចីរភាព និងរៀបចំកម្មវិធីកសាងសមត្ថភាពនិងលើកកម្ពស់ចំណេះដឹងទាក់ទិននឹងហិរញ្ញប្បទានប្រកបដោយចីរភាព។

iv/-បរិយាបន្នហិរញ្ញវត្ថុ៖ គណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុ (WC-FINC) បានរៀបចំការវាយតម្លៃខ្លួនឯងលើការអនុវត្តតាមឯកសារណែនាំស្តីពីក្របខ័ណ្ឌតាមដាននិងវាយតម្លៃលើបរិយាបន្នហិរញ្ញវត្ថុ រៀបចំរបាយការណ៍បរិយាបន្នហិរញ្ញវត្ថុក្នុងតំបន់អាស៊ានឆ្នាំ២០២១ ធ្វើបច្ចុប្បន្នកម្មលើឯកសារនិងសហការរៀបចំកម្មវិធីបណ្តុះបណ្តាលពាក់ព័ន្ធនឹងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ចែករំលែកចំណេះដឹងនិងគំនិតផ្តួចផ្តើមនានាទាក់ទងនឹងសេវាហិរញ្ញវត្ថុតាមរយៈប្រព័ន្ធឌីជីថល និងសហការរៀបចំឯកសារគោលនយោបាយស្តីពីចំណេះដឹងផ្នែកហិរញ្ញវត្ថុតាមរយៈប្រព័ន្ធឌីជីថល។

v/-សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ៖ គណៈកម្មាធិការសេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (WC-FSL) បានអភិវឌ្ឍផែនការការងារក្នុងការប្តូរពីបញ្ជីវិជ្ជមានទៅបញ្ជីអវិជ្ជមានដើម្បីពង្រីកវិសាលភាពនៃការធ្វើសេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ និងបង្កើតគោលការណ៍ណែនាំទៅលើការត្រួតពិនិត្យកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ បញ្ចប់ការពិភាក្សាលើពិធីសារសម្រាប់សេវាហិរញ្ញវត្ថុកញ្ចប់ទី៩និងត្រៀមចុះហត្ថលេខានៅចុងឆ្នាំ២០២១នេះ និង

បញ្ចប់ការពិភាក្សាលើទស្សនទានស្តីពី ការសិក្សាលើផលប៉ះពាល់នៃការធ្វើសេរីភាវូបនីយកម្ម ចំពោះប្រទេសជាសមាជិក។

vi/-ប្រព័ន្ធទូទាត់៖ គណៈកម្មាធិការប្រព័ន្ធទូទាត់ (WC-PSS) បានកំណត់និងផ្តល់អាទិភាព លើផ្នែកពាក់ព័ន្ធនឹងអាស៊ានចំពោះរបាយការណ៍ស្តីពី ការលើកកម្ពស់ការទូទាត់សងប្រាក់ឆ្លងដែន ការធ្វើបច្ចុប្បន្នកម្មលើគោលការណ៍ណែនាំស្តីពីការអនុវត្តក្របខ័ណ្ឌគោលនយោបាយភ្ជាប់ប្រព័ន្ធ ទូទាត់រាយភ្លាមៗឆ្លងដែន និងអនុម័តក្របខ័ណ្ឌអន្តរប្រតិបត្តិការ QR កូដ អាស៊ានដើម្បីជំរុញការភ្ជាប់ ប្រព័ន្ធទូទាត់ក្នុងតំបន់ និង vii/-ការកសាងសមត្ថភាព៖ គណៈកម្មាធិការកសាងសមត្ថភាព (SCCB) បានបន្តរៀបចំវគ្គបណ្តុះបណ្តាលតាមរយៈប្រព័ន្ធអនឡាញ ហើយប្រទេសសមាជិកកំពុងរៀបចំ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាសម្រាប់ការងារបណ្តុះបណ្តាលផងដែរ។

ក្រោមកិច្ចសហប្រតិបត្តិការអាស៊ាន+៣ លទ្ធផលការងារចម្បងៗដែលសម្រេចបាន រួមមាន៖

i/-ការកែសម្រួលគោលការណ៍ប្រតិបត្តិនៃកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើម ឈៀងម៉ៃ (CMIM) ដើម្បីឱ្យការអនុវត្តកិច្ចព្រមព្រៀងនេះប្រកបដោយពិលាស ស្របទៅតាម ការវិវត្តថ្មីៗ ដូចជា ការកំណត់អត្រាការប្រាក់យោង (Reference Rate) ការប្រើប្រាស់រូបិយវត្ថុក្នុង ស្រុកក្នុងយន្តការ CMIM និងការកំណត់ទិសដៅអនាគត

ii/-ការអនុវត្តសាកល្បង (Test Run) លើកទី១២ ក្រោមយន្តការ CMIM ដែលមិនពាក់ព័ន្ធនឹង IMF ដើម្បីពង្រឹងការវាយតម្លៃស្ថានភាពសេដ្ឋកិច្ចប្រទេសសុំខ្ចី

iii/-ការបង្កើតកម្មវិធីជំនួយបច្ចេកទេសដើម្បីពង្រីកចំណេះដឹងលើដំណើរការនៃកិច្ចព្រម-ព្រៀង CMIM

iv/-ការកំណត់កម្មវិធីការងារ ការកែសម្រួលផែនការរយៈពេលមធ្យម និងការត្រៀមរៀបចំ ជ្រើសរើសថ្នាក់ដឹកនាំថ្មីសម្រាប់អង្គភាព AMRO

v/-ការបន្តសិក្សាពីគំនិតផ្តួចផ្តើមថ្មីៗដើម្បីពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ អាស៊ាន+៣ និង

vi/-ការជំរុញការចេញផ្សាយសញ្ញាប័ណ្ណក្នុងតំបន់អាស៊ាន+៣ ជារូបិយវត្ថុក្នុងស្រុក។

### ២- កិច្ចសហប្រតិបត្តិការទ្វេភាគី

កិច្ចសហប្រតិបត្តិការទ្វេភាគីត្រូវបានពង្រឹងនិងពង្រីក ដើម្បីចែករំលែកចំណេះដឹងនិង បទពិសោធន៍ និងគាំទ្រការរីកចម្រើននៃវិស័យធនាគារ។ កិច្ចប្រជុំទ្វេភាគីដូចជា ជាមួយធនាគាររដ្ឋ វៀតណាមនិងធនាគារកណ្តាលឡាវ ត្រូវបានរៀបចំឡើង ដើម្បីបន្តពង្រឹងកិច្ចសហប្រតិបត្តិការជា ប្រពៃណី និងកំណត់ទិសដៅនៃកិច្ចសហប្រតិបត្តិការនាពេលអនាគត។ ធនាគារកណ្តាលថៃបាន ចែករំលែកបទពិសោធន៍ លើការគ្រប់គ្រងការប្តូរប្រាក់ និងការគ្រប់គ្រងប្រតិបត្តិការរបស់ធនាគារ កណ្តាលផងដែរ។ ធនាគារកណ្តាលកូរ៉េបានសហការស្រាវជ្រាវលើប្រធានបទស្តីពី "ប្រតិបត្តិការ រូបិយវត្ថុនិងគោលនយោបាយប្តូរប្រាក់"។ អាជ្ញាធររូបិយវត្ថុសិង្ហបុរី និងធនាគារកណ្តាលប្រទេស មួយចំនួនទៀត បានសហការចេញផ្សាយជាផ្លូវការនូវឯកសារសិក្សាស្រាវជ្រាវស្តីពី "ហេដ្ឋារចនា-សម្ព័ន្ធឌីជីថលគ្រឹះសម្រាប់សេដ្ឋកិច្ចឌីជីថលប្រកបដោយបរិយាបន្ន"។ ទន្ទឹមនេះ ធនាគារជាតិនៃ

កម្ពុជាក៏បានចែករំលែកចំណេះដឹងនិងបទពិសោធន៍ដល់ i/-ធនាគារកណ្តាលឡាវលើប្រធានបទស្តីពីការអភិវឌ្ឍប្រព័ន្ធទូទាត់ ការពង្រឹងការត្រួតពិនិត្យធនាគារ និងការរៀបចំប្រព័ន្ធគណនេយ្យ និង ii/-ធនាគារកណ្តាលទីម័រលេសលើប្រធានបទស្តីពី ដំណើរការចុះកិច្ចបញ្ជិកា និងការចេញផ្សាយមូលបត្រអាចជួញដូរបាន (NCD) និង iii/-ធនាគារកណ្តាលប៉ាគីស្ថានលើប្រធានបទស្តីពី ការអភិវឌ្ឍប្រព័ន្ធបាគង។

## VIII- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ន ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| - | ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| - | លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិកា |
| - | ឯកឧត្តម ជូ គឹមឡេង | តំណាងប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| - | ឯកឧត្តម អ៊ុំ ចុង | តំណាងឱ្យមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| - | ឯកឧត្តម រស់ សីលវ៉ា | តំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - | ឯកឧត្តម ឡាយ ម៉េងស៊ុន | តំណាងឱ្យមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក និង |
| - | លោក មុំ ដារ៉េត | តំណាងឱ្យបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិក។ |

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាបានជួបប្រជុំចំនួន ៦ លើក គឺកិច្ចប្រជុំក្រុមប្រឹក្សាភិបាលៈ

- លើកទី១ៈ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៤៤ កាលពីថ្ងៃចន្ទ ១២កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជា សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០២០។

- លើកទី២ៈ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៤៥ កាលពីថ្ងៃព្រហស្បតិ៍ ១៤រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជាឆ្នាំ២០២០ និងផែនការឆ្នាំ២០២១។

- លើកទី៣ៈ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៤៦ កាលពីថ្ងៃព្រហស្បតិ៍ ៦រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងគោលនយោបាយវិនិយោគសម្រាប់ការគ្រប់គ្រងទុនបម្រុងវិនិយោគ។

- លើកទី៤ៈ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៤៧ កាលពីថ្ងៃអង្គារ ៧កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ ដើម្បីពិនិត្យ និងអនុម័តលើរបាយការណ៍ស្តីពីសកម្មភាពការងារគ្រប់គ្រងទុនបម្រុងវិនិយោគឆ្នាំ២០២០។

- លើកទី៥ៈ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៤៨ កាលពីថ្ងៃព្រហស្បតិ៍ ១៤រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ និង

- លើកទី៦៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៤៩ កាលពីថ្ងៃអង្គារ ១០កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ដើម្បីពិនិត្យ និងអនុម័តលើសេចក្ដីព្រាង របាយការណ៍ប្រចាំឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២។

## ២- ការអភិវឌ្ឍធនធានមនុស្ស

### ក- ស្ថិតិមន្ត្រីបុគ្គលិក

មន្ត្រីបុគ្គលិកក្របខ័ណ្ឌទូទាំងប្រទេសរបស់ធនាគារជាតិនៃកម្ពុជាមានចំនួន ១.៧៧៦ រូប (ប្រុស ៩១៧ រូប ស្រី ៨៥៩ រូប) ក្នុងនោះទីស្នាក់ការកណ្ដាលមានចំនួន ១.២៩៥ រូប (ប្រុស ៦៨៦ រូប ស្រី ៦០៩ រូប) និងសាខារាជធានី-ខេត្តមានចំនួន ៤៨១ រូប (ប្រុស ២៣១ រូប ស្រី ២៥០ រូប)។ មន្ត្រីបុគ្គលិកក្របខ័ណ្ឌនៅទីស្នាក់ការកណ្ដាលកើនឡើងចំនួន ៤៣ រូប (ជ្រើសរើសថ្មី ៥១ រូប ផ្ទេរចូល ៣ រូប ផ្ទេរចេញ ១ រូប ចូលនិវត្តន៍ ៤ រូប លាឈប់ ៤ រូប មរណភាព ២ រូប) ខណៈនៅសាខា ថយចុះចំនួន ៩ រូប (ផ្ទេរចេញ ៣ រូប ចូលនិវត្តន៍ ២ រូប លាឈប់ ៣ រូប មរណភាព ១ រូប)។

**តារាង ២ ៖ ស្ថិតិមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ប្រចាំឆ្នាំ២០២១**

| | | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ប្រែប្រួល |
|---|---|---|---|---|---|---|
| **ទីស្នាក់ការកណ្ដាល** | ប្រុស | ៦៤២ | ៦៤២ | ៦៦៤ | ៦៨៦ | ២២ |
| | ស្រី | ៥៥០ | ៥៦៦ | ៥៨៨ | ៦០៩ | ២១ |
| | សរុប | **១១៩២** | **១២០៨** | **១២៥២** | **១២៩៥** | **៤៣** |
| **សាខា** | ប្រុស | ២៣២ | ២២៤ | ២៣៣ | ២៣១ | -២ |
| | ស្រី | ២៤១ | ២៣៣ | ២៥៧ | ២៥០ | -៧ |
| | សរុប | **៤៧៣** | **៤៥៧** | **៤៩០** | **៤៨១** | **-៩** |
| **សរុបទូទាំងប្រទេស** | ប្រុស | ៨៧៤ | ៨៦៦ | ៨៩៧ | ៩១៧ | ២០ |
| | ស្រី | ៧៩១ | ៧៩៩ | ៨៤៥ | ៨៥៩ | ១៤ |
| | សរុប | **១៦៦៥** | **១៦៦៥** | **១៧៤២** | **១៧៧៦** | **៣៤** |

### ខ- ការបណ្ដុះបណ្ដាល

**- ការបណ្ដុះបណ្ដាលក្នុងប្រទេស**

ការអភិវឌ្ឍសមត្ថភាពមន្ត្រីបុគ្គលិកត្រូវបានធ្វើឡើងតាមរយៈការបើកវគ្គបណ្ដុះបណ្ដាលនានា ជាពិសេសតាមរយៈប្រព័ន្ធអនឡាញ។ ការចូលរួមសិក្ខាសាលាចំនួន ៦ លើក ដោយមានសិក្ខាកាមចូលរួមចំនួន ៥០ រូប វគ្គសិក្សាចំនួន ២ លើក ដោយមានសិក្ខាកាមចូលរួមចំនួន ១៤០ រូប កិច្ចប្រជុំចំនួន ១៥ លើក ដែលមានមន្ត្រីបុគ្គលិកចូលរួមចំនួន ៣៤៥ រូប។ ទន្ទឹមនេះ កម្មវិធីកម្មសិក្សានៅធនាគារជាតិនៃកម្ពុជាក៏បានទទួលនិស្សិតមកពីបណ្ដាគ្រឹះស្ថានឧត្ដមសិក្សាចំនួន ១៥០ រូប។

ធនាគារជាតិនៃកម្ពុជាក៏បានបន្តបណ្តុះបណ្តាលជំនាញជូនមន្ត្រីបុគ្គលិកតាមរយៈប្រព័ន្ធអនឡាញ ដូចជាៈ

- កម្មវិធីបណ្តុះបណ្តាល NBC FSI Connect ជំនាញត្រួតពិនិត្យធនាគារ ក្រោមកម្មវិធីរបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុនៃធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) បានចំនួន ៥ ជំនាន់ មានសិក្ខាកាមសរុបចំនួន ៣៣៥ រូប (ក្នុងនោះអាហារូបករណ៍២៥រូប) និងបានរៀបចំឱ្យប្រឡងតាមរយៈប្រព័ន្ធអនឡាញជាផ្លូវការ ដើម្បីវាយតម្លៃគុណភាពសិក្សាជាបន្តបន្ទាប់ចំនួន ៣៩ លើក និងមានមន្ត្រីបុគ្គលិកបញ្ចប់ការសិក្សាកម្រិតបឋមចំនួន ២១៥ រូប កម្រិតមធ្យមចំនួន ១០៣ រូប និងកម្រិតខ្ពស់ចំនួន ៤៨ រូប។

- កម្មវិធីបណ្តុះបណ្តាល NBC-IMF ស្តីពីកម្មវិធីនិងគោលនយោបាយហិរញ្ញវត្ថុ (FPP) របស់មូលនិធិរូបិយវត្ថុអន្តរជាតិចំនួន៣ជំនាន់ មានសិក្ខាកាមសរុបចំនួន ២៦១ រូប ក្នុងនោះ មន្ត្រីបុគ្គលិកជំនាន់ទី១មានចំនួន ៥៥ រូប និងជំនាន់ទី២មានចំនួន ១០៥ រូប បានប្រឡងបញ្ចប់កម្មវិធីសិក្សាទាំងពីរកម្រិតតាមរយៈប្រព័ន្ធអនឡាញ ជាផ្លូវការដោយជោគជ័យ។ ម្យ៉ាងទៀត សិក្ខាកាមជំនាន់ទី៣មានចំនួន ១០១ រូប ដែលទើបជ្រើសរើស ត្រូវបានអនុញ្ញាតឱ្យសិក្សានិងត្រូវប្រឡងបញ្ចប់កម្រិត១ តាមរយៈប្រព័ន្ធអនឡាញ នៅចុងឆ្នាំ២០២១។

- កម្មវិធីសិក្សា Chartered Fintech Professional (CFtP) របស់វិទ្យាស្ថាន Global Fintech ដែលមាន២កម្រិត សម្រាប់សិក្ខាកាមចំនួន ៦ រូប ក្នុងគោលបំណងពង្រឹងសមត្ថភាព ផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ និងការវិវត្តថ្មីៗនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និង

- កម្មវិធីបណ្តុះបណ្តាល FSI Connect ជំនាញធានារ៉ាប់រងប្រាក់បញ្ញើ ដែលផ្តល់អាហារូបករណ៍ដោយសមាគមអន្តរជាតិសម្រាប់អង្គភាពការពារប្រាក់បញ្ញើ (IADI) ជូនមន្ត្រីបុគ្គលិកចំនួន ៣ រូប ដើម្បីពង្រឹងសមត្ថភាពផ្នែកកិច្ចការពារប្រាក់បញ្ញើ។

ដើម្បីបន្តនិរន្តរភាពនៃការសិក្សារបស់និស្សិត ក្នុងអំឡុងពេលនៃការរាលដាលជំងឺកូវីដ-១៩ មណ្ឌលសិក្សាបច្ចេកទេសធនាគារបានរៀបចំអភិវឌ្ឍវេទិកាឌីជីថលផ្លែតហ្វម និង hybrid education ក្នុងការបណ្តុះបណ្តាលជូននិស្សិតជំនាន់ទី២៨ និង២៩ តាមរយៈប្រព័ន្ធអេឡិចត្រូនិក (CBS E-Learning)។ សរុបនិស្សិតកំពុងសិក្សានៅមណ្ឌលសិក្សាបច្ចេកទេសធនាគារមានចំនួន២៧៧រូបដែលក្នុងនោះនិស្សិតជំនាន់ទី២៩ មាន ១៣៣ រូប និងជំនាន់ទី៣០ មាន ១៤៤ រូប។ បច្ចុប្បន្ន មណ្ឌលសិក្សាបច្ចេកទេសធនាគារមានសាស្ត្រាចារ្យចំនួន ៥៨ រូប (ស្រី ១១រូប) ក្នុងនោះសាស្ត្រាចារ្យក្នុងប្រព័ន្ធធនាគារជាតិនៃកម្ពុជាមានចំនួន៤៣រូប (ស្រី៦រូប)។

**- ការបណ្តុះបណ្តាលក្រៅប្រទេស**

ដើម្បីបន្តបង្កើនសមត្ថភាពនិងអភិវឌ្ឍធនធានមនុស្ស ធនាគារជាតិនៃកម្ពុជាបានចាត់មន្ត្រីបុគ្គលិកឱ្យចូលរួមវគ្គសិក្សាអនឡាញរយៈពេលខ្លី ចំនួន ២២៦ លើក (មន្ត្រីបុគ្គលិកចូលរួម ៨៤៣ រូប) និងកិច្ចប្រជុំអនឡាញចំនួន ១៥៥ លើក (មន្ត្រីបុគ្គលិកចូលរួម ៤១១ រូប) ព្រមទាំងចាត់បញ្ជូនចូលរួមវគ្គសិក្សារយៈពេលវែងថ្នាក់បណ្ឌិត ចំនួន ២ លើក (មន្ត្រីបុគ្គលិកចូលរួម ២ រូប) អនុបណ្ឌិត ចំនួន ២៦ លើក (មន្ត្រីបុគ្គលិកចូលរួម ២៧ រូប)។

## ៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការងារសវនកម្មនិងអធិការកិច្ចដែលជាផ្នែកមួយនៃអភិបាលកិច្ចរបស់ធនាគារជាតិនៃកម្ពុជាក្នុងការពិនិត្យ និងវាយតម្លៃទៅលើការអនុវត្តរបស់នាយកដ្ឋាន និងអង្គភាពនានា ចំពោះការប្រតិបត្តិតាម បទប្បញ្ញត្តិ សេចក្តីណែនាំ និងនីតិវិធីការងារផ្សេងៗ ដើម្បីធានានូវប្រសិទ្ធភាពការងារ និងភាពរឹងមាំ នៃការត្រួតពិនិត្យផ្ទៃក្នុង។

ការងារសវនកម្មត្រូវបានអនុវត្តទាំងដល់ទីកន្លែងផង និងតាមអនឡាញផង នៅសាខាធនាគារជាតិនៃកម្ពុជា (ខេត្តព្រះសីហនុ ព្រៃវែង ស្ទឹងត្រែង កំពង់ឆ្នាំង បាត់ដំបង កោះកុង និងរតនគិរី និងនៅស្នាក់ការកណ្តាលនាយកដ្ឋានប្រតិត្តិការ និងនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់)។ រីឯការងារអធិការកិច្ចបានអនុវត្តតែ៤សាខាប៉ុណ្ណោះ (សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពត កំពង់ចាម កំពង់ស្ពឺ និងតាកែវ)។ ដោយឡែក ការតាមដានការអនុវត្តតាមអនុសាសន៍ត្រូវបានអនុវត្តតាមអនឡាញទាំងអស់។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានសិក្សានិងរៀបចំនីតិវិធីសវនកម្មពីចម្ងាយ (Remote Audit) ដើម្បីរក្សានិរន្តភាពការងារសវនកម្មនៅក្នុងស្ថានភាពដែលសវនករមិនអាចទៅដល់ទីកន្លែងបានក៏ដូចជា ដើម្បីពង្រឹងប្រសិទ្ធភាពនៃការធ្វើសវនកម្ម។

គណៈកម្មការគ្រប់គ្រងហានិភ័យប្រព័ន្ធធនាគារស្នូលរបស់ធនាគារជាតិនៃកម្ពុជា បានប្រជុំចំនួន៥លើក ដើម្បីពិនិត្យលើវឌ្ឍនភាពនៃការធ្វើបច្ចុប្បន្នកម្ម ផែនការនិរន្តរភាពធុរកិច្ច (BCP) សម្រាប់ស្នាក់ការកណ្តាល និងការរៀបចំផែនការនិរន្តរភាពធុរកិច្ច សម្រាប់អនុវត្តនៅសាខាធនាគារជាតិនៃកម្ពុជា។

## ៤- ការគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា

ប្រតិបត្តិការនៅតាមសាខារាជធានី-ខេត្តត្រូវបានពង្រឹងជាលំដាប់ ដើម្បីបម្រើដល់ការរីកចម្រើននៅតាមតំបន់។ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តបានរួមចំណែកបំពេញសេចក្តីត្រូវការសាច់ប្រាក់, លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងបានលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ។ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តបានចូលរួម៖ i/-ផ្តល់សេវាប្តូរក្រដាសប្រាក់រៀលចាស់ សឹក រេច រិល ទក់ និងរហែក ជូនដល់សាធារណជន ii/-តាមដានស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់ដូចជាការប្រែប្រួលថ្លៃ អត្រាប្តូរប្រាក់ និងសូចនាករម៉ាក្រូសេដ្ឋកិច្ចដទៃទៀតដែលរួមចំណែកក្នុងការតាមដានស្ថានភាពសេដ្ឋកិច្ចជារួម និងការអនុវត្តនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា និង iii/-ផ្តល់ព័ត៌មានអំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុជូនសាធារណជនតាមប្រព័ន្ធហាត់ឡាញផងដែរ។ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ក៏បានចូលរួមយ៉ាងសំខាន់ក្នុងការអនុវត្តការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនិងគណនេយ្យភាពរបស់ប្រតិបត្តិការគ្រប់គ្រងសាច់ប្រាក់របស់អង្គភាពនានានៃរាជរដ្ឋាភិបាល។

**ក្រាហ្វ ៧០ ៖ ស្ថិតិមន្ត្រីបុគ្គលិកសាខារាជធានី-ខេត្ត**
(ឆ្នាំ២០២១)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## សន្និដ្ឋាន

នៅឆ្នាំ២០២១ សេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញ ប៉ុន្តែវិស័យចម្បងៗ មានល្បឿនកំណើនខុសគ្នា ដែលក្នុងនោះវិស័យកាត់ដេរបានចាប់ផ្តើមកើនឡើងលឿន ចំណែកឯវិស័យពាក់ព័ន្ធនឹងសេវាកម្ម ជាពិសេសវិស័យទេសចរណ៍បន្តធ្លាក់ចុះ។ ការអនុវត្តនយោបាយរូបិយវត្ថុវិត្ថារកម្មប្រកបដោយភាពប្រុងប្រយ័ត្ន ជាមួយនឹងការគ្រប់គ្រងបាននូវសម្ពាធលើតម្លៃប្រាក់រៀល បានបន្តរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដែលចូលរួមយ៉ាងសកម្មក្នុងការរក្សាស្ថិរភាពថ្លៃនិងការពារអំណាចទិញនៃប្រាក់ចំណូលរបស់ប្រជាជន។ ជាមួយគ្នានេះ ទុនបម្រុងអន្តរជាតិបន្តស្ថិតក្នុងកម្រិតខ្ពស់គ្រប់គ្រាន់ក្នុងការបម្រើដល់ការអនុវត្តនយោបាយរូបិយវត្ថុនិងអត្រាប្តូរប្រាក់ដែលបានរួមចំណែករក្សាជំនឿទុកចិត្តរបស់សាធារណជនមកលើសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ។

ការអនុវត្តវិធានការគាំទ្រជាបន្តបន្ទាប់ក្នុងវិស័យធនាគារ បានរក្សាភាពធន់នៃប្រព័ន្ធធនាគារនិងធ្វើឱ្យប្រព័ន្ធធនាគារដើរតួនាទីកាន់តែសំខាន់ ក្នុងការរក្សានិរន្តរភាពនៃអាជីវកម្មនិងជួយសម្រួលការលំបាករបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីវិបត្តិ។ ម្យ៉ាងទៀត ការធ្វើទំនើបកម្មប្រព័ន្ធធនាគារជាពិសេសប្រព័ន្ធទូទាត់ បានជួយសម្រួលដល់ដំណើរការសេដ្ឋកិច្ចនិងពាណិជ្ជកម្មទាំងក្នុងនិងក្រៅប្រទេស ដោយកាត់បន្ថយចំណាយប្រតិបត្តិការ បង្កើនល្បឿននិងប្រសិទ្ធភាពនៃការទូទាត់ និងគាំទ្រការប្រែក្លាយសេដ្ឋកិច្ចកម្ពុជាទៅជាសេដ្ឋកិច្ចឌីជីថលស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល។ ក្រៅពីនេះ ការជំរុញបរិយាបន្ននិងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការពង្រឹងយន្តការការពារអ្នកប្រើប្រាស់ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បានរក្សាជំនឿទុកចិត្តនិងអភិវឌ្ឍប្រព័ន្ធធនាគារប្រកបដោយចីរភាពនិងបរិយាបន្ន។

ប្រឈមនឹងស្ថានភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក កិច្ចសហប្រតិបត្តិការអន្តរជាតិជាពិសេសការបង្កើនសមាហរណកម្មវិស័យហិរញ្ញវត្ថុ ការពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់និងការផ្លាស់ប្តូរបទពិសោធន៍ក្នុងក្របខ័ណ្ឌទ្វេនិងពហុភាគី បានរួមចំណែកពង្រឹងភាពធន់និងការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុកម្ពុជា។ ទន្ទឹមនេះ អភិបាលកិច្ចល្អ ការអភិវឌ្ឍធនធានមនុស្សនិងគុណភាពសេវាធនាគារកណ្តាល ត្រូវបានបន្តលើកកម្ពស់ជាប្រចាំ ដើម្បីបង្កើនប្រសិទ្ធភាពការងារនិងគាំទ្រដល់ការរីកចម្រើនវិស័យធនាគារនិងសេដ្ឋកិច្ច។

# ផ្នែកទី២ - ទិសដៅការងារឆ្នាំ២០២២

## ទស្សនវិស័យនិងទិសដៅការងារឆ្នាំ២០២២

មូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករថា សេដ្ឋកិច្ចពិភពលោកឆ្នាំ២០២២ មានកំណើន ៤,៩% ដែលក្នុងនោះកំណើនសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍មាន ៤,៥% ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍មាន ៥,១% និងអាស៊ាន-៥[១] មាន ៥,៨%។[២] ទន្ទឹមនេះ សេដ្ឋកិច្ចពិភពលោកក៏ប្រឈមនឹងហានិភ័យចម្បងៗដូចជា៖ i/-ការអូសបន្លាយនៃជំងឺកូវីដ-១៩ និងការបំប្លែងនៃមេរោគកូវីដ-១៩ ii/-ការអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិតឡើងវិញដែលអាចធ្វើឱ្យមានសម្ពាធដល់អតិផរណា iii/-ការកើនឡើងបំណុលសាធារណៈនិងឯកជន iv/-ភាពតានតឹងភូមិសាស្ត្រនយោបាយ v/-ភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្ម និង vi/-គ្រោះមហន្តរាយធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

ការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក និងការបើកសេដ្ឋកិច្ចនិងប្រទេសឡើងវិញ នឹងគាំទ្រវិស័យចម្បងៗនៃសេដ្ឋកិច្ចកម្ពុជា។ វិស័យកាត់ដេរដែលមានចំណែកធំជាងគេក្នុងវិស័យឧស្សាហកម្មកម្ពុជា រំពឹងថាមានកំណើន ៦,៨% ដែលគាំទ្រជាចម្បងដោយភាពប្រសើរឡើងនៃតម្រូវការខាងក្រៅគួបផ្សំនឹងវិធានការគាំទ្ររបស់រដ្ឋាភិបាល។ វិស័យសំណង់រំពឹងថាមានកំណើន ៥% ដោយសារការរំពឹងទុកនៃកំណើនលំហូរទុនវិនិយោគបរទេសនិងតម្រូវការក្នុងស្រុក ដែលផ្តោតលើទីផ្សារអចលនទ្រព្យដែលមានតម្លៃសមរម្យ។ វិស័យកសិកម្មរំពឹងមានវឌ្ឍនភាពល្អជាមួយនឹងអត្រាកំណើន ១,១% ដោយសារគោលនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាលក្នុងការធ្វើពិពិធកម្មទៅកាន់វិស័យកសិ-ឧស្សាហកម្មនិងភាពអំណោយផលនៃកត្តាអាកាសធាតុ។ វិស័យទេសចរណ៍ រំពឹងថាកើនឡើងដោយសារគោលនយោបាយគាំទ្រវិស័យទេសចរណ៍របស់រាជរដ្ឋាភិបាល និងអាចមានកំណើនយឺតត្រឹម ១,៥% ដែលបណ្តាលមកពីការហូរចូលយឺតនៃភ្ញៀវទេសចរអន្តរជាតិ។ នៅក្នុងវិស័យហិរញ្ញវត្ថុ វិស័យធនាគារនឹងបន្តរក្សាបានស្ថិរភាពនិងការចូលរួមគាំទ្រកំណើនសេដ្ឋកិច្ច តាមរយៈការផ្តល់ហិរញ្ញប្បទានដល់វិស័យឯកជន, បរិយាបន្នហិរញ្ញវត្ថុ និងជួយសម្រាលបន្ទុកប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ដូចជា ការរៀបចំឥណទានឡើងវិញ ជាដើម។ ជាមួយនឹងបច្ច័យវិជ្ជមានទាំងនេះ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងមានអត្រាកំណើន ៤,៨% នាឆ្នាំ២០២២។

---

[១] អាស៊ាន-៥ រួមមាន ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និង វៀតណាម។

[២] សេដ្ឋកិច្ចសហរដ្ឋអាមេរិកមានកំណើន ៥,២% សហភាពអឺរ៉ុប ៤,៣% ចក្រភពអង់គ្លេស ៥% និងចិន ៥,៦%។

## តារាង ៣ ៖ កំណើនសេដ្ឋកិច្ចកម្ពុជាតាមវិស័យ

| | ឆ្នាំ២០២០ | ឆ្នាំ២០២១ប | ឆ្នាំ២០២២ព |
|---|---|---|---|
| កសិកម្ម | ០,៧៩% | ១,៨១% | ១,១១% |
| ឧស្សាហកម្ម | -២,៧៦% | ៥,៦៩% | ៧,៦៩% |
| សេវាកម្ម | -៥,៤២% | ០,៣១% | ៤,១៥% |
| **កំណើនផ.ស.ស** | **-៣,១៣%** | **២,៤២%** | **៤,៧៩%** |

*សម្គាល់៖ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

## តារាង ៤ ៖ ការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជារបស់ស្ថាប័នអន្តរជាតិ

| | ឆ្នាំ២០២១ប | ឆ្នាំ២០២២ព |
|---|---|---|
| រាជរដ្ឋាភិបាល | ៣% | ៤,៨% |
| មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) | ១,៩% | ៥,៧% |
| ធនាគារពិភពលោក (WB) | ២,២% | ៤,៥% |
| ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) | ១,៩% | ៥,៥% |

*សម្គាល់៖ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

## កត្តាអំណោយផលនិងហានិភ័យចំពោះកំណើនសេដ្ឋកិច្ចកម្ពុជា

**កត្តាអំណោយផល**

+ការកើនឡើងវិញនៃការវិនិយោគក្នុងតំបន់
+ មានទីតាំងភូមិសាស្ត្រនៅចំកណ្តាលអាស៊ាន
+ ការកើនឡើងការវិនិយោគក្នុងវិស័យកសិ-ឧស្សាហកម្ម
+ លទ្ធភាពខ្ពស់នៃវិស័យធនាគារក្នុងការឆ្លើយតបនឹងតម្រូវការហិរញ្ញប្បទានក្នុងពេលមានវិបត្តិ
+ សេដ្ឋកិច្ចមានភាពបើកទូលាយនិងសមាហរណកម្មខ្ពស់
+ ស្ថិរភាពនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
+ កត្តាភាគលាភប្រជាសាស្ត្រ



**ហានិភ័យនិងបញ្ហាប្រឈម**

- ការអូសបន្លាយនៃជំងឺកូវីដ-១៩ និងការបំប្លែងនៃមេរោគប្រភេទថ្មី
- កំណើនទាបជាងការរំពឹងទុកនៃសេដ្ឋកិច្ចពិភពលោក និងតំបន់
- ការកើនឡើងភាពប្រកួតប្រជែងនិងនយោបាយគាំពារនិយម
- ភាពមិនច្បាស់លាស់នៃការប្រែប្រួលអាកាសធាតុ
-ការកើនឡើងបំណុលសាជីវកម្មនិងគ្រួសារ
- ការធ្លាក់ចុះនៃទេសចរអន្តរជាតិ

ជាមួយនឹងការព្យាករដោយសុទិដ្ឋិនិយម សេដ្ឋកិច្ចកម្ពុជាក៏ប្រឈមនឹងហានិភ័យមួយចំនួនផងដែររួមមាន៖ i/-ការបន្តរាលដាលនៃជំងឺកូវីដ-១៩ និងការបំប្លែងនៃមេរោគប្រភេទថ្មី ii/-ការកើនឡើងការប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិ ដោយសារប្រទេសមួយចំនួនដែលនាំចេញផលិតផលដូចកម្ពុជា ទទួលបានការអនុគ្រោះពន្ធនិងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសដែលជាទីផ្សារនាំចេញរបស់កម្ពុជា iii/-ការកើនឡើងបំណុលរបស់សាជីវកម្មនិងក្រុមគ្រួសារប្រសិនបើការរាលដាលនៃជំងឺកូវីដ-១៩ នៅតែបន្ត iv/-កំណើនយឺតនៃវិស័យទេសចរណ៍ដែលនឹងប៉ះពាល់ដល់រចនាសម្ព័ន្ធសេដ្ឋកិច្ចនិងទីផ្សារការងារ និង v/-ការប្រែប្រួលអាកាសធាតុដែលអាចបន្ថយកំណើនក្នុងវិស័យកសិកម្ម។ ទន្ទឹមនេះបញ្ហាប្រឈមជារចនាសម្ព័ន្ធរបស់សេដ្ឋកិច្ចកម្ពុជា រួមមាន៖ i/-ភាពប្រកួតប្រជែងរបស់កម្ពុជានៅមានកម្រិត ដោយសារថ្លៃដើមផលិតកម្មខ្ពស់និងកង្វះហេដ្ឋារចនាសម្ព័ន្ធ ii/-ការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចមានល្បឿនយឺតនៅឡើយ និង iii/-កម្រិតខ្ពស់នៃដុល្លារូបនីយកម្ម ដែលដាក់សម្ពាធលើការអនុវត្តនយោបាយរូបិយវត្ថុ។

ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារកំណើនសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានកំណត់ទិសដៅការងារសំខាន់ៗសម្រាប់ឆ្នាំ២០២២ មានដូចខាងក្រោម៖

## ១- ការអនុវត្តនយោបាយរូបិយវត្ថុ

- គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប
- រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែកស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជន
- លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមយន្តការទីផ្សារ
- អភិវឌ្ឍឧបករណ៍នយោបាយរូបិយវត្ថុថ្មីៗ និង
- ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនយោបាយរូបិយវត្ថុ។

## ២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

- អនុវត្តសេចក្តីណែនាំការវិនិយោគសម្រាប់ឆ្នាំ២០២២
- សិក្សាស្រាវជ្រាវលើឧបករណ៍វិនិយោគថ្មីៗ ដើម្បីសម្រេចបានពិពិធកម្មហានិភ័យនិងបង្កើនចំណូល
- សិក្សាស្រាវជ្រាវលើការរៀបចំថវិកាហានិភ័យ និងពង្រឹងការវាស់វែងសមិទ្ធផលសំពៀតវិនិយោគ តាមរយៈការសិក្សាស្រាវជ្រាវលើម៉ូឌែលថ្មីៗ និង
- សិក្សាពីឱកាស និងលទ្ធភាពពង្រីកការវិនិយោគក្រោមក្របខ័ណ្ឌការវិនិយោគប្រកបដោយការទទួលខុសត្រូវ។

## ៣- ការអភិវឌ្ឍប្រព័ន្ធទូទាត់

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ក្នុងនោះរួមមានប្រព័ន្ធទូទាត់សងប្រាក់រាយនិងប្រព័ន្ធទូទាត់សងប្រាក់តម្លៃធំ
- តភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែនជាមួយប្រទេសក្នុងតំបន់

- លើកកម្ពស់បច្ចេកវិទ្យាហិរញ្ញវត្ថុស្របតាមផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ២០២០-២០២៥
- លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធបាគង និងបន្តអភិវឌ្ឍប្រព័ន្ធបាគងដំណាក់កាលបន្ទាប់
- ពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់ និងសេវាទូទាត់សងប្រាក់ និង
- ត្រួតពិនិត្យនិងវាយតម្លៃប្រព័ន្ធទូទាត់សងប្រាក់ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។

## ៤- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

- ប្រមូល គ្រប់គ្រង និងលើកកម្ពស់គុណភាពទិន្នន័យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- វិភាគ និងតាមដានសុខុមាលភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាប់ជាប្រចាំតាមរយៈការធ្វើបច្ចុប្បន្នភាពលើស្ថានភាពនិងការវិវឌ្ឍរបស់គ្រឹះស្ថាន និងបន្តអនុវត្តការត្រួតពិនិត្យប្រកបដោយឥរិយាបទទន់ភ្លន់និងប្រុងប្រយ័ត្ន សម្រាប់គាំទ្រកំណើនសេដ្ឋកិច្ច
- ធ្វើបច្ចុប្បន្នភាពវិធីសាស្ត្រត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្តោតលើហានិភ័យនិងទស្សនៈអនាគត
- ពិនិត្យ និងកែសម្រួលបទប្បញ្ញត្តិទាក់ទងនឹងក្របខ័ណ្ឌសាធនភាព/ភាពគ្រប់គ្រាន់នៃដើមទុនសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាការរៀបចំបទប្បញ្ញត្តិថ្មីៗបន្ថែម
- តាមដានការអនុវត្តវិធានការអនុគ្រោះនានាដែលបានដាក់ចេញក្នុងអំឡុងពេលនៃការរាលដាលនៃជំងឺកូវីដ-១៩ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រចាកចេញពីវិបត្តិ (Exit Strategy) របស់គ្រឹះស្ថាន
- តាមដានការអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥
- ត្រួតពិនិត្យក្រុមហ៊ុនផ្តល់សេវាចែករំលែកព័ត៌មានឥណទានជាប្រចាំ និង
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិក្នុងក្របខ័ណ្ឌត្រួតពិនិត្យ និងបណ្តុះបណ្តាលការងារបរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន

## ៥- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

- ផ្សព្វផ្សាយនិងពង្រឹងចំណេះដឹងដល់បុគ្គលរាយការណ៍និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិជាធរមាន
- រៀបចំ និងដាក់ឱ្យអនុវត្តសេចក្តីណែនាំនានា តាមការតម្រូវនៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- អនុវត្តការត្រួតពិនិត្យអំពីការប្រតិបត្តិតាមច្បាប់និងបទប្បញ្ញត្តិរបស់បុគ្គលរាយការណ៍
- បន្តពង្រឹងសមត្ថភាពនៃការត្រួតពិនិត្យនិងការវិភាគប្រតិបត្តិការហិរញ្ញវត្ថុឱ្យកាន់តែមានគុណភាពល្អថែមទៀត
- រៀបចំប្រព័ន្ធវិភាគការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មផ្ទៃក្នុងជាមួយនាយកដ្ឋានព័ត៌មានវិទ្យា

- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ
- សម្របសម្រួលការអនុវត្តផែនការសកម្មភាពដែលកំណត់ក្នុងយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣
- សហការជាមួយ APG ដើម្បីដំឡើងចំណាត់ថ្នាក់នៃការអនុលោមតាមផ្នែកបច្ចេកទេសរបស់កម្ពុជា
- ដឹកនាំនិងសម្របសម្រួលការអនុវត្តផែនការសកម្មភាពរបស់ក្រុមការងារ ICRG-JG របស់ FATF និង
- រៀបចំ និងសម្របសម្រួលការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញ-ប្បទានភេរវកម្ម លើកទី២។

## ៦- ការងារប្រតិបត្តិការ

- ផ្តល់សន្ទនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ ដើម្បីធានាឱ្យសភាផាត់ទាត់ជាតិប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព
- ផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) និងផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF) ក្នុងទំហំសមស្រប និង
- អភិវឌ្ឍទីផ្សារអន្តរធនាគារ តាមរយៈការចូលរួមបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មីៗ និងលើកកម្ពស់ការប្រើប្រាស់មូលបត្រអាចជួញដូរបាន (NCD)។

## ៧- ការងារបោះផ្សាយនិងឃ្លាំងបេឡា

- ពង្រឹងសេវាបង់និងបើកសាច់ប្រាក់នៅបញ្ជរធនាគារជាតិនៃកម្ពុជា
- ពង្រឹងការងារដឹកជញ្ជូនធនបត្រ និងការរាប់ស្រាល់ជ្រើសក្រដាសប្រាក់
- លើកកម្ពស់ការងារគ្រប់គ្រងសាច់ប្រាក់ និងការថែរក្សាសុវត្ថិភាពឃ្លាំងប្រាក់ និង
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចទប់ស្កាត់ការចរាចរក្រដាសប្រាក់ក្លែងក្លាយ។

## ៨- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ

- អនុវត្តការងារសវនកម្ម និងអធិការកិច្ចស្របតាមផែនការសវនកម្មឆ្នាំ២០២២ និងតាមការចាំបាច់
- ពង្រឹងសមត្ថភាព ដើម្បីបង្កើនគុណភាពសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ស្របតាមសភាពការណ៍ដែលត្រូវអនុវត្តការងារតាមគន្លងថ្មី
- រៀបចំនីតិវិធីថ្មីសម្រាប់សវនកម្មពីចម្ងាយ និងសាកល្បងអនុវត្តការធ្វើសវនកម្មតាមនីតិវិធីថ្មីនេះ និង
- សិក្សាអំពីការធ្វើសវនកម្មដោយផ្អែកលើហានិភ័យ (Risk-based Audit) និងការគ្រប់គ្រងហានិភ័យដោយផ្អែកលើក្របខ័ណ្ឌខ្សែការពារទាំងបី (The Three Line of Defense)។

## ៩- ការគ្រប់គ្រងសាខា

- ពង្រឹងប្រតិបត្តិការការងារនៅតាមសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ស្របតាមការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់
- សហការជាមួយអាជ្ញាធរមូលដ្ឋានប្រចាំសាខារាជធានី-ខេត្ត សំដៅជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ និង
- ពង្រឹងការតាមដានស្ថានភាពសេដ្ឋកិច្ច និងលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ។

## ១០- គណនេយ្យ

- ពិនិត្យនិងវាយតម្លៃលើការអនុវត្តផែនការថវិការបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ឆ្នាំ២០២១ និងរៀបចំផែនការថវិកាសម្រាប់ឆ្នាំ២០២២
- សហការ និងពង្រឹងការងារគ្រប់គ្រងបញ្ជីទ្រព្យសម្បត្តិរបស់ធនាគារជាតិនៃកម្ពុជា
- ចុះពិនិត្យដោយផ្ទាល់នូវកិច្ចបញ្ជិកាគណនេយ្យ និងឯកសារគណនេយ្យនៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ដើម្បីធានាពីភាពត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុរបស់សាខា និង
- រៀបចំវគ្គបណ្តុះបណ្តាលលើការប្រើប្រាស់ប្រព័ន្ធធនាគារស្នូល Flexcube និងសៀវភៅក្រហមដល់មន្ត្រីបុគ្គលិកនៅសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត។

## ១១- ការគ្រប់គ្រង និងបណ្តុះបណ្តាល

- កែលម្អកម្មវិធីបណ្តុះបណ្តាល និងបើកវគ្គប្រតិបត្តិការធនាគារកណ្តាល វគ្គត្រួតពិនិត្យធនាគារ វគ្គភាពជាអ្នកដឹកនាំ និងរៀបចំកិច្ចប្រជុំផ្សេងៗនៅធនាគារជាតិនៃកម្ពុជា
- រៀបចំនិងកែលម្អគោលនយោបាយគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស ដើម្បីធានាឱ្យបាននូវនិរន្តរភាព សុវត្ថិភាព និងប្រសិទ្ធភាពការងារ
- រៀបចំគោលនយោបាយលើកទឹកចិត្តមន្ត្រីបុគ្គលិក ដើម្បីពង្រឹងឯកទេសកម្មជំនាញត្រួតពិនិត្យធនាគារ ជំនាញសេដ្ឋកិច្ច ជំនាញវិភាគហិរញ្ញវត្ថុ ជំនាញគណនេយ្យ និងសវនកម្មផ្ទៃក្នុង
